សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# កំណែទម្រង់ស្ថាប័នជាតិរៀបចំការបោះឆ្នោតនៅកម្ពុជា ឆ្នាំ២០១៥

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **អ៊ុំ ម៉ុំម៉ាជីកូ**

សាស្ត្រាចារ្យណែនាំ
លោក **យូ តូនី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៧

ឆ្នាំចូលសិក្សា ២០១៣
ឆ្នាំសរសេរសារណា ២០១៧

# អារម្ភកថា

បន្ទាប់ពីបានទទួលការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រអស់រយៈពេល ៤ឆ្នាំទៅលើមុខវិជ្ជាជាច្រើនរួចមកយើងបានទទួលចំណេះដឹងយ៉ាងទូលំទូលាយពីមុខវិជ្ជាទាំងនោះ ក្រោមការជួយខិតខំប្រឹងប្រែងរបស់ លោក លោកស្រីសាស្ត្រាចារ្យ ដែលបានខិតខំយកចិត្តទុកដាក់បង្រៀនដល់រូបខ្ញុំ។ ដោយមានការជួយណែនាំជ្រោមជ្រែង និងការយកចិត្តទុកដាក់ខ្ពស់ដល់ការបង្ហាត់បង្ហាញក្នុងការបង្រៀនអស់ពីកម្លាំងកាយកម្លាំងចិត្តទាំងអស់នេះហើយ ទើបធ្វើឱ្យខ្ញុំអាចឈានមកដល់ការចងក្រងសរសេរជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះឡើង ដើម្បីជាប្រយោជន៍ទូទៅក្នុងក្នុងសង្គម និងការសិក្សាស្រាវជ្រាវ។

ក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះឡើង ខ្ញុំបានជ្រើសរើសយកប្រធានបទមួយទាក់ទងទៅនឹងស្ថាប័នជាតិរៀបចំការបោះឆ្នោតដែលមានចំណងជើងថា "កំណែទម្រង់ស្ថាប័នជាតិរៀបចំការបោះឆ្នោត នៅកម្ពុជាឆ្នាំ២០១៥"។ ការជ្រើសរើសយកប្រធានបទនេះ គឺដើម្បីឱ្យសិស្សនិស្សិត ជាពិសេសមជ្ឈដ្ឋានអ្នកសិក្សាស្រាវជ្រាវទូទៅ ដែលមានបំណងចង់សិក្សាពីស្ថាប័នឯករាជ្យរបស់ជាតិមួយនេះ ចាប់តាំងពីការកកើតរហូតឈានដល់មានការកំណែទម្រង់នៅចុងឆ្នាំ ២០១៥ នេះ។

ខ្ញុំសង្ឃឹមថាយ៉ាងមុតមាំថា សារណានេះនឹងអាចជាជំនួយដល់ការសិក្សាស្រាវជ្រាវរបស់សិស្ស និស្សិត មជ្ឈដ្ឋានអ្នកសិក្សាទូទៅនិងក៏ដូចជាប្រជាពលរដ្ឋគ្រប់រូបដែលមានបំណងចង់ស្វែងយល់បន្ថែមទៅនឹងស្ថាប័នជាតិរៀបចំការបោះឆ្នោត ដែលហៅកាត់ថា គ.ជ.ប ដែលទទួលបន្ទុកក្នុងការរៀបចំការបោះឆ្នោតនៅកម្ពុជាចាប់តាំងពីឆ្នាំ១៩៩៨ មកនោះ។ សារណានេះ ក៏ទុកជាស្ពាដៃសម្រាប់អ្នកសិក្សាជំនាន់ក្រោយ ដើម្បីសិក្សាបន្ថែមឱ្យកាន់តែច្បាស់អំពី កំណែទម្រង់ស្ថាប័នជាតិរៀបចំការបោះឆ្នោត នៅកម្ពុជាឆ្នាំ២០១៥។

ជាការពិតណាស់ ការសរសេរជៀសមិនផុតពីកំហុសអចេតនា និងចំណុចខ្វះខាតមួយចំនួនកើតឡើងជាក់ជាមិនខាន ដូចជាពាក្យពេចន៍ ខ្លឹមសារ អត្ថន័យ និងអក្ខរាវិរុទ្ធជាដើម។ ខ្ញុំសូមទទួលស្វាគមន៍ជានិច្ច នូវរាល់មតិរិះគន់កែលម្អក្នុងន័យស្ថាបនាជាមួយគំនិតល្អៗ របស់មិត្តអ្នកអានទាំងអស់ ក្នុងគោលបំណងឱ្យកាន់តែមានភាពល្អប្រសើរជាងមុន៕

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទជានិស្សិតឆ្នាំទី៤ ជំនាន់ទី១៧ ផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០១៣-២០១៧។ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ លោកឪពុក **អ៊ុំ សំអាន** និងអ្នកម្តាយ **តូច គឿក** ជាទីគោរពស្រលាញ់នៃកូន ដែលលោកបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាកូនដោយក្តីមេត្តា ករុណា ចំពោះរូបកូនតាំងពីតូចរហូតដល់ធំពេញវ័យ ដែលរូបលោកទាំងពីរបានលះបង់គ្រប់យ៉ាងនូវកម្លាំងកាយចិត្ត ថវិកា អប់រំទូន្មានប្រៀនប្រដៅកូន ជំរុញលើកទឹកចិត្តដល់កូនក្នុងការសិក្សារៀនសូត្រ ឱ្យកូនធ្វើខ្លួនជាកូនល្អសិស្សល្អ ពលរដ្ឋល្អ នៅក្នុងសង្គម។ ទឹកចិត្តដែលរិតតែមិនអាចកាត់ថ្លៃបាន ដោយការយកចិត្តទុកដាក់ និងខិតខំរបស់លោកទាំងពីរ ដើម្បីឱ្យរូបកូនបានបន្តការសិក្សាចាប់តាំងពីគ្រូចាប់ដៃឱ្យសរសេរអក្សរ រហូតដល់កូនបានរៀនបន្តដល់មហាវិទ្យាល័យ ទើបកូនមានថ្ងៃនេះគឺ ជាថ្ងៃដែលកូនបានបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រប្រកបដោយភាពជោគជ័យ។

ទន្ទឹមនេះដែរ ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះ **ឯកឧត្តមបណ្ឌិត លុយ ចន្ធា** សាកលវិទ្យាធិការ នៃវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានគ្រប់គ្រងឱ្យដំណើរការទូទៅក្នុងសាកលវិទ្យាល័យប្រកបដោយភាពរីកចម្រើន ជាពិសេសផ្តល់ឱកាស និងភាពងាយស្រួលជូនដល់និស្សិត បានទទួលការសិក្សាគ្រប់ៗគ្នា ដើម្បីជាធនធានសម្រាប់យកទៅបម្រើសង្គមជាតិ តាមជំនាញនីមួយៗក្នុងទិសដៅតែមួយ គឺការអភិវឌ្ឍកម្ពុជាប្រកបដោយចីរភាព។

ម្យ៉ាងទៀត ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យទាំងអស់ដែលបានខិតខំបង្រៀនអស់ពីកម្លាំងកាយចិត្ត និងផ្តល់នូវចំណេះដឹង ចែករំលែកយ៉ាងច្រើនដល់រូបខ្ញុំឱ្យឈានដល់ការបង្កើតស្នាដៃនេះឡើង។

ជាងនេះទៅទៀត ខ្ញុំសូមគោរពថ្លែងអំណរគុណចំពោះ **លោកសាស្ត្រាចារ្យ យូ តូនី** ដែលជាសាស្ត្រាចារ្យណែនាំដល់ខ្ញុំបាទ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការជួយបង្ហាត់បង្ហាញណែនាំ កែតម្រូវ ផ្តល់អនុសាសន៍ និងជំរុញដល់ខ្ញុំដើម្បីឱ្យកិច្ចការស្រាវជ្រាវនេះទទួលបានជោគជ័យ។

ចុងបញ្ចប់នេះ ខ្ញុំបាទសូមបួងសួងដល់វត្ថុស័ក្តសិទ្ធិក្នុងលោកទាំងអស់ តាមជួយថែរក្សាការពារ ប្រសិទ្ធពរជ័យ សេចក្តីសុខចម្រើនជូនដល់អស់លោកទាំងអស់គ្នា ឱ្យមានសុខភាពល្អកម្លាំងមាំមួន អាយុយឺនយូរ ទទួលបានជោគជ័យគ្រប់ភារកិច្ច និងរាល់សេចក្តីប៉ងប្រាថ្នា ជាពិសេសសូមជួបនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........................................................................................................ ១

**ជំពូកទី ១**

**ការកើតឡើងនៃស្ថាប័នជាតិរៀបចំការបោះឆ្នោត**

**១. ស្ថាប័នរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅនីតិកាលនីមួយៗ** ......៨

**១.១ ស្ថាប័នរៀបចំការបោះឆ្នោតឆ្នាំ១៩៩៨ នៃរដ្ឋសភានីតិកាលទី២** ........................៨

ក.សមាសភាពសមាជិក គ ជ ប ..........................................................................................៩

ខ. ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី២ .........................................................៩

**១.២ ស្ថាប័នរៀបចំការបោះឆ្នោតឆ្នាំ២០០៣ នៃរដ្ឋសភានីតិកាលទី៣** ......................១១

ក.សមាសភាពសមាជិក គ ជ ប ........................................................................................១១

ខ. ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៣ .......................................................១១

**១.៣ ស្ថាប័នរៀបចំការបោះឆ្នោតឆ្នាំ២០០៨ នៃរដ្ឋសភានីតិកាលទី៤** ........................១២

ក.សមាសភាពសមាជិក គ ជ ប ........................................................................................១៣

ខ. ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៤ .......................................................១៣

**១.៤ ស្ថាប័នរៀបចំការបោះឆ្នោតឆ្នាំ២០១៣ នៃរដ្ឋសភានីតិកាលទី៥** ........................១៤

ក.សមាសភាពសមាជិក គ ជ ប ....................................................................................... ១៤

ខ. ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ..................................................... .១៥

**២. ការបោះឆ្នោតផ្សេងៗទៀតដែលត្រូវរៀបចំដោយ គ ជ ប ពីនីតិកាលទី២ ដល់នីតិកាលទី៥ នៃរដ្ឋសភា** ....................១៧

**២.១. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ - សង្កាត់** ....................១៧

ក. ការរៀបចំការបោះឆ្នោតជ្រើសក្រុមប្រឹក្សាឃុំ-សង្កាត់ ឆ្នាំ២០០២ ....................១៨

ខ.ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ឆ្នាំ២០០៧ .................... ២០

គ.ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ឆ្នាំ២០១២ .................... ២២

**២.២ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ** ........២៣

ក.ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា រាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក-ខណ្ឌ ឆ្នាំ២០០៩ ....................២៣

ខ.ការបោះឆ្នោតឡើងវិញជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ ឆ្នាំ២០១១ ....................២៥

គ. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០១៤ .................... ២៦

## ជំពូកទី ២

## ការដាក់បញ្ចូលស្ថាប័នរៀបចំការបោះឆ្នោតទៅជាស្ថាប័នមានចែងក្នុងរដ្ឋធម្មនុញ្ញ

**១. បញ្ហាប្រឈមក្រោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នៃនីតិកាលនីមួយៗ** ....................២៨

**១.១ ហេតុការណ៍ដែលៗកើតឡើងក្រោយពេលប្រកាសលទ្ធផលឆ្នោតរបស់ គ ជ ប** ....................២៩

**១.២ ហេតុការណ៍កើតឡើងក្រោយពេលប្រកាសលទ្ធផលបោះឆ្នោតរបស់ គ ជ ប នៅឆ្នាំ ២០១៣** ....................៣០

ក. ការមិនទទួលស្គាល់លទ្ធផលរបស់គណបក្សសង្គ្រោះជាតិ ....................៣០

ខ. គណបក្សសង្គ្រោះជាតិទាមទារឲ្យមានការបោះឆ្នោតឡើងវិញ ..................................៣៥

**២. ដំណោះស្រាយនយោបាយ** ..................................................................................៤០

**២.១ កិច្ចព្រមព្រៀងនយោបាយថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤** ...............................៤០

**២.២ ការឈានទៅដល់ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញដើម្បីដាក់ គ ជ ប ជាស្ថាប័នរដ្ឋធម្មនុញ្ញ** ...........................................................................................៤៦

## ជំពូកទី ៣

## ស្ថាប័នជាតិរៀបចំការបោះឆ្នោតថ្មី ក្រោយកំណែទម្រង់

**១. រចនាសម្ព័ន្ធរបស់ គ ជ ប** ......................................................................................៤៨

**១.១ សមាសភាពសមាជិក គ ជ ប** ........................................................................ ៤៨

ក.ការជ្រើសរើសសមាជិក គ ជ ប របស់គណបក្សមានអាសនៈក្នុងរដ្ឋសភា ..................... ៥២

ខ.ការជ្រើសតាំងសមាជិក គ ជ ប តាមការព្រមព្រៀងរបស់គណបក្សមានអាសនៈក្នុងរដ្ឋសភា .......................................................................................................៥២

គ.រដ្ឋសភាបោះឆ្នោតផ្តល់សេចក្តីទុកចិត្ត ប្រធាន អនុប្រធាន សមាជិក និងសមាជិការបស់ គ ជ ប .......................................................................................................៥៤

**១.២ រចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាននៃ គ ជ ប** ..............................................៥៤

- អគ្គលេខាធិការដ្ឋាន ...................................................................................................៥៤

ក. លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន ..................................................................៥៦

ខ. នាយកដ្ឋានរដ្ឋបាល ...................................................................................................៥៦

គ. នាយកដ្ឋានប្រតិបត្តិការ ..............................................................................................៥៧

ឃ. នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត....................................៥៨

ង. នាយកដ្ឋានហិរញ្ញវត្ថុ.....................................................................................................៥៩

ច. នាយកដ្ឋានបណ្តុះបណ្តាលនិងអប់រំអ្នកបោះឆ្នោត....................................................៥៩

ឆ. នាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ........................................................៦០

ជ. នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម....................................................................៦១

ឈ. នាយកដ្ឋានសវនកម្មផ្ទៃក្នុង......................................................................................៦២

ញ. លេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត...............................៦២

**២. ការវិវត្តនៃបច្ចេកទេសការងាររបស់ គ ជ ប** ...............................................................៦៣

**១.១ ការផ្តល់ជំនួយរបស់បរទេសសម្រាប់ការងារបោះឆ្នោត**.....................................៦៣

ក.ជំនួយប្រទេស ជប៉ុន.................................................................................................៦៣

ខ.ជំនួយសហភាពអ៊ឺរ៉ុប ...............................................................................................៦៤

គ.ជំនួយប្រទេស ចិន....................................................................................................៦៤

**១.២ ប្រព័ន្ធសុក្រឹតភាពសម្រាប់ប្រព័ន្ធចុះឈ្មោះអ្នកបោះឆ្នោត**.................................៦៥

**សេចក្តីសន្និដ្ឋាន**..................................................................................................៦៦

**អនុសាសន៍**..........................................................................................................៦៧

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជាអនុវត្តនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស។ ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួន។ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋខ្មែរ ដែលប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈការបោះឆ្នោត។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ជំពូកទី១៥ ថ្មី(ពីរ) ត្រង់ខ្លឹមសារមាត្រា ១៥០ ថ្មី(ពីរ)ចែងថា " គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គឺជាអង្គការដែលមានសមត្ថកិច្ចរៀបចំចាត់ចែង និងគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ព្រមទាំងការបោះឆ្នោតផ្សេងទៀត តាមការកំណត់នៃច្បាប់។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបានអនុវត្តសមត្ថកិច្ចរបស់ខ្លួនប្រកបដោយឯករាជ្យ និងអព្យាក្រឹត ដើម្បីធានាឲ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។ មុខងារជាសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានវិសមិតភាពជាមួយការបំពេញមុខតំណែងក្នុងមុខងារសាធារណៈ និងជាមួយមុខងារជាសមាជិកនៃស្ថាប័នដទៃទៀត ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនេះ។ សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនអាចធ្វើជាសមាជិកនៃគណបក្សនយោបាយ ឬធ្វើជាអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬក្រុមហ៊ុនពាណិជ្ជកម្មណាមួយបានឡើយ [១]។

ការបោះឆ្នោត គឺជាគន្លឹះនៃការកសាងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ការបង្រួបបង្រួមជាតិ ឲ្យមានសន្តិភាព និងការអភិវឌ្ឍនៅប្រទេសកម្ពុជា ។ ប្រសិនបើគ្មានការបោះឆ្នោតនៅកម្ពុជាទេ នោះប្រទេសកម្ពុជាមិនអាចបញ្ចប់បាននូវសង្គ្រាមដ៏រ៉ាំរ៉ៃជាង ៣ ទសវត្ស ពុំអាចផ្សះផ្សារបាននូវការបែកបាក់ជាតិ និងពិតជាមិនអាចលុបបំបាត់បាននូវវិនាសកម្មដ៏ជូរចត់ខ្លោចផ្សារក្នុងសង្គ្រាមរវាងជាតិសាសន៍ឯងបានឡើយ ។

វត្តមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ជាផ្នែកមួយដែលជំរុញឲ្យមានការបោះឆ្នោតនៅកម្ពុជា ក៏ប៉ុន្តែទម្រាំសម្រេចបានដូច្នេះ គឺត្រូវបានចំណាយពេលវេលាអស់ជាច្រើនឆ្នាំ។ បញ្ហាកម្ពុជានេះបានធ្វើឲ្យអង្គការសហប្រជាជាតិ និងប្រទេសដែលជាហត្ថលេខីនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស រួមទាំងសហគមន៍អន្តរជាតិ បានខិតខំប្រឹងប្រែងនិងប្រើប្រាស់បញ្ញាស្មារតី សម្ភារៈ ថវិកា ក៏ដូចជាធនធានមនុស្សអស់ច្រើនសន្ធឹកសន្ធាប់ណាស់ ដើម្បីនាំមកឲ្យខាងតែបាននូវសន្តិភាពជូនប្រទេសជាតិ និងប្រជាពលរដ្ឋកម្ពុជា ដោយសារតែមនោគមន៍វិជ្ជារបស់

(១).មាត្រា ១៥០ ថ្មី(ពីរ) រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

បរទេស និងការបែកបាក់ផ្ទៃក្នុងជាតិសាសន៍ឯង។ សមិទ្ធិផលទាំងឡាយនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ជាសក្ខីភាពនៃសប្បុរសធម៌ដែលបានផ្តល់កំណើតលើកទី២នូវព្រះរាជាណាចក្រកម្ពុជា។ ប្រសិនបើ គ្មានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនោះទេ នោះសង្គ្រាមនៅតែបន្តការបំផ្លិចបំផ្លាញប្រទេសជាតិ និងជីវិតរបស់ប្រជាពលរដ្ឋកម្ពុជា ពុំដឹងពេលណានឹងបញ្ចប់បាននោះឡើយ។ ចំពោះប្រជាពលរដ្ឋកម្ពុជា កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសដែលស្តែងឡើងតាមរយៈការបង្កើតឲ្យមានការដោះស្រាយបញ្ហានយោបាយ តាមការបោះឆ្នោតបែបប្រជាធិបតេយ្យសេរីពហុបក្ស។

បន្ទាប់ពីនោះវត្តមានរបស់អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិ(UNTAC) បានបង្កបរិយាកាសមួយឲ្យកម្ពុជាមាននូវការបោះឆ្នោតជាសកល ដោយសេរី និងយុត្តិធម៌ ដែលចេញពីឆន្ទៈពិតប្រាកដរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូបក្នុងគោលដៅជ្រើសតាំងសមាជិកសភាធម្មនុញ្ញដើម្បីតាក់តែងរដ្ឋធម្មនុញ្ញ និងបង្កើតរាជរដ្ឋាភិបាលស្របច្បាប់ថ្មីមួយនៅកម្ពុជា។ ការបោះឆ្នោតជាតិលើកទី១ ត្រូវបានធ្វើឡើងនៅថ្ងៃទី ២៣-២៨ ខែឧសភា ឆ្នាំ១៩៩៣។ បើទោះជាមានអស្ថេរភាពនៅតាមតំបន់ខ្លះគ្រប់គ្រងដោយខ្មែរក្រហម អ្នកទៅបោះឆ្នោតមានចំនួនច្រើន ស្មើនឹង ៨៦.៧៨ ភាគរយ នៃអ្នកចុះឈ្មោះបោះឆ្នោតសរុបជិត ៥លាននាក់[២]។ គណបក្សនយោបាយចំនួន ៤ បានឈ្នះអាសនៈនៅក្នុងសភាធម្មនុញ្ញ ប៉ុន្តែគ្មានគណបក្សណា គ្រប់គ្រងអាសនៈភាគច្រើនដាច់ខាត២/៣ ដែលត្រូវការចាំបាច់សម្រាប់បង្កើតរដ្ឋាភិបាលថ្មីនោះទេ ដែលជាហេតុនាំឱ្យមានរដ្ឋាភិបាលចម្រុះ។ ការបោះឆ្នោតប្រព្រឹត្តទៅក្នុងបរិយាកាសនយោបាយអព្យាក្រឹត្យ មានការគោរពយ៉ាងពេញលេញដល់អធិបតេយ្យភាពកម្ពុជា និងធ្វើឡើងតាមប្រព័ន្ធសមាមាត្រ ដែលមានការស្នើឡើងពីគណបក្សនយោបាយនានាដែលបានចុះឈ្មោះចូលរួមប្រកួតប្រជែង។ ការបោះឆ្នោតជ្រើសតាំងសមាជិកសភាធម្មនុញ្ញនេះត្រូវបានធ្វើឡើងសម្រាប់មណ្ឌលចំនួន ២១ ដោយយកខេត្ត-ក្រុងធ្វើជាមណ្ឌល គឺមានខេត្តចំនួន១៩ និងក្រុងចំនួន ២ គឺក្រុងភ្នំពេញ និងក្រុងព្រះសីហនុ ដែលមានគណបក្សនយោបាយ ចំនួន ២០បានចុះឈ្មោះប្រកួតប្រជែង។ លទ្ធផលនៃការបោះឆ្នោតត្រូវបានប្រកាសជាផ្លូវការដោយUNTAC ដោយមានតែគណបក្សនយោបាយចំនួន ៤ ប៉ុណ្ណោះដែលជាប់អាសនៈ ជាសមាជិកសភាធម្មនុញ្ញទាំង ១២០រូប ក្នុងនោះរួមមាន គណបក្សហ៊្វុនស៊ិនប៉ិច ទទួលបាន ៥៨ អាសនៈ គណបក្សប្រជាជនកម្ពុជា ទទួលបាន ៥៣ អាសនៈ គណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា ទទួលបាន ១០ អាសនៈ និងគណបក្សម៉ូលីណាកា ទទួលបាន ១ អាសនៈ។ ក្រោយមកសភាធម្មនុញ្ញដែលជាប់ឆ្នោតបានដើរតួនាទីយ៉ាងសំខាន់ស្របតាមកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសដើម្បីបំពេញមុខងាររបស់ខ្លួនបន្តទៀត។

(២).គេហទំព័រ: សហភាពអន្តរសភា. http://www.ipu.org/parline-e/reports/arc/2051_93.htm ចូលមើលថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៧

ភ្លាមនោះរដ្ឋធម្មនុញ្ញមួយត្រូវបានអនុម័តនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ និងប្រកាសឲ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្របពេលជាមួយគ្នានោះសភាធម្មនុញ្ញ ក៏បានក្លាយជារដ្ឋសភាសម្រាប់នីតិកាលទី១ រយៈពេល៥ឆ្នាំ (១៩៩៣-១៩៩៨) ។

សភាធម្មនុញ្ញ ត្រូវបានបោះឆ្នោតនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៩៣ នៅទូទាំងប្រទេស ដើម្បីជ្រើសរើសសមាជិកសភាធម្មនុញ្ញក្នុងការតាក់តែងរដ្ឋធម្មនុញ្ញមួយ។ សមាជិកសភាធម្មនុញ្ញទាំងអស់មានចំនួន ១២០ រូប ដែលកើតចេញពីការបោះឆ្នោតជាសកល សម្ងាត់ ដោយស្មើភាព ដោយផ្ទាល់ និងដោយចំពោះ ក្រោមការរៀបចំរបស់អង្គការសហប្រជាជាតិ ។

សភាធម្មនុញ្ញមានកិច្ចប្រជុំរបស់ខ្លួនជាដំបូង នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៣ ក្រោមព្រះរាជធិបតីភាព **សម្តេចព្រះបាទ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ** ព្រះបិតាបង្រួបបង្រួមជាតិ ជាប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា(SNC)។ ក្រោមការដឹកនាំរបស់ **សម្តេចបវរសេដ្ឋា សឺន សាន** ជាប្រធានសភាធម្មនុញ្ញ **ឯកឧត្តម ជា ស៊ីម** ជាអនុប្រធានទី១ និង **ឯកឧត្តម អ៊ឹង គៀត** ជាអនុប្រធានទី២ សភាធម្មនុញ្ញបានចាប់ផ្តើម ដំណើការរបស់ខ្លួនយ៉ាងសកម្មដើម្បីរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។ បន្ទាប់មកគណៈកម្មាធិការអចិន្ត្រៃយ៍បានសម្រេចធ្វើសេចក្តីព្រាងរដ្ឋធម្មនុញ្ញថ្មីនៃព្រះរាជាណាចក្រកម្ពុជាមួយ ដែលរៀបចំធ្វើឡើងនាសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី១ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៣។ គួរបញ្ជាក់ផងដែរថាបទបញ្ជាផ្ទៃក្នុងនេះត្រូវចូលជាធរមានចាប់ពីពេលដែលសភាធម្មនុញ្ញបាន អនុម័ត បទបញ្ជាយល់ព្រមរួចហើយផងដែរ[៣]។ ត្រង់ជំពូក១ប្រការ១នៃបទបញ្ជាផ្ទៃក្នុងសភាធម្មនុញ្ញបានបញ្ជាក់ថា បទបញ្ជានេះមានសុពលភាពតែក្នុងសភាធម្មនុញ្ញប៉ុណ្ណោះ[៤]។ ត្រង់ជំពូក៧ បានចែងកំណត់អំពីការបង្កើតគណៈកម្មការដើម្បីធ្វើរបាយការណ៍ ឬបង្កើតឲ្យមានគណៈកម្មការដើម្បីធ្វើរបាយការណ៍ ឬសេចក្តីសង្ខេប ការងាររបស់សភាធម្មនុញ្ញ[៥]។ សភាធម្មនុញ្ញបានបង្កើតឲ្យមានគណៈកម្មាធិការអចិន្ត្រៃយ៍ពីរ គឺ គណៈកម្មាធិការព្រាងរដ្ឋធម្មនុញ្ញ និងគណៈកម្មាធិការបទបញ្ជាផ្ទៃក្នុង។ក្រោយកិច្ចពិភាក្សាយ៉ាងល្អិតល្អន់របស់សមាជិកសមាជិកា របស់សភាធម្មនុញ្ញអស់រយៈពេល ៦ថ្ងៃ គឺគិតចាប់ពីថ្ងៃទី ១៥ ដល់ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៩៣ មក សេចក្តីព្រាងរដ្ឋធម្មនុញ្ញនេះត្រូវបានអនុម័តដោយសមាជិកសមាជិកាសភាធម្មនុញ្ញ ដែលមានសម្លេងគាំទ្រលើសពី ២ភាគ៣ នៅថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ១៩៩៣ ហើយរដ្ឋធម្មនុញ្ញនេះត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ដោយ **ព្រះបាទ នរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ** ។ ក្រោយមកសភាធម្មនុញ្ញត្រូវបានប្រែក្លាយ

(៣),(៤),(៥) បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

ទៅជារដ្ឋសភានីតិកាលទី១ នៃព្រះរាជាណាចក្រកម្ពុជាទី២ ស្របតាមស្មារតីមាត្រា ១៥៥ថ្មី (មាត្រា ១៣៦ចាស់) នៃរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា និងអនុលោមតាមមាត្រា ១ និងមាត្រា១២ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ។

បន្ទាប់ពីការបោះឆ្នោតនៅឆ្នាំ១៩៩៨ សភាមួយថ្នាក់ទៀតត្រូវបានបង្កើតឡើង បើទោះបីមានព្រឹត្តិការណ៍ថ្ងៃទី៥-៦ ខែកក្កដា ឆ្នាំ១៩៩៧ បានកើតឡើងក៏ដោយ។ ស្ថាប័នព្រឹទ្ធសភា គឺជាផ្លែផ្កានៃការមូលមតិគ្នាខាងនយោបាយ សំដៅដោះស្រាយភាពជាប់គាំងខាងនយោបាយ ដែលអង្គនីតិប្រតិបត្តិមិនអាចបង្កើតបានដោយសារលក្ខខណ្ឌសំឡេងភាគច្រើនដាច់ខាត ២/៣ នៅក្នុងរដ្ឋសភា។ ចាប់តាំងពីឆ្នាំ២០០៦មកស្ទើរតែទាំងអស់នៃសមាជិកព្រឹទ្ធសភា ត្រូវបានជ្រើសតាំងដោយមិនផ្ទាល់ ដោយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ខណៈពេលដែលសមាជិក ៤រូប ត្រូវបានតែងតាំងដោយ ព្រះមហាក្សត្រ និងរដ្ឋសភា។

នៅឆ្នាំ២០០២ ការបោះឆ្នោតនៅរដ្ឋបាលក្រោមជាតិ ត្រូវបានធ្វើឡើងជាសកល និងដោយផ្ទាល់ សម្រាប់ឃុំ និងសង្កាត់។ ក្រោយពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបោះឆ្នោត ជ្រើសតាំងក្រុមប្រឹក្សាឃុំ សង្កាត់គ្រប់សមាជិកក្រុមប្រឹក្សាត្រូវបានបោះឆ្នោតជ្រើសតាំង ដោយផ្ទាល់ពីប្រជាពលរដ្ឋខ្មែរ ស្របតាមប្រព័ន្ធបោះឆ្នោតសមាមាត្រ។ ក្រុមប្រឹក្សាដែលកើតចេញពីការបោះឆ្នោតនេះនឹងគ្រប់គ្រងមូលនិធិនិងធន ធានផ្ទាល់ខ្លួន ព្រមទាំងដឹកនាំចាត់ចែងកិច្ចការក្នុងមូលដ្ឋានខ្លួនរាប់បញ្ចូលទាំងការអភិវឌ្ឍ និងសន្តិសុខ។

ប៉ុន្តែគេត្រូវរង់ចាំរហូតដល់ឆ្នាំ២០០៩ ទើបរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា ពង្រីកវិសាលភាពនៃកំណែទម្រង់រដ្ឋបាលរបស់ខ្លួន រហូតទៅដល់រដ្ឋបាលដែនដីថ្នាក់ខ្ពស់។ ជាលទ្ធផលនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ការបោះឆ្នោត ត្រូវបានរៀបចំ ឡើងសម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប៉ុន្តែជាការបោះឆ្នោតអសកល និង មិនផ្ទាល់។

រហូតមកទល់បច្ចុប្បន្ននេះ ការបោះឆ្នោតជាតិសម្រាប់រដ្ឋសភា ត្រូវបានរៀបចំឡើង ចំនួន ៥ ដងរួចមកហើយ គឺនៅឆ្នាំ១៩៩៣ ឆ្នាំ១៩៩៨ ឆ្នាំ២០០៣ ឆ្នាំ២០០៨ និងឆ្នាំ២០១៣។ ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ទើបតែត្រូវបានធ្វើឡើង ចំនួន ២លើកប៉ុណ្ណោះ គឺនៅឆ្នាំ២០០៦ និងឆ្នាំ២០០១២។ នៅថ្នាក់មូលដ្ឋាន ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានរៀបចំឡើងចំនួន ៣លើក គឺនៅឆ្នាំ២០០២ ឆ្នាំ២០០៧ និងឆ្នាំ២០១២ ខណៈក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទើបមានការបោះឆ្នោយជ្រើសរើស ចំនួន ២លើក គឺនៅឆ្នាំ២០០៩ និងឆ្នាំ២០១៤។ ចាប់តាំងពីការបោះឆ្នោតជាតិឆ្នាំ១៩៩៣មក ភាពជាប់គាំងខាងនយោបាយបានក្លាយទៅជាប្រពៃណី

ទៅហើយ នៅក្រោយការប្រកាសលទ្ធផលនៃការបោះឆ្នោត។ គណបក្សនយោបាយខ្លះមិនទទួលយកលទ្ធផលនៃការបោះឆ្នោតដោយអះអាងពីភាពមិនប្រក្រតីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប)។ គណបក្សឈ្នះឆ្នោត មិនអាចឈានទៅដល់ការបង្កើតរដ្ឋាភិបាលដោយខ្លួនឯង។ មានន័យថា ការបង្កើតរដ្ឋាភិបាលចំរុះ មិនអាចជៀសផុត ហើយជាវិបាក ការធ្វើសម្បទានខាងនយោបាយ គឺមិនអាចខ្វះបាន។

កំណែទម្រង់ជាច្រើន បានកើតមានឡើងនៅក្រោយការបោះឆ្នោតឆ្នាំ២០១៣ ជាពិសេសទាក់ទងនឹងសភា ច្បាប់បោះឆ្នោត និង គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ យោងទៅតាមកិច្ចព្រមព្រៀងនយោបាយ ថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១៤ រវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ គណៈកម្មាធិការជំនាញត្រូវបានតម្លើងពី ៩ គណៈកម្មាធិការ មក ១០ គណៈកម្មាធិការ ហើយគណបក្សនីមួយៗ ដឹកនាំម្នាក់ ៥ គណៈកម្មាធិការ។[៦] លើសពីនេះ ដោយសារមានគណបក្សតែពីរប៉ុណ្ណោះនៅក្នុងរដ្ឋសភា ការសន្ទនាគ្នាតែងត្រូវធ្វើឡើងរវាងមេដឹកនាំសំឡេងភាគច្រើន ជាមួយនឹងមេដឹកនាំសំឡេងភាគតិច ដើម្បីដោះស្រាយបញ្ហាជាតិសំខាន់ៗ។ ច្បាប់បោះឆ្នោតឆ្នាំ១៩៩៧ ត្រូវបានអនុវត្តរហូតមកដល់ការបោះឆ្នោតរដ្ឋសភានៅក្នុង ឆ្នាំ២០១៣។ ច្បាប់ថ្មីស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិករដ្ឋសភាត្រូវបានប្រកាស ឱ្យប្រើនៅឆ្នាំ២០១៥ ដើម្បីធ្វើវិសោធនកម្មច្បាប់ឆ្នាំ១៩៩៧។ បទប្បញ្ញត្តិគួរជាទីកត់សម្គាល់ដែលនាំយកមកដោយច្បាប់ថ្មីនេះ គឺ "ការសន្មត់ដោយសង្ងាត់ស្ងៀមពីការបោះបង់ចោលអាសនៈរដ្ឋសភា" ដោយការធ្វើពហិការរបស់គណបក្សនយោបាយ នៅក្នុងសម័យប្រជុំដំបូង សម័យប្រជុំលើកទី១ នៃរដ្ឋសភា និងសច្ចាប្រណិធានចូលកាន់តំណែង។[៧]

កំណែទម្រង់សំខាន់ចុងក្រោយមួយទៀត នៅក្រោយការបោះឆ្នោតឆ្នាំ២០១៣ គឺទាក់ទងនឹងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (NEC)។ ជាលទ្ធផលនៃកិច្ចព្រមព្រៀងនយោបាយរវាងគណបក្សប្រជាជនកម្ពុជានិងគណបក្សសង្គ្រោះជាតិ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបានស្តារឡើងវិញឱ្យក្លាយទៅជាស្ថាប័នមួយក្នុងចំណោមស្ថាប័នកំពូលរបស់ជាតិ ដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា ត្រង់ជំពូកទី១៥ថ្មី (ពីរ)។[៨] ការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបានកំណត់នៅក្នុងច្បាប់អង្គការមួយដោយឡែកចៀសជាងនៅក្នុងច្បាប់បោះឆ្នោត។[៩]

(៦). កិច្ចព្រមព្រៀងនយោបាយរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ថ្ងៃទី ២២ កក្កដា ២០១៤

(៧). ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ១៩៩៧

(៨),(៩). រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

ដើម្បីឈានដល់ការបកស្រាយប្រធានបទស្តីពី"កំណែទម្រង់ស្ថាប័នរៀបចំការបោះឆ្នោតក្នុងប្រទេសកម្ពុជា ឆ្នាំ២០១៥" យើងចាំបាច់ត្រូវសិក្សាលើចំនោទបញ្ហាមួយចំនួនដូចខាងក្រោមជាមុនសិន៖

- ក្រោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី២ តើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនបែបណាខ្លះ ក្នុងការរៀបចំឲ្យមានដំណើរការនៃការបោះឆ្នោតក្នុងអាណត្តិបន្តបន្ទាប់រហូតអាណត្តិចុងក្រោយ នៃស្ថាប័នមួយនេះ ?
- អ្វីខ្លះជាបញ្ហាចោទក្នុងដំណើរការរៀចំការបោះឆ្នោតក្នុងអាណត្តិនីមួយៗដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជួបប្រទះ ?
- កត្តាអ្វីខ្លះដែលឈានទៅដល់ការធ្វើកំណែទម្រង់ស្ថាប័នរៀបចំការបោះឆ្នោតនេះ ?
- តើកំណែទម្រង់ស្ថាប័នរៀបចំការបោះឆ្នោតថ្មីនេះ អាចផ្តល់ភាពជឿជាក់ដល់ភាគីពាក់ព័ន្ធ និងមតិសាធារណៈទូទៅលើដំណើរការរៀបចំការបោះឆ្នោតផ្សេងៗតាមការកំណត់នៃច្បាប់បានដែរឬទេ ?

សារណាដែលមានប្រធានបទ "កំណែទម្រង់ស្ថាប័នរៀបចំការបោះឆ្នោតនៅកម្ពុជា ឆ្នាំ២០១៥" មិនត្រឹមតែរំលេចឲ្យឃើញនូវដំណើរការជុំវិញការរៀបចំបោះឆ្នោតនៅកម្ពុជា កំណើតឡើងនៃស្ថាប័នជាតិរៀបចំការបោះឆ្នោត និងឈានរហូតដល់កំណែទម្រង់ស្ថាប័នជាតិរៀបចំការបោះឆ្នោតប៉ុណ្ណោះទេ តែការសិក្សាស្រាវជ្រាវលើសារណាបទនេះបានបង្ហាញពីឥទ្ធិពលសង្គមនៃអ្នកនយោបាយកម្ពុជាពាក់ព័ន្ធប្រក្រតីភាពនៃស្ថាប័នជាតិរៀបចំការបោះឆ្នោតនេះ។ យ៉ាងណាមិញ ឥទ្ធិពលរបស់ក្រុមអ្នកនយោបាយនេះហើយធ្វើឲ្យមានកំណែទម្រង់នេះកើតឡើង។ កាលណាស្ថាប័នជាតិរៀបចំការបោះឆ្នោតត្រូវបានអ្នកនយោបាយគ្រប់និន្នាការនិងមតិសាធារណៈទូទៅផ្តល់តម្លៃ និងទទួលស្គាល់ពីសុក្រឹតភាព ឯករាជ្យ យុត្តិធម៌ និងតម្លាភាពលើការរៀបចំការបោះឆ្នោតជាពិសេសការប្រកាសលទ្ធផលឆ្នោតហើយនោះការជាប់គាំងនយោបាយនិងការចោទដាក់គ្នាទៅវិញទៅមក ប្រាកដជាមិនកើតមានទៀតឡើយក្នុងឆន្ទៈនយោបាយ។ ពេលនោះដំណើរការនៃការអនុវត្តលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា នឹងមានភាពល្អប្រសើរប្រកបដោយប្រសិទ្ធិភាព ក្នុងការកសាងខឿនសេដ្ឋកិច្ចជាតិ និងនយោបាយ ។

ដើម្បីឆ្លើយតបទៅនិងចំនោទបញ្ហាខាងលើ និងយល់កាន់តែច្បាស់ពាក់ព័ន្ធប្រធានបទនៃសារណា ស្តីពី "កំណែទម្រង់ស្ថាប័នរៀបចំការបោះឆ្នោតនៅកម្ពុជា" យើងបានធ្វើការបែងចែកជាបីជំពូកសំខាន់ៗ ក្នុងនោះរួមមាន៖ (ជំពូក១) "ការកើតឡើងនៃស្ថាប័នជាតិរៀបចំការបោះឆ្នោត"

(ជំពូក២) "ការដាក់បញ្ចូលស្ថាប័នរៀបចំការបោះឆ្នោតទៅជាស្ថាប័នមានចែងក្នុងរដ្ឋធម្មនុញ្ញ" និង (ជំពូក៣) "ស្ថាប័នជាតិរៀបចំការបោះឆ្នោតថ្មី ក្រោយកំណែទម្រង់" ដូចតទៅ៖

# ជំពូកទី១
# ការកើតឡើងនៃស្ថាប័នជាតិរៀបចំការបោះឆ្នោត

# ជំពូកទី ១

# ការកើតឡើងនៃស្ថាប័នជាតិរៀបចំការបោះឆ្នោត

## ១. ស្ថាប័នរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅនីតិកាលនីមួយៗ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គឺជាស្ថាប័នជាតិ ទទួលបន្ទុកលើ ការរៀបចំ និងការប្រព្រឹត្តទៅនៃការបោះឆ្នោត។ ក្រោយពីមានការបោះឆ្នោតលើកទី១ ដែលរៀបចំដោយ អ៊ុនតាក់ ក្នុងការជ្រើសរើសសមាជិកសភាធម្មនុញ្ញក្រោយមកក្លាយជារដ្ឋសភា ដើម្បីអនុម័តរដ្ឋធម្មនុញ្ញនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ក្រោយមកប្រកាសឲ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ពេលនោះកម្ពុជាមានការបោះឆ្នោតមួយនៅក្នុងប្រទេសរបស់ខ្លួនសារជាថ្មី ក្នុងរបត់ប្រជាធិបតេយ្យ។ អាណត្តិទី១ នៃរដ្ឋសភាក្រោមការរៀបចំឡើងដោយអ៊ុនតាក់ កម្ពុជាបានសិក្សាពីការរៀបចំការបោះឆ្នោតដោយខ្លួនឯងសម្រាប់អាណត្តិបន្តបន្ទាប់។ ស្ថាប័នរៀបចំការបោះឆ្នោត(គ.ជ.ប) មួយបានចាប់ផ្តើមបង្កើតឡើងដើម្បីក្នុងគោលបំណងរៀបចំដំណើរការការបោះឆ្នោតនៅកម្ពុជា នាអាណត្តិបន្តបន្ទាប់។ គ.ជ.ប នៃអាណត្តិដំបូងក៏បានកើតឡើង។

### ១.១ ស្ថាប័នរៀបចំការបោះឆ្នោតឆ្នាំ១៩៩៨ នៃរដ្ឋសភានីតិកាលទី២

ការងាររៀបចំការបោះឆ្នោត គឺជាការៀបចំនិងអនុវត្តគម្រោងការងាររួមមានទាំងខាងច្បាប់ទម្លាប់ទាំងខាងបច្ចេកទេសតម្រូវតាមប្រតិទិនកំណត់មួយនិងមានការចូលរួមសហការគាំទ្រពីសង្គមជាតិទាំងមូលដូចជា រដ្ឋសភា រាជរដ្ឋាភិបាល គណបក្សនយោបាយ អង្គការសង្គមមិនមែនរដ្ឋាភិបាល ប្រជាពលរដ្ឋ និងសហគមន៍អន្តរជាតិដែលមានទាំងរដ្ឋាភិបាល ទាំងអង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ។

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ១៩៩៨ នៅព្រះរាជាណាចក្រកម្ពុជាមានអត្ថន័យជាប្រវត្តិសាស្ត្រដែលកម្ពុជាបានរៀបចំការបោះឆ្នោតជាលើកដំបូងតាមលទ្ធិប្រជាធិបតេយ្យដោយខ្លួនឯង ក្រោយសន្ធិសញ្ញាសន្តិភាពក្រុងប៉ារីសឆ្នាំ ១៩៩១ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ សំដៅដោះស្រាយបញ្ហានយោបាយដែលកើតមានឡើង ដោយសន្តិវិធីទៅតាមឆន្ទៈ និងការសម្រេចរបស់ប្រជាពលរដ្ឋដែលជាម្ចាស់ប្រទេសម្ចាស់អំណាច។ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតពុំទាន់ត្រូវបានបង្កើតឡើង នៅចុងឆ្នាំ១៩៩៥ រាជរដ្ឋាភិបាលបានប្រគល់ភារកិច្ចឱ្យក្រសួងមហាផ្ទៃ បង្កើតការិយាល័យកណ្តាលបោះឆ្នោតដើម្បីធ្វើការសិក្សាស្រាវជ្រាវ និងតាក់តែងគម្រោងនៃការងាររៀបចំបោះឆ្នោត ហើយដែលលទ្ធផលនៃការត្រៀមរៀបចំបច្ចេកទេស

ជាមុននេះ បានក្លាយជាចំណែកសំខាន់ចាំបាច់មួយដល់កិច្ចដំណើរការរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

### គ.សមាសភាពសមាជិក គ.ជ.ប

គ.ជ.ប ឆ្នាំ១៩៩៨-២០០២ មានសមាសភាពចំនួន ១១រូប តំណាងឲ្យគណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភា តំណាងឲ្យក្រសួងមហាផ្ទៃ តំណាងប្រជាពលរដ្ឋ និងតំណាងអង្គការសង្គមមិនមែនរដ្ឋាភិបាល។ សមាសភាពទាំងនោះត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៩៨ ដោយប្រមុខរដ្ឋស្តីទី សម្តេច ជា ស៊ីម មានដូចជា៖

| | |
|---|---|
| ១. ឯកឧត្តម ឆេង ផុន | ប្រធាន |
| ២. ឯកឧត្តម នៅ កាស៊ី | អនុប្រធាន |
| ៣. ឯកឧត្តម ជូ កុងងួន | សមាជិក |
| ៤. ឯកឧត្តម យូ កន | សមាជិក |
| ៥. ឯកឧត្តម ទា ចំរ៉ាត់ | សមាជិក |
| ៦. ឯកឧត្តម ព្រហ្ម ញាណវិចិត្រ | សមាជិក |
| ៧. ឯកឧត្តម កែវ ឡុងឌី | សមាជិក |
| ៨. ឯកឧត្តម វ៉េង គឹមអេង | សមាជិក |
| ៩. ឯកឧត្តម ឆាយ គឹម | សមាជិក |
| ១០. ឯកឧត្តម ទិប ចន្ទវិបុល | សមាជិក |
| ១១. ឯកឧត្តម ជា ចំរើន | សមាជិក |

### ខ.ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី២

នៅខែឧសភា ឆ្នាំ១៩៩៧ រាជរដ្ឋាភិបាលបានសម្រេចនឹងធ្វើការបោះឆ្នោតនៅឆ្នាំ១៩៩៨។[១០] នៅថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៩៨ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលមានសមាជិក ១១រូប ត្រូវបានរដ្ឋសភាអនុម័តយល់ព្រម ហើយត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៨/០៤២។

(១០). គ.ជ.ប របាយការណ៍ស្តីពី ការបូកសរុបវាយតម្លៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី២ សម័យបោះឆ្នោតថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ ទំព័រ ១

នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៩៨ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានរៀបចំចាប់ផ្តើមដំណើរការការងាររបស់ខ្លួន។ រដ្ឋសភា រាជរដ្ឋាភិបាល គណបក្សនយោបាយ ក៏ដូចជាប្រជាជនកម្ពុជាគាំទ្រឱ្យមានការបោះឆ្នោត។ បណ្តាប្រទេសជាមិត្តកម្ពុជាបានយកចិត្តទុកដាក់ដល់ការដោះស្រាយវិបត្តិនយោបាយនៅកម្ពុជា និងលើកទឹកចិត្តដល់ការរៀបចំការបោះឆ្នោត។[១១]

ការបោះឆ្នោតគឺជាដំណាក់ការខ្ពស់បំផុតនៃដំណើរការបោះឆ្នោត។ ការបោះឆ្នោតបានប្រព្រឹត្តទៅនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ ចាប់ពីម៉ោង ៧ព្រឹក រហូតដល់ម៉ោង ១៥ រសៀល។ នៅពេលបោះឆ្នោត ការិយាល័យចុះឈ្មោះបោះឆ្នោតទាំង ១១.៣៩១ បានក្លាយទៅជាការិយាល័យបោះឆ្នោត។ តាមបញ្ជីបោះឆ្នោតនៅទូទាំងប្រទេសមានអ្នកទៅបោះឆ្នោតចំនួន ៥.០៥៧.៨៣០នាក់ ស្មើនិង ៩៣,៧៤% នៃចំនួនអ្នកចុះឈ្មោះបោះឆ្នោត។[១២]

នៅថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៨ ក្រោយពីការត្រួតពិនិត្យផ្ទៀងផ្ទាត់កំណត់បានប្រកាសសរុបលទ្ធផលបោះឆ្នោតតាមខេត្ត ក្រុងនីមួយៗ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានប្រកាសលទ្ធផលបឋមនៃការបោះឆ្នោតថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ១៩៩៨ តាមខេត្ត ក្រុងនីមួយៗ និងសរុបទូទាំងប្រទេស។លទ្ធផលនេះបានបង្ហាញឱ្យឃើញសន្លឹកឆ្នោតបានការទូទាំងប្រទេសមានចំនួន ៤.៩០២.៤៨៨ សន្លឹក មានគណបក្ស ៣ នាំមុខគឺគណបក្សប្រជាជនកម្ពុជាបាន ២.០៣០.៨០២សំឡេង គណបក្សហ៊្វុនស៊ិនប៉ិចបាន ១.៥៥៤.៣៧៤សំឡេង គណបក្សសម រង្ស៊ី បាន ៦៩៩.៦៥៣សំឡេង។ សន្លឹកឆ្នោតមិនបានការមាន ១៥ ៥.១៦៩ សន្លឹក ស្មើនឹង ៣,១% និងសន្លឹកឆ្នោតខូចមាន១៩.៥៣៨ សន្លឹក ស្មើនឹង ០,៤%។ សរុបទាំង ៣ គណបក្សមានបេក្ខជនជាប់ឆ្នោតទាំងអស់ ១២២នាក់ ក្នុងនោះប្រុសមាន១១២នាក់ ស្មើនឹង៩១,៨% និងស្រីមាន ១០នាក់ ស្មើនឹង ៨,១៩%។[១៣]នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ១៩៩៨ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានចេញសេចក្តីសម្រេច ស្តីពីការប្រកាសឈ្មោះបេក្ខជនតំណាងរាស្ត្រដែលត្រូវបានជាប់ឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រសម័យបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨។[១៤]

(១១). គ.ជ.ប របាយការណ៍ស្តីពី ការបូកសរុបវាយតម្លៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី២ សម័យបោះឆ្នោតថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ ទំព័រ ៤៧)

(១២). ឧបសម្ព័ន្ធទី IX ទំព័រទី៨១ នៃរបាយការណ៍ស្តីពី ការបូកសរុបវាយតម្លៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី២ សម័យបោះឆ្នោត ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨

(១៣). របាយការណ៍ស្តីពី ការបូកសរុបវាយតម្លៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី២ សម័យបោះឆ្នោតថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ ទំព័រ ៥៣ និង៥៦

(១៤). ឧបសម្ព័ន្ធទី XII ទំព័រ៨៤ នៃរបាយការណ៍ស្តីពី ការបូកសរុបវាយតម្លៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី២ សម័យបោះឆ្នោតថ្ងៃទី២៦ កក្កដា ឆ្នាំ១៩៩៨

## ១.២ ស្ថាប័នរៀបចំការបោះឆ្នោតឆ្នាំ២០០៣ នៃរដ្ឋសភានីតិកាលទី៣

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៣ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៣ គឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដែលប្រជាជាតិកម្ពុជាបានរៀបចំការបោះឆ្នោតតាមកាលកំណត់ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលជាការបង្ហាញឱ្យឃើញនូវភាពរីចម្រើននៃយន្តការប្រជាធិបតេយ្យូបនីយកម្ម និងដែលលើកកម្ពស់កិត្យានុភាពប្រទេសកម្ពុជាលើឆាកអន្តរជាតិ។

ច្បាប់ស្តីពីការវិសោធនកម្មច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលត្រូវបានប្រកាសឱ្យប្រើឆ្នាំ២០០២ បានកំណត់ការកែទម្រង់សមាសភាពនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ព្រមទាំងបទប្បញ្ញត្តិ និងនីតិវិធីនៃការបោះឆ្នោតមួយចំនួនទៀត និងការប្រគល់ភារកិច្ចដល់ គ.ជ.ប ដើម្បីរៀបចំ និងគ្រប់គ្រងការបោះឆ្នោត។[១៥]

### ក.សមាសភាពសមាជិក គ.ជ.ប

ចាប់ពីឆ្នាំ ២០០២-២០០៦ គ.ជ.ប មានសមាជិក សមាជិកា ប្រាំ (៥) រូប ដែលរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៣ឆ្នាំ២០០៣និងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានិតីកាលទី២ ឆ្នាំ២០០៦។ សមាសភាព សមាជិក សមាជិកា របស់ គ.ជ.ប ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០២ រួមមានៈ

| | |
|---|---|
| ១.ឯកឧត្តម អ៊ឹម សូស្ដី | ប្រធាន |
| ២. ឯកឧត្តម ង៉ែ ឆាយលាង | អនុប្រធាន |
| ៣. ឯកឧត្តម មាន សទិ | សមាជិក |
| ៤. លោកជំទាវ កុយ វ៉េត | សមាជិកា |
| ៥. លោកជំទាវ ស៊ីន ជុំបូ | សមាជិកា |

### ខ. ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៣

ការិយាល័យបោះឆ្នោតសរុបមានចំនួន ១២.៨២៦ការិយាល័យ ដែលក្នុងនោះមានភ្លោះចំនួន ៨ ការិយាល័យផង។ បញ្ជីទីតាំងការិយាល័យបោះឆ្នោតទាំងអស់ ដែលរួមទាំងការិយាល័យបង្កើតថ្មី ការិយាល័យដែលត្រូវកែសម្រួលត្រូវបាន គ.ជ.ប បិទផ្សាយនិងជូនដំណឹងដល់អ្នកបោះឆ្នោតយ៉ាង

(១៥). គ.ជ.ប សន្និបាតបូកសរុបការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៣ ឆ្នាំ២០០៣ ទំព័រ ៣

ទូលំទូលាយ តាមរយៈគណៈកម្មាការឃុំ សង្កាត់ រៀបចំការបោះឆ្នោតចាប់ពីថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០០៣។[១៦]

នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៣ ចាប់ពីម៉ោង៧ ព្រឹក រហូតដល់ម៉ោង៣ រសៀល ការិយាល័យបោះឆ្នោតទាំងអស់ក្នុងទូទាំងប្រទេស បានបើកដំណើរការបោះឆ្នោតយ៉ាងអធឹកអធម។ ជាទូទៅដំណើរការបោះឆ្នោតនៅគ្រប់ការិយាល័យទាំងអស់បានប្រព្រឹត្តទៅប្រកបដោយបរិយាកាសល្អ ត្រឹមត្រូវ រលូន តម្លាភាព និងគ្មានការគម្រាមកំហែង។ ជាលទ្ធផលប្រជាពលរដ្ឋអ្នកបោះឆ្នោតចំនួន ៥.២៧៧.៤៩៤នាក់ ត្រូវជា៨៣.២២% នៃអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចំនួន ៦.៣៤១.៨៣៤នាក់ បានបោះឆ្នោតសម្តែងឆន្ទៈដោយសេរីក្នុងការជ្រើសរើសតំណាងរបស់ខ្លួនសម្រាប់រដ្ឋសភានីតិកាលទី៣។[១៧]

លទ្ធផលបង្ហាញឱ្យឃើញថា សន្លឹកឆ្នោតបានការទូទាំងប្រទេសមានចំនួន ៥.១៦៨.៨៣៧ សន្លឹក ដោយមានគណបក្សបីនាំមុខគឺ គណបក្សប្រជាជនកម្ពុជាបាន ២.៤៤៥.២៥៩ សំឡេង ស្មើនឹង ៤៧,៣៥%។ គណបក្ស សម រង្ស៊ី បាន ១.១៣០.៤២៣សំឡេង ស្មើនឹង២១,៨៧%។ គណបក្សហ្វ៊ុនស៊ិនប៉ិចបាន ១.០៧២.៣១៣ សំឡេងស្មើនឹង២០,៧៥% ។ សន្លឹកឆ្នោតមិនបានការមាន ១០៨.៦៥៧ សន្លឹក ស្មើនឹង២,០៦%។[១៨]សរុបទាំង ៣ គណបក្សមានបេក្ខជនជាប់ឆ្នោតទាំងអស់១២៣នាក់ ក្នុងនោះប្រុសមាន ១១១នាក់ ស្មើនឹង ៩០,២៤% និងស្រីមាន ១២នាក់ ស្មើនឹង៩,៧៦%។[១៩]

## ១.៣ ស្ថាប័នរៀបចំការបោះឆ្នោតឆ្នាំ២០០៨ នៃរដ្ឋសភានីតិកាលទី៤

ក្រោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី១ ឆ្នាំ១៩៩៣ ដែលរៀបចំដោយអាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិនៅកម្ពុជា "UNTAC" ប្រទេសកម្ពុជាបានរៀបចំការបោះឆ្នោតដោយខ្លួនឯងចំនួន ៦លើក ដែលជាការបោះឆ្នោតសកល ឬអសកល ដើម្បីជ្រើសរើសតំណាងថ្នាក់ជាតិ ឬមូលដ្ឋាន។ ជាបន្តបន្ទាប់ ដែលបង្ហាញពីការរីកចម្រើនឡើងជាលំដាប់នៃលទ្ធិប្រជាធិតេយ្យនៅកម្ពុជា និងសមត្ថភាពនៃការរៀបចំ និងគ្រប់គ្រងការបោះឆ្នោត។ ក្រោយពីបានបញ្ចប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់លើកទី២ភ្លាម ចាប់ពីខែមិថុនា ឆ្នាំ២០០៧ គ.ជ.បបានត្រៀមរៀបចំសម្រាប់ការបោះឆ្នោតជ្រើសតំណាងរាស្ត្រអាណត្តិទី៤។[២០]

(១៦). គ.ជ.ប សន្និបាតបូកសរុបការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៣ ឆ្នាំ២០០៣ ទំព័រ ២៥

(១៧). ឧបសម្ព័ន្ធទីVI ទំព័រទី១២៧ គ.ជ.ប សន្និបាតបូកសរុបការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៣ ឆ្នាំ២០០៣

(១៨). គ.ជ.ប សន្និបាតបូកសរុបការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៣ ឆ្នាំ២០០៣ ទំព័រ២៩

(១៩). ឧបសម្ព័ន្ធទីVII ទំព័រទី១២៨ គ.ជ.ប សន្និបាតបូកសរុបការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៣ ឆ្នាំ២០០៣

(២០). គ.ជ.ប របាយការណ៍ស្តីពី ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី ៤ ឆ្នាំ២០០៨ ទំព័រ ១

### ក.សមាសភាពសមាជិក គ.ជ.ប

ចាប់ពីឆ្នាំ ២០០៦ ដល់ ២០១៥ គ.ជ.ប មានសមាជិក សមាជិកា ប្រាំបួន(៩) រូប ដែលរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី២ ឆ្នាំ២០០៧ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៤ ឆ្នាំ២០០៨ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី១ ឆ្នាំ២០០៩ ការបោះឆ្នោតឡើងវិញជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ ឆ្នាំ២០១១ ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានិតីកាលទី៣ ឆ្នាំ២០១២ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ឆ្នាំ២០១៣។ សមាសភាព សមាជិក សមាជិកា របស់ គ.ជ.ប ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៦ រួមមានៈ

| | |
|---|---|
| ១.ឯកឧត្តម អ៊ឹម សូស្ដី | ប្រធាន |
| ២.លោកជំទាវ ស៊ីន ជុំបូ | អនុប្រធាន |
| ៣. លោកជំទាវ កុយ វ៉េត | សមាជិកា |
| ៤. ឯកឧត្តម ឃ្លោក ប៊ុតឌី | សមាជិក |
| ៥. ឯកឧត្តម ហារ៉ាំណ ស៊ីរិល័យ | សមាជិក |
| ៦. ឯកឧត្តម មាន សទិ | សមាជិក |
| ៧. ឯកឧត្តម ឯម សូផាត | សមាជិក |
| ៨. ឯកឧត្តម សោម ច័ន្ទឌីណា | សមាជិក |
| ៩. ឯកឧត្តម ម៉ៅ សុភារិទ្ធ | សមាជិក |

### ខ. ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៤

កាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៤ ត្រូវបានកំណត់ធ្វើនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៨ ក្នុងសភាពការណ៍ដែលប្រទេសជាតិស្ថិតនៅក្នុងសន្តិភាព ស្ថេរភាពនយោបាយ និងសេដ្ឋកិច្ចមានការរីកចម្រើនល្អ។ តាមបញ្ជីបោះឆ្នោតផ្លូវការប្រចាំឆ្នាំ ២០០៧ មានអ្នកបោះឆ្នោតចំនួន ៥.១២៥.៥២៩ នាក់ និងមានការិយាល័យបោះឆ្នោតចំនួន១៥.២៥៥ ក្នុងនោះមានការិយាល័យភ្លោះចំនួន ៣៥៥ការិយាល័យ។[២១]

(២១). គ.ជ.ប របាយការណ៍ស្តីពី ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី ៤ ឆ្នាំ២០០៨ ទំព័រ ១

ការបោះឆ្នោតត្រូវធ្វើតែមួយថ្ងៃ គឺចាប់ផ្ដើមពីម៉ោង ៧ព្រឹក រហូតដល់ម៉ោង ៣រសៀល នៃថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០៨។ ការិយាល័យបោះឆ្នោតទាំងអស់បានបើកដំណើរការនៅទូទាំងប្រទេស។ នៅតាមការិយាល័យបោះឆ្នោតនីមួយៗមានវត្តមាន តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងអ្នកសារព័ត៌មាន ចូលរួមសង្កេតមើលជាក់ស្ដែងអំពីដំណើរបោះឆ្នោតទាំងមូល។ ជារួមដំណើរការបោះឆ្នោតបានប្រព្រឹត្តទៅល្អ ស្ងប់ស្ងាត់ និងគ្មានអំពើហិង្សាណាមួយគួរឱ្យកត់សម្គាល់ឡើយ។ ប្រជាពលរដ្ឋចំនួន ៦.១១០.៨២៨នាក់ ស្មើនឹង ៧៥,២១% នៃអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចំនួន ៨.១២៥.៥២៩នាក់ បានអញ្ជើញទៅបោះឆ្នោត។[២២]

លទ្ធផលផ្លូវការ និងសេចក្ដីប្រកាសបេក្ខជនជាប់ឆ្នោតនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៤ បានបង្ហាញថា សន្លឹកឆ្នោតបានការនៅទូទាំង ២៤ មណ្ឌលខេត្ត ក្រុង មានចំនួន ៦.០១០.២៧៧ សន្លឹក ដែលក្នុងនោះមានគណបក្សចំនួន ៥ នាំមុខគេ ក្នុងចំណោមគណបក្សនយោបាយចំនួន ១១ ដែលបានចូលរួមប្រកួតប្រជែង។ គណបក្សនាំមុខគេទាំង៥ នោះមាន៖ គណបក្សប្រជាជនកម្ពុជា បានទទួល ៣.៤៩២.៣៧៤ សំឡេង ស្មើនឹង ៥៨,១១%។ គណបក្ស សម រង្ស៊ី បានទទួល ១.៣១៦.៧១៤ សំឡេង ស្មើនឹង ២១,៩១% ។ គណបក្សសិទ្ធិមនុស្សបានទទួល ៣៩៧.៨១៦ សំឡេង ស្មើនឹង ៦,៦២%។ គណបក្ស នរោត្តម រណឫទ្ធិ បានទទួល ៣៣៧.៩៤៣សំឡេង ស្មើនឹង ៥,៦៣%។ គណបក្ស ហ៊្វុន ស៊ិនប៉ិច បានទទួល ៣០៣.៧៦៤ សំឡេង ស្មើនឹង ៥.០៦% ។ ក្នុងចំណោមតំណាងរាស្ត្រអាណត្តិទី៤ទាំង ១២៣រូប ដែលបានជាប់ឆ្នោត មានសមាជិកជាស្ត្រីចំនួន ២០រូប ស្មើនឹង ១៦,២៦% ។[២៣]

## ១.៤ ស្ថាប័នរៀបចំការបោះឆ្នោតឆ្នាំ២០១៣ នៃរដ្ឋសភានីតិកាលទី៥

### ក.សមាសភាពសមាជិក គ.ជ.ប

សមាជិកគ.ជ.ប ត្រូវបានបោះឆ្នោតជ្រើសតាំងដោយរដ្ឋសភា និងត្រូវបានតែងតាំងដោយព្រះមហាក្សត្រតាមរយៈព្រះរាជក្រឹត្យចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០១២ ។ ក្រសួងមហាផ្ទៃត្រូវបានស្នើភាពនេះដោយផ្អែកលើអព្យាក្រឹតភាព និងវិជ្ជាជីវៈ ដូចមានចែងនៅក្នុង ច.ប.ត.រ។ បញ្ជីតែងតាំងត្រូវទទួលការយល់ព្រមដំបូងពីគណៈរដ្ឋមន្ត្រី មុននឹងបញ្ជូនទៅរដ្ឋសភា។ គ.ជ.ប រួមមានប្រធានមួយរូប អនុប្រធានមួយរូប និងអ្នកផ្សេងទៀតជាសមាជិក។ គ.ជ.ប មានសមាសភាព ៩ រូប ដែល ៥ រូប

(២២). គ.ជ.ប របាយការណ៍ស្ដីពី ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី ៤ ឆ្នាំ២០០៨ ទំព័រ ៤២និង ៤៣

(២៣). ឧបសម្ព័ន្ធXI ទំព័រទី ៩៩ គ.ជ.ប របាយការណ៍ស្ដីពី ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី ៤ ឆ្នាំ ២០០៨

ធ្លាប់បម្រើការងារជាចៅក្រម ឬមេធាវី ។ សមាសភាព សមាជិក សមាជិកា គ.ជ.ប រួមមាន៖

| | |
|---|---|
| ១. ឯកឧត្តម អ៊ឹម សូស្ដី | ប្រធាន |
| ២.លោកជំទាវបណ្ឌិត ស៊ីន ជុំបូ | អនុប្រធាន |
| ៣. ឯកឧត្តម ហាវ៉ាណ ស៊ីរិល័យ | សមាជិក |
| ៤. ឯកឧត្តម មាន សទិ | សមាជិក |
| ៥. ឯកឧត្តម ឯម សូផាត | សមាជិក |
| ៦. ឯកឧត្តម សោម ច័ន្ទឌីណា | សមាជិក |
| ៧. ឯកឧត្តម ម៉ៅ សុភារិទ្ធ | សមាជិក |
| ៨. ឯកឧត្តម ស៊ិន ឌឹម | សមាជិក |
| ៩. ឯកឧត្តម សោ សុភរី | សមាជិក |

ក្នុងនាមជាស្ថាប័នគ្រប់គ្រងការបោះឆ្នោតទទួលបន្ទុករៀបចំការបោះឆ្នោត ដោយសេរី និងយុត្តិធម៌ គ.ជ.ប ត្រូវគោរពតាមរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងបទបញ្ជា និងនីតិវិធី ។ គ.ជ.ប ត្រូវបំពេញភារកិច្ចរបស់ខ្លួនក្នុងស្មារតីឯករាជ្យ អព្យាក្រឹត សុចរិត តម្លាភាព ប្រសិទ្ធភាព ប្រកបដោយវិជ្ជាជីវៈ និងយកចិត្តទុកដាក់ខ្ពស់ ចំពោះការផ្តល់សេវាកម្ម។

## ខ. ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥

ការបោះឆ្នោតសកលសម្រាប់នីតិកាលទី៥ នៃរដ្ឋសភាកម្ពុជាត្រូវបានរៀបចំឡើងនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ នៅតាមការិយាល័យបោះឆ្នោតចំនួន ១៩,០០៩ នៅទូទាំងប្រទេស។ ការបោះឆ្នោតនៅឆ្នាំ២០១៣នេះ ដំបូងឡើយ គ.ជ.ប បានទទួលស្គាល់តំណាងគណបក្សនយោបាយចំនួន ៩៩,៨៨១ រូប ដែលមកពីគណបក្សនយោបាយផ្សេងៗ រួមមានគណបក្សប្រជាជនកម្ពុជា (តំណាងចំនួន ១៩,០០៩ រូប និងតំណាងបម្រុងចំនួនចំនួន១៩,០១៣រូប)គណបក្សសង្គ្រោះជាតិ(តំណាងចំនួន ១៨,០១២ និងតំណាងបម្រុងចំនួន ១៧,៥១៤ រូប)។ គ.ជ.ប ក៏បានទទួលស្គាល់ផងដែរនូវអ្នកសង្កេតការណ៍ចំនួន ៩,៩៣១ រូប មកពីគណបក្សសមរង្ស៊ី និងអ្នកសង្កេតការណ៍ចំនួន ៨,៧៨០ រូប មកពីគណបក្សសិទ្ធិមនុស្ស ដែលបន្ថែមទៅលើចំនួនអ្នកសង្កេតការណ៍បោះឆ្នោតជាតិ ដែលទទួលស្គាល់រួចហើយ ចំនួន ៨០,១៨២ រូប មកពីអង្គការ និងសមាគមចំនួន ៣៥ រួមមាន អង្គការមិនមែនរដ្ឋាភិបាលទទួលបន្ទុកតាមដានការបោះឆ្នោត ដូចជា COMFREL ដែលបានដាក់អ្នកសង្កេតការណ៍នៅតាមការិយាល័យបោះឆ្នោតនីមួយៗ។

គ.ជ.ប បានទទួលស្គាល់ផងដែរនូវអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិចំនួន ២៩២ រូប មកពីអង្គការអន្តរជាតិចំនួន ៣៥ និងមកពីស្ថានទូត និងប្រទេសនានា។ ក្នុងចំណោមអ្នកសង្កេតការណ៍អន្តរជាតិ មានឥស្សរជនជាន់ខ្ពស់មួយចំនួនដូចជា អតីតប្រធានរដ្ឋសភា៥អាណត្តិ របស់ហ្វីលីពីនអតីតអនុប្រធានាធិបតីឥណ្ឌូនេស៊ី អតីតឧបនាយករដ្ឋមន្ត្រីកាណាដា អតីតឧបនាយករដ្ឋមន្ត្រីសាធារណៈរដ្ឋកូរ៉េ សមាជិកព្រឹទ្ធសភាប៉ាគីស្ថាន ប្រធានគណៈកម្មការរៀបចំការបោះឆ្នោតរបស់ហ្វីលីពីន ថៃ និងមីយ៉ាន់ម៉ា និងសមាជិកគណៈកម្មការរៀបចំការបោះឆ្នោតម៉ាឡេស៊ី ឡាវ និងរុស្ស៊ី និងប្រធានលេខាធិការដ្ឋានអាស៊ានទទួលបន្ទុកអភិវឌ្ឍកិច្ចការសហគមន៍។

ការបោះឆ្នោតត្រូវបានធ្វើឡើងដើម្បីជ្រើសតាំងតំណាងរាស្ត្រចំនួន ១២៣ រូប តំណាងឲ្យ២៤ រាជធានីខេត្តនៅការិយាល័យបោះឆ្នោតចំនួន១៩,០០៩ដោយមានមន្ត្រីរៀបចំការបោះឆ្នោតសរុបចំនួន ១១៩,០៥៤ រូប ។ លទ្ធលផលបោះឆ្នោតបឋម ដែលផ្តល់ដោយ គ.ជ.ប និងបានផ្សព្វផ្សាយតាមរយៈទូរទស្សន៍ជាតិកម្ពុជានៅល្ងាចថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោតបានឲ្យដឹងអំពីចំនួនសន្លឹកឆ្នោតសរុបដែលបានបោះនៅតាមឃុំនីមួយៗ ។ លទ្ធផលបណ្តោះអាសន្នដែលប្រកាសដោយ គ.ជ.ប នៅថ្ងៃទី១២ ខែសីហា បានឲ្យដឹងអំពីចំនួនសន្លឹកឆ្នោតដែលទទួលបានដោយគណបក្សនីមួយៗ ដែលក្នុងនោះគណបក្សប្រជាជនកម្ពុជា ទទួលបាន ៣,២៣៥,៩៦៩សំឡេង និងគណបក្សសង្គ្រោះជាតិទទួលបាន ២,៩៤៦,១៧៦សំឡេង។

គណបក្សប្រជាជនកម្ពុជាបានប្រកាសអំពីការគណនាលទ្ធផលរបស់ខ្លួន ដោយគណបក្សប្រជាជនកម្ពុជាទទួលបាន៦៨ អាសនៈ ហើយគណបក្សសង្គ្រោះជាតិទទួលបាន ៥៥ អាសនៈ ដែលស្រដៀងគ្នាទៅនឹងការប្រកាសរបស់អង្គការ COMFREL (គណបក្សប្រជាជនកម្ពុជា ៦៧ អាសនៈនិងគណបក្សសង្គ្រោះជាតិ ៥៦ អាសនៈ)។ ផ្ទុយទៅវិញ គណបក្សសង្គ្រោះជាតិបានប្រកាសថា ខ្លួនទទួលបាន ៦៣អាសនៈ ហើយគណបក្សប្រជាជនកម្ពុជាទទួលបាន៦០ អាសនៈ ។ ប្រសិនបើការអះអាងនេះ ផ្អែកទៅលើទម្រង់បែបបទដើម ដែលផ្តល់ជូនដោយប្រធានការិយល័យបោះឆ្នោតនីមួយៗ ហើយដែលតំណាងគណបក្សប្រជាជនកម្ពុជានិងតំណាងគណបក្សសង្គ្រោះជាតិក៏ដូចជាអ្នកសង្កេតការណ៍របស់អង្គការ COMFREL ទទួលបានពីការិយាល័យបោះឆ្នោតនីមួយៗ នោះលទ្ធផលបឋមនឹងមិនមានភាពខុសគ្នានោះទេ។[២៩]

(២៩).សៀវភៅ ស ស្តីពីការបោះឆ្នោតសកលជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៣

## ២. ការបោះឆ្នោតផ្សេងៗទៀតដែលត្រូវរៀបចំដោយ គ.ជ.ប ពីនីតិកាលទី២ ដល់នីតិកាលទី៥ នៃរដ្ឋសភា

### ២.១. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ - សង្កាត់

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៥ ដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ១៥៨/00៦/២០១៥ កបធ.ច ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥ ។

ច្បាប់នេះមានគោលដៅកំណត់បែបបទនិងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។ ច្បាប់នេះត្រូវអនុវត្តន៍ចំពោះឃុំ សង្កាត់ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។[២៥] ឃុំ សង្កាត់ នីមួយៗត្រូវមានក្រុមប្រឹក្សាមួយ ដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួនតាមការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ ស្របតាមនីតិវិធីដូចមានចែងក្នុងច្បាប់នេះ។[២៦]

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ត្រូវធ្វើឡើងរៀងរាល់៥(ប្រាំ)ឆ្នាំម្តង។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំធ្វើឡើងនៅថ្ងៃជាមួយគ្នា។ កាលបរិច្ឆេទនៃការបោះឆ្នោតត្រូវកំណត់ដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ នាយករដ្ឋមន្ត្រីត្រូវប្រកាសកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងរយៈពេលយ៉ាងតិច ០៩ (ប្រាំបួន)ខែ យ៉ាងតិចមុនថ្ងៃបោះឆ្នោត។ ការបោះឆ្នោតត្រូវធ្វើអាទិត្យ តែមួយថ្ងៃ។[២៧]ជ្រើសរើសឡើងចូលកាន់តំណែងជំនួស។[២៨] ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបោះឆ្នោតជ្រើសរើសទៅតាមប្រព័ន្ធសមាមាត្រ ដោយអ្នកបោះឆ្នោតដែល ៖

- ការចុះឈ្មោះនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត នៅក្នុងឃុំ សង្កាត់នោះ
- មានសិទ្ធិបោះឆ្នោតតែមួយសន្លឹកប៉ុណ្ណោះ តាមរយៈការបោះឆ្នោតជាសម្ងាត់
- អ្នកបោះឆ្នោតម្នាក់ៗមានសិទ្ធិបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់តែមួយប៉ុណ្ណោះ។[២៩]

(២៥). ម១ (២៦). (១៣).ម ២ (២៧). ម៣ នៃច្បាប់ស្តីពីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១៥

(២៨).ម៤ (២៩).ម៥ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១៥

## ក. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ឆ្នាំ២០០២

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០០២ គឺជាការប្តេជ្ញាចិត្តប្រកបដោយសុឆន្ទៈរបស់រាជរដ្ឋាភិបាលអាណត្តិទី២ដើម្បីអនុវត្តនយោបាយវិមជ្ឈការជាលើកដំបូងក្នុងការផ្តល់អំណាចពីថ្នាក់កណ្តាលទៅឱ្យប្រជាពលរដ្ឋនៅមូលដ្ឋាន សំដៅលើកស្ទួយលទ្ធិប្រជាធិបតេយ្យពង្រឹកអភិបាលកិច្ចល្អ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលត្រូវបានរដ្ឋសភាអនុម័ត និងបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ បានប្រគល់ឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នូវសមត្ថកិច្ចចាត់ចែងរៀបចំ និងគ្រប់គ្រងបញ្ជីឈ្មោះអ្នកបោះឆ្នោត និងគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

ចាប់តាំងពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០០១ ក្រោយពីរាជរដ្ឋាភិបាលបានប្រកាសកាលបរិច្ឆេទនៃការបោះឆ្នោត ដោយកំណត់យកថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០០២ ការរៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ បានចាប់ផ្តើមជាផ្លូវការ។ ជាបន្តបន្ទាប់ គ.ជ.ប បានធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុង អនុម័តបញ្ជានិងនីតិវិធីសម្រាប់ការបោះឆ្នោត ដើម្បីអនុលោមតាមច្បាប់ដូចមានចែងខាងលើ កសាងផែនការមេសម្រាប់ការបោះឆ្នោត ដែលមានចំនួនជាទឹកប្រាក់ ៧១.៩៥០.៧៦០.០០០រៀល ប្រមាណជា ១៧.៩៨៧.៦ ៩០ ដុល្លាអាមេរិក។(ឧបសម្ព័ន្ធ I ទំព័រទី ២៨) ការរអាក់រអួលខាងថវិកានៅគ្រាដំបូង បាននាំឱ្យមានការយឺតយ៉ាវក្នុងការចាប់ផ្តើមការងាររហូតដល់២២ ថ្ងៃ បើប្រៀបធៀបទៅនឹងប្រតិទិនការងារ។ តែទោះជាយ៉ាងណាក៏ដោយ គ.ជ.ប បានប្តេជ្ញាចិត្តបណ្តុះបណ្តាល និងការរៀបចំសម្ភារបរិក្ខារចាំបាច់ដែលត្រូវបម្រើការជាបន្ទាន់ ដើម្បីតម្រូវតាមពេលវេលា ដែលមានរយៈពេលតិចជាងការកំណត់ក្នុងប្រតិទិន។[៣០]

ការបោះឆ្នោតបានប្រព្រឹត្តទៅនៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០២ ចាប់ពីម៉ោង ៧:០០ ដល់ម៉ោង ១៥:០០រសៀល ដែលមានគណបក្សនយោបាយចូលរួមចំនួន៥២ ក៏ប៉ុន្តែមានគណបក្សនយោបាយចំនួន៨ប៉ុណ្ណោះ ដែលបានចុះបញ្ជីបេក្ខជនរបស់ខ្លួន ដើម្បីឈរឈ្មោះបោះឆ្នោតជាក្រុមប្រឹក្សាឃុំ សង្កាត់។[៣១] បេក្ខជនឈរឈ្មោះបោះឆ្នោតទូទាំងប្រទេសមាន ៧៥.២៨៧នាក់ ក្នុងនោះមានស្ត្រី ១២.៣៧៥ នាក់ ក្នុងនោះមានគណបក្សនយោបាយចំនួន៨ ដែលបានចុះឈ្មោះប្រកួតប្រជែង មានតែគណនយោបាយធំបីប៉ុណ្ណោះដែលបានចូលរួមយ៉ាងទូលំទូលាយនៅទូទាំងប្រទេសគឺគណបក្ស

(៣០), (៣១).របាយការណស្តីពីការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ សម័យបោះឆ្នោតថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ២០០២ ទំព័រ ១, ទំព័រ ២០

ប្រជាជនកម្ពុជា ១០០% គណបក្សហ្វ៊ុនស៊ិនប៉ិច ៩៩,២៧% និងគណបក្ស សម រង្ស៊ី ៩៤,៤១%។ (ឧបសម្ព័ន្ធទីvទំព័រទី ៣២)

ការិយាល័យបោះឆ្នោតសរុបចំនួន ១២.៥៣៤ការិយាល័យ ក្នុងនោះមានការិយាល័យភ្លោះចំនួន ៣២១ ការិយាល័យត្រូវបានបើកឱ្យដំណើរការ។ តែជាក់ស្តែងនៅថ្ងៃបោះឆ្នោតគឺមានតែការិយាល័យ ចំនួន ១២.៥២៨ប៉ុណ្ណោះបានដំណើរការដោយការិយាល័យចំនួន០៦ មានការិយាល័យលេខ ១០៨០ ១០៨១ នៅឃុំអង្គរាជ ការិយាល័យលេខ ០៧៣៥ ០៧៤១ ០៧៣៣ នៅឃុំបឹងដោល និង ការិយាល័យលេខ ០០៣២ នៅឃុំរក្សជ័យ នៃខេត្តព្រៃវែង មិនបានបើកឱ្យដំណើរការបោះឆ្នោត ព្រោះមានកំហុសបច្ចេកទេសផ្នែកបោះពុម្ព និងការវេចខ្ចប់សន្លឹកឆ្នោតច្រឡំគោលដៅ។ ករណីនេះ គណៈ កម្មាធិការជាតិរៀបចំការបោះឆ្នោតបានរាយការណ៍ជូននាយករដ្ឋមន្ត្រី ដើម្បីជ្រាបតាមច្បាប់ និងដើម្បីរៀបចំការបោះឆ្នោតសាជាសារជាថ្មី។[៣២] បន្ទាប់ពីការបានត្រួតពិនិត្យលទ្ធផល រួមទាំង លទ្ធផលនៃការបោះឆ្នោតនៃការបោះឆ្នោតនៅឃុំ ដែលត្រូវបានឱ្យបោះឆ្នោតសារជាថ្មី និងការរាប់ សន្លឹកឆ្នោតឡើងវិញ ចំពោះការិយាល័យមួយចំនួន ដែលមានការប្តឹងតវ៉ា គណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត បានចេញសេចក្តីប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុម ប្រឹក្សាឃុំ សង្កាត់ជាបន្តបន្ទាប់ ចាប់ពីថ្ងៃទី ១២ រហូតដល់ថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០០២។ ប្រជា ពលរដ្ឋដែលបានមកបោះឆ្នោតមាន ចំនួន៤.៥៤៣.៩៧៤ នាក់ ស្មើនឹង ៨៧,៥៥% នៃចំនួនអ្នកចុះ ឈ្មោះបោះឆ្នោតសរុបចំនួន ៥.១៩០.៣០៧នាក់។ ជាលទ្ធផល គណបក្សនយោបាយ ៤ គឺ គណ បក្សប្រជាជនកម្ពុជានាំមុខនៅក្នុងឃុំ សង្កាត់ចំនួន ១.៥៩៨ គណបក្សសមរង្ស៊ីនាំមុខនៅក្នុងឃុំ សង្កាត់ចំនួន ១៣ គណបក្សហ្វ៊ុនស៊ិនប៉ិចនាំមុខនៅក្នុងឃុំ សង្កាត់ចំនួន ១០ និងគណបក្សប្រជាធិប តេយ្យខ្មែរបាន ១អាសនៈ។[៣៣]

ក្នុងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នេះ គ.ជ.ប បានបង្ហាញថា ប្រជា ពលរដ្ឋ ៨៣,០២% នៃអ្នកមានវ័យបោះឆ្នោតបានទៅចុះឈ្មោះបោះឆ្នោត ប្រជាពលរដ្ឋ ៨៧,៥៥% នៃអ្នកបោះឆ្នោតបានទៅបោះឆ្នោត សម្តែងឆន្ទៈរបស់ខ្លួនដោយសេរី។ ដំណើរការបោះឆ្នោតបាន ប្រព្រឹត្តទៅដោយស្ងប់ស្ងាត់ប្រកបដោយសន្តិសុខ និងគ្មានអំពើហិង្សា ទោះបីក្នុងរយៈពេលរៀបចំ ការបោះឆ្នោត គេឃើញមានអំពើឃាតកម្ម ដោយមូលហេតុផ្សេងៗនៅកន្លែងខ្លះក៏ដោយ។ចំពោះ លក្ខណៈបច្ចេកទេសវិញ ត្រូវបានសាធារណៈមតិជាតិ និងអន្តរជាតិវាយតម្លៃល្អ ហើយលទ្ធផល

(៣២),(៣៣). របាយការណស្តីពីការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ សម័យបោះឆ្នោតថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ២០០២ ទំព័រ ២០ និងទំព័រ ២៤

នៃការបោះឆ្នោត ត្រូវបានទទួលស្គាល់ពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ។ ទន្ទឹមនឹងលទ្ធផលខាងលើនេះ ដំណើរការរៀបចំបោះឆ្នោត បានជួបការលំបាកខ្លះ ដែលនាំឱ្យមានការខ្វះខាត និងទទួលការរិះគន់ពីមជ្ឈសដ្ឋានជាតិ និងអន្តរជាតិមួយចំនួនតូច ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយកមកពិចារណា ដើម្បីជាមេរៀនសម្រាប់ការបោះឆ្នោតលើកក្រោយៗទៀត។[៣៤]

### ខ.ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ឆ្នាំ២០០៧

ដើម្បីឱ្យដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី២នេះ ប្រព្រឹត្តទៅបានល្អប្រសើរ និងសមស្របនឹងសភាពការណ៍វិវត្តថ្មី នៅខែមិថុនា ឆ្នាំ២០០៦ ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានធ្វើវិសោធនកម្មមាត្រាមួយចំនួនពាក់ព័ន្ធនឹងការចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងការចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតរបស់អង្គការមិនមែនរដ្ឋាភិបាល។ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ការចាត់ចែង និងគ្រប់គ្រងបញ្ជីឈ្មោះអ្នកបោះឆ្នោត និងគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាសមត្ថកិច្ចរបស់ គ.ជ.ប ដែលត្រូវបង្កើតឡើងតាមច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។[៣៥]ផ្អែកតាមលទ្ធផលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ២០០៦ បានបង្ហាញថាមានអ្នកបោះឆ្នោតចំនួន ៧.៧៩៩.៣៧១នាក់ ត្រូវបោះឆ្នោតក្នុងការិយាល័យបោះឆ្នោតចំនួន ១៤.៤២៨ ការិយាល័យ ក្នុងនោះមានការិយាល័យភ្លោះចំនួន ២៩០ ការិយាល័យ។[៣៦] ការបោះឆ្នោត បានប្រព្រឹត្តទៅនៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៧ ចាប់ពីម៉ោង ៧ព្រឹកដល់ម៉ោង ៣ រសៀល។ ការិយាល័យបោះឆ្នោតទាំងអស់នៅទូទាំងប្រទេសបានបើកដំណើរការព្រមគ្នា។គណៈកម្មការការិយាល័យនីមួយៗបានបំពាក់សម្ភារ ស្របតាមបច្ចេកទេស ដូចបានកំណត់នៅក្នុងបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត។ ក្នុងការិយាល័យបោះឆ្នោតនីមួយៗ មានវត្តមានភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងអ្នកសារព័ត៌មាន ដើម្បីចូលរួមសង្កេតមើលជាក់ស្ដែងនូវដំណើរការបោះឆ្នោតទាំងមូល។[៣៧]តាមការិយាល័យបោះឆ្នោតនីមួយៗទាំងបរិវេណខាងក្នុង និងបរិវេណខាងក្រៅ ត្រូវបានរៀបចំឱ្យមានសណ្ដាប់ធ្នាប់ និងមានកម្លាំងសន្តិសុខយាមកាមយ៉ាងហ្មត់ចត់ ដើម្បីរក្សាសន្តិសុខ និងសុវត្ថិភាពជូនអ្នកបោះឆ្នោត។ បរិយាកាសទូទៅក្នុងថ្ងៃបោះឆ្នោត ជារួមបានប្រព្រឹត្តទៅល្អ ស្ងប់ស្ងាត់ និងគ្មានអំពើហិង្សា។

---

(៣៤).របាយការណស្ដីពីការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ សម័យបោះឆ្នោតថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ២០០២ ទំព័រ ២៥ និង២៦

(៣៥),(៣៦), (៣៧).របាយការណស្ដីពីការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី២ ថ្ងៃអាទិត្យ ទី ០១ ខែមេសា ឆ្នាំ២០០៧ ទំព័រ ១, ៣៧ និងទំព័រ ៤១

លទ្ធផលនៃការបោះឆ្នោត មានប្រជាពលរដ្ឋបានទៅបោះឆ្នោតចំនួន ៥.២៩៣.៣២៧នាក់ ស្មើនឹង ៦៧,៨៧% នៃអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចំនួន ៧.៧៩៩.៣៧១នាក់។[ឧបសម្ព័ន្ធទី X ទំព័រទី៧៦]

ការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោត ចាប់តាំងពីយប់ថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៧ គ.ជ.ប បានប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមឃុំ សង្កាត់មួយចំនួនជាបន្តបន្ទាប់។ បន្ទាប់ពីបានបញ្ចប់ការត្រួតពិនិត្យលទ្ធផល ការផ្ទៀងផ្ទាត់ចំនួនអាសនៈក្នុងឃុំ សង្កាត់ នៃខេត្ត ក្រុង នីមួយៗ និងការដោះស្រាយបណ្តឹងទាក់ទងនឹងលទ្ធផលបោះឆ្នោតតាមឃុំ សង្កាត់ នីមួយៗចប់ គ.ជ.ប បានចេញសេចក្តីប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់ ជាបន្ត បន្ទាប់ចាប់ពីថ្ងៃទី១០ រហូតដល់ថ្ងៃទី ២៤ ខែមេសា ឆ្នាំ២០០៧។ លទ្ធផលផ្លូវការនៃការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី២ ត្រូវបានបង្ហាញថា មានគណបក្សចំនួន ៥ ប៉ុណ្ណោះ ដែលបានជាប់ឆ្នោតក្នុងឃុំ សង្កាត់ទាំង ១៦២១ ដែលទទួលបានតំណែងជាមេឃុំ ឬចៅសង្កាត់ ជំទប់ ចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងនោះគឺៈ គណបក្សប្រជាជនកម្ពុជា បាន នាំមុខក្នុងឃុំ សង្កាត់ ចំនួន ១.៥៩១ ឃុំ សង្កាត់ ទទួលបានអាសនៈ៧.៩៩៣ អសនៈ គណបក្ស សម រង្ស៊ី បាននាំមុខក្នុងឃុំ សង្កាត់ ចំនួន ២៨ ឃុំ សង្កាត់ ទទួលបានអសនៈ ២.៦៦០ អាសនៈ គណបក្សហ្វ៊ុនស៊ិនប៉ិច បាននាំមុខក្នុងឃុំ សង្កាត់ចំនួន ២ ឃុំ ទទួលបានអាសនៈ ២៧៤ អាសនៈ។ ក្នុងចំណោមសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាប់ឆ្នោតសរុប ១១.៣៥៣អាសនៈ មាន សមាជិកជាស្ត្រីចំនួន ១.៦៦១ នាក់ ស្មើនឹង១៤.៦៣%។[៣៨]

ក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី២ឆ្នាំ២០០៧ នេះ ត្រូវបានសាធារណមតិជាតិ អន្តរជាតិ គណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល អន្តរ ជាតិ អ្នកសង្កេតការណ៍បោះឆ្នោត តំណាងស្ថានទូតជាច្រើនវាយតម្លៃជាវិជ្ជាមានថា បានប្រព្រឹត្តទៅ ល្អ រលូន មានសណ្តាប់ធ្នាប់ សន្តិភាព តម្លាភាព ត្រឹមត្រូវ និងមានប្រជាធិបតេយ្យ និងបានវាយតម្លៃ អំពីសមត្ថភាពបច្ចេកទេសក្នុងការរៀបចំការបោះឆ្នោត។ ជាមួយនេះ គ.ជ.ប ក៏ទទួលរងនូវការរិះ គន់មួយចំនួន ពិសេសអំពីគុណភាពនៃបញ្ជីបោះឆ្នោត និងការធ្លាក់ចុះនៃអត្រាអ្នកបោះឆ្នោត។ ជោគជ័យនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ ឆ្នាំ២០០៧ គឺជាសមិទ្ធិផល ថ្មីមួយទៀត នៃការរីកចម្រើននៃលទ្ធិប្រជាធិតេយ្យ និងការអនុវត្តគោលនយោបាយវិមជ្ឈការនៅ ព្រះរាជាណាចក្រកម្ពុជា។[៣៩]

(៣៨),(៣៩).របាយការណស្តីពីការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី២ ថ្ងៃអាទិត្យ ទី ០១ ខែមេសា ឆ្នាំ២០០៧ ទំព័រ ៤១,៤២ និងទំព័រ ៣៧

## គ.ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ឆ្នាំ២០១២

វិសោធនកម្មមាត្រា ១៩០ ថ្មី(ពីរ)នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ បានកំណត់យកថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១២ ជាកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣។ ឃុំសង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាមួយ ដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួន តាមការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ តាមប្រព័ន្ធសមាមាត្រ ដោយបែងចែកអាសនៈតាមមធ្យមភាគខ្ពស់បំផុត ហើយយកឃុំ សង្កាត់ធ្វើជាមណ្ឌលបោះឆ្នោត។[៤០]

ការបោះឆ្នោតបានប្រព្រឹត្តពីម៉ោង ៧:០០ ព្រឹកដល់ម៉ោង ៣ រសៀល ផ្អែកតាមបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១១ អ្នកបោះឆ្នោតសរុបចំនួន ៩.២០៣.៤៩៣ នាក់ ក្នុងនោះអ្នកបោះឆ្នោតជាស្ត្រីចំនួន ៤.៨៦១.៨៥៣ នាក់ ស្មនឹង ៥២.៨៣% នៃចំនួនអ្នកបោះឆ្នោតសរុបត្រូវបោះឆ្នោតនៅការិយាល័យបោះឆ្នោតចំនួន ១៨.១០៧ ការិយាល័យ ក្នុងឃុំ សង្កាត់ចំនួន ១,៦៣៣ នៃរាជធានី ខេត្តទាំង២៤។ ដំណើរការបោះឆ្នោតបានប្រព្រឹត្តទៅក្រោមបរិយាកាសល្អ ស្ងប់ស្ងាត់ គ្មានអំពើហិង្សា គ្មានការគម្រាមកំហែង។ អ្នកបោះឆ្នោតចំនួន ៥,៩៩៣,៩៩២ នាក់ ស្មើនឹង ៦៥.១៣% នៃចំនួនអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតបានទៅបោះឆ្នោត។ អ្នកបោះឆ្នោតដែលអវត្តមានភាគច្រើនជាអ្នកចំណាកស្រុក អ្នកចេញទៅធ្វើការនៅក្រៅប្រទេស និងមួយចំនួន គឺដោយសារមូលហេតុផ្ទាល់ខ្លួន ឬមូលហេតុផ្សេងទៀត។[៤១]

គ.ជ.ប បានចេញសេចក្តីប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១២។ លទ្ធផលនេះបានបង្ហាញថា ក្នុងឃុំ សង្កាត់ទាំង ១៦៣៣ មានគណបក្សចំនួន៧ប៉ុណ្ណោះ ដែលបានជាប់ឆ្នោត និងទទួលបានអាសនៈនៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់ ហើយគណបក្សនយោបាយដែលបានទទួលតំណែងជាមេឃុំ ឬចៅសង្កាត់ ជំទប់ ឬចៅសង្កាត់រង និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។ ក្នុងចំណោមសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលជាប់ឆ្នោតសរុប១១,៤៥៩ អាសនៈមានសមាជិកជាស្ត្រីចំនួន ២,០៣៨នាក់ ស្មើនឹង ១៧.៧៨%។

(៤០), (៤១). គ.ជ.ប របាយការណ៍ស្តីពីការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២ ទំព័រ ១, ៤៦ និងទំព័រ៤៧

## ២.២ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០០៨ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ នឹងដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៨ នាសម័យប្រជុំពេញអង្គលើកទី៤ នីតិកាលទី២ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ០៩៧/០០២/២០០៨ កបធ.ច ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៨ ។

### ក.ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា រាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក-ខណ្ឌ ឆ្នាំ២០០៩

តាមសេចក្តីសម្រេចលេខ ២៣ សសរ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០០៩ ជាកាលបរិច្ឆេទនៃការបោះឆ្នោតលើកទី១ ដើម្បីជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ(ក្រុមប្រឹក្សា) ដែលជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រថ្មីមួយទៀត នៃការបោះឆ្នោតអសកលដោយមានក្រុមប្រឹក្សាឃុំ សង្កាត់ ទាំងអស់នៅក្នុងមុខតំណែងជាអ្នកបោះឆ្នោត។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា គឺជាគោលនយោបាយក្នុងការកែទម្រង់រដ្ឋបាលសាធារណៈថ្នាក់ក្រោមជាតិ ដើម្បីនាំមកនូវការគ្រប់គ្រងមួយតាមបែបវិមជ្ឈការ និងវិសហមជ្ឈការ សម្រាប់អនុវត្តនៅថ្នាក់រាជធានី/ខេត្ត ក្រុង ស្រុក/ខណ្ឌ ក្នុងគោលដៅធ្វើការកែលម្អឱ្យកាន់តែប្រសើរឡើងដល់ការគ្រប់គ្រងរដ្ឋបាលឯកភាពមួយនៅកម្ពុជា។ នេះជាលើកដំបូងហើយ ដែលព្រះរាជាណាចក្រកម្ពុជាបានធ្វើការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពីរប្រភេទផ្សេងគ្នាក្នុងការិយាល័យបោះឆ្នោតតែមួយ និងពេលតែមួយក្នុងនេះ មានអាសនៈក្រុមប្រឹក្សារាជធានីខេត្តចំនួន ៣៧៥នាក់ និងអាសនៈក្រុមប្រឹក្សាក្រុង/ស្រុក/ខណ្ឌ ២,៨៦១ នាក់។[៤២] ផ្អែកតាមបញ្ជីបោះឆ្នោត មានអ្នកបោះឆ្នោតដែលសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ចំនួន ១១,៣៥៣នាក់ ត្រូវបោះឆ្នោតក្នុងការិយាល័យចំនួន ១៩៣ ការិយាល័យចំណុះឱ្យ២១៧ មណ្ឌលបោះឆ្នោត។ បញ្ជីទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតទាំងអស់ ត្រូវបានបិទផ្សាយតាំងថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០០៩ នៅសាលាឃុំ សង្កាត់ និងនៅតាមមណ្ឌលបោះឆ្នោតក្រុង/ស្រុក/ខណ្ឌ។

(៤២).របាយការណ៍ស្តីពីការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី១ ឆ្នាំ២០០៩ ទំព័រ ១,២១ និង ២២

ការបោះឆ្នោតបានប្រព្រឹត្តទៅនៅថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០០៩ ចាប់ពីម៉ោង ៧ព្រឹក រហូតដល់ម៉ោង ៣ រសៀល។ គណៈកម្មការការិយាល័យបោះឆ្នោត(គកប) បានរៀបចំការិយាល័យរៀងៗខ្លួនស្របតាមលក្ខណៈបច្ចេកទេសដូចបានកំណត់ក្នុងបទបញ្ជា និងនីតិវិធី ក្នុងនោះមានបំពាក់នូវសម្ភារ បរិក្ខារគ្រប់គ្រាន់ សម្រាប់ បម្រើឱ្យការបោះឆ្នោត។ នៅគ្រប់ការយាល័យបោះឆ្នោតវត្តមានតំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ និងអ្នកសារព័ត៌មាន។ តាមច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អ្នកបោះឆ្នោតម្នាក់ ត្រូវបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាពីរ(២) ប្រភេទផ្សេងគ្នាក្នុងការិយាល័យបោះឆ្នោតតែមួយ និងជាបន្តបន្ទាប់គ្នាដូចខាងក្រោម៖

-លើកទី១ ត្រូវបោះឆ្នោតសន្លឹកពណ៌ខៀវ ដាក់ក្នុងហិបឆ្នោតទី១ សម្រាប់ជ្រើសរើសក្រុមប្រឹក្សាក្រុង/ស្រុក/ខណ្ឌ។

-លើកទី២ ត្រូវបោះឆ្នោតសន្លឹកឆ្នោតពណ៌ស ដាក់ក្នុងហិបឆ្នោតទី២ សម្រាប់ជ្រើសរើសក្រុមប្រឹក្សារាជធានី/ខេត្ត។

ផ្អែកតាមគំនូសលើបញ្ជីបោះឆ្នោតទាំង ១៩៣ការិយាល័យ មានអ្នកបោះឆ្នោតចំនួន ១១.៣៤៩ ស្មើនឹង៩៩.៩០% នៃអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចំនួន ១១.៣៥៣នាក់ បានបោះឆ្នោតសម្តែងឆន្ទៈរបស់ខ្លួន ដោយសេរីតាមរយៈសន្លឹកឆ្នោតជាសម្ងាត់ ក្នុងនោះមានអ្នកបោះឆ្នោតពីរ(២) នាក់ដែលជាប់ពន្ធនាគារ ហើយពុំទាន់មានសាលក្រមស្ថាពរនៅឡើយ និងដែលត្រូវបាន គ.ជ.ប ធ្វើអន្តរាគមន៍ទៅស្ថាប័នពាក់ព័ន្ធ ដើម្បីបង្កលក្ខណៈឱ្យពួកគាត់បានចូលរួមបោះឆ្នោតបានទាន់ពេលវេលាដែរ។ អ្នកបោះឆ្នោតចំនួន ៥នាក់ បានអវត្តមានដោយមូលហេតុទទួលមរណភាព មានជម្ងឺ និងចាកចេញទៅក្រៅប្រទេសមុនថ្ងៃបោះឆ្នោត។[៤៣]

លទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌត្រូវបាន គ.ជ.ប ធ្វើការផ្សព្វផ្សាយនៅថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០០៩។[៤៤] នេះជាលើកទី១ ដែល គ.ជ.ប រៀបចំការបោះឆ្នោត ដែលអ្នកបោះឆ្នោតម្នាក់ត្រូវបោះឆ្នោតពីរសន្លឹក។ អាស្រ័យដោយការរៀបបច្ចេកទេសបានល្អនៅការិយាល័យ ដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោតបានប្រព្រឹត្តទៅរលូនល្អ មានលក្ខណៈសេរី និងយុត្តិធម៌ អ្នកបោះឆ្នោតប្រមាណ ៩៩.៩០% បានទៅបោះឆ្នោត ហើយការិយាល័យបោះឆ្នោតភាគច្រើនបានបិទការបោះឆ្នោតនៅមុនម៉ោង ១០ព្រឹក។ លទ្ធផលបឋម លទ្ធផលបណ្តោះអាសន្ន និងលទ្ធផលផ្លូវការនៃការបោះឆ្នោត

(៤៣).របាយការណ៍ស្តីពីការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី១ ឆ្នាំ២០០៩ ទំព័រ ២១ និង ២២

(៤៤).ឧបសម្ព័ន្ធទី VI ទំព័រ ៤៩ របាយការណ៍ស្តីពីការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី១ ឆ្នាំ២០០៩ ទំព័រ២៦

ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយជាបន្ទាន់ និងបន្តបន្ទាប់តាមការគ្រោងទុក។ ដំណើរការបោះឆ្នោតក៏មានការខ្វះខាតមួយចំនួនដូចជា ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ដោយពុំបានពិនិត្យត្រឹមត្រូវពីលក្ខខណ្ឌអាយុរបស់បេក្ខជន។[៤៥]

ជោគជ័យនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឆ្នាំ២០០៩ បាននាំមកនូវការបង្កើតក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យបានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។[៤៦]

## ខ.ការបោះឆ្នោតឡើងវិញជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ ឆ្នាំ២០១១

ខណ្ឌពោធិ៍សែនជ័យ គឺជាខណ្ឌទើបបង្កើតថ្មីចំណុះឱ្យរាជធានីភ្នំពេញតាមអនុក្រឹត្យលេខ ៨០ អនក្រ.បកចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ របស់រាជរដ្ឋាភិបាលកម្ពុជា។ ខណ្ឌនេះមានសង្កាត់ចំនួន ១៣ គឺសង្កាត់ត្រពាំងក្រសាំង គោករកា ភ្លើងឆេះរទេះ ចោមចៅ កាកាប សំរោងក្រោម ក្រាំងធ្នង់ បឹងធំ កំបូល កន្ទោក ឪឡោក ពន្សាំង និងសង្កាត់ស្នោ ដែលកាត់ចេញពីខណ្ឌដង្កោ។

តាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាខណ្ឌ(ច.ប.ក) ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបង្កើតថ្មីត្រូវរៀបចំការបោះឆ្នោតឡើងវិញ ដើម្បីជ្រើសរើសក្រុមប្រឹក្សាក្នុងរយៈពេលយ៉ាងយូរពីររយសែសិប(២៤០)ថ្ងៃ បន្ទាប់ពីការបង្កើតខេត្ត ក្រុង ស្រុកខណ្ឌ នោះ និងក្នុងករណីអាណត្តិនៅសល់របស់ក្រុមប្រឹក្សាមានរយៈពេលលើសពី ១៨០ថ្ងៃ។

បញ្ជីបោះឆ្នោតត្រូវបានបិទផ្សាយនៅការិយាល័យបោះឆ្នោតស្ថិតក្នុងវិទ្យាល័យ ហ៊ុន សែន ជម្ពូវ័ន្ត នាថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១១។ ទីតាំងការិយាល័យបោះឆ្នោតត្រូវបានបិទផ្សាយនៅថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ២០១១ នៅទីស្នាក់ការ គធប រាជធានីភ្នំពេញ សាលាខណ្ឌពោធិ៍សែនជ័យ វិទ្យាល័យ ហ៊ុន សែន ជម្ពូវ័ន្ត និងសាលាសង្កាត់ទាំង ១៣។ នៅថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០១១ វេលាម៉ោង ៧ព្រឹក គណៈកម្មការការិយាល័យបោះឆ្នោត (គកប) បានបើកការិយាល័យបោះឆ្នោតស្របតាមកាលកំណត់។ នៅមុខការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតបានឈរជាជួរ និងមានរបៀបរៀបរយ ដើម្បីចូលរួមបោះឆ្នោត ដោយមានការចូលរួមសង្កេតមើលពីតំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ និងអ្នកសារព័ត៌មានមួយចំនួនទៀត។ដំណើរការបោះឆ្នោតបានប្រព្រឹត្តទៅដោយរលូនល្អស្ងប់

(៤៥).របាយការណ៍ស្តីពីការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតឡើងវិញជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ ឆ្នាំ២០១១ ទំព័រ១

(៤៦). របាយការណ៍ស្តីពីការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី១ ឆ្នាំ២០០៩ ទំព័រ២៩

ស្ងាត់គ្មានអំពើហិង្សា ដោយមានការការពារសន្តិសុខ សុវត្ថិភាពពីអាជ្ញាធរមានសមត្ថកិច្ច។[៤៧]

ដំណើរការបោះឆ្នោតឡើងវិញជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ នៃរាជធានីភ្នំពេញ បានប្រព្រឹត្តទៅត្រឹមត្រូវស្របតាមច្បាប់ បទបញ្ញា និងនីតិវិធី ប្រកបដោយជោគជ័យ គ្មានការគម្រាមកំហែងការបំភិតបំភ័យ និងអំពើហិង្សាណាមួយដែលគួរឱ្យគត់សម្គាល់ឡើយ។ ការបោះឆ្នោតឡើងវិញជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ គឺជាការបោះឆ្នោតសម្រាប់ខណ្ឌដែលបានបង្កើតថ្មីដើម្បីបង្គ្រប់អាណត្តិនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ កាលពីឆ្នាំ ២០០៩ កន្លងមក។

ស្ថាប័នពាក់ព័ន្ធអាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងអ្នកបោះឆ្នោតដែលជាសមាជិកក្រុមប្រឹក្សាសង្កាត់ បានចូលរួមសហការអនុវត្តប្រកបដោយការយល់ដឹងខ្ពស់ដើម្បីបំពេញកាតព្វកិច្ចក្នុងការបោះឆ្នោត ដែលជាការបង្ហាញឱ្យឃើញដំណើរការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាកាន់តែចាក់គ្រឹះរឹងមាំជាលំដាប់។[៤៨]

## គ. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០១៤

រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៤ កាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាអាណត្តិទី២។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាអាណត្តិទី២បានប្រព្រឹត្តទៅក្នុងបរិយាកាសសង្គម និងសេដ្ឋកិច្ចកម្ពុជា មានការប្រែប្រួលក្នុងរបត់ថ្មី ដែលក្នុងនោះសភាពការណ៍នយោបាយនៅក្រោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ឆ្នាំ ២០១៣ នៅមិនទាន់វិលទៅរកសភាពការធម្មតាវិញនៅឡើយ។ បើប្រៀបធៀប នឹងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាអាណត្តិទី១ ឆ្នាំ២០០៩ ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាអាណត្តិទី២ ឆ្នាំ២០១៤ ចំនួនអ្នកបោះឆ្នោត ចំនួនមណ្ឌលបោះឆ្នោត និងចំនួនសមាជិកក្រុមប្រឹក្សាគ្រប់ប្រភេទមានការកើនឡើង។ ក្នុងនោះចំនួនឃុំ សង្កាត់ បានកើនឡើងពី ១,៦២១ ដល់ ១,៦៣៣ និងចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់បានកើនឡើងពី ១១,៣៥៣ ដល់ ១១,៤៥៩នាក់។ ខេត្តថ្មីមួយគឺខេត្តត្បូងឃ្មុំ ត្រូវបានបង្កតឡើងដោយបំបែកចេញពីខេត្តកំពង់ចាមបន្ថែម ដែលធ្វើឱ្យរាជធានី ខេត្តកើនឡើងដល់ ២៥ ហើយនៅរាជធានីភ្នំពេញ ខណ្ឌថ្មីចំនួន ៣ ត្រូវបានបង្កើតឡើងបន្ថែម ដែលធ្វើឱ្យចំនួនក្រុង ស្រុក ខណ្ឌរុបកើនឡើងពី ១៩៤ ដល់ ១៩៧ ជាមួយនេះចំនួនស្រុក ខណ្ឌបានកើនឡើងពី ២,៨៨០ ដល់២,៩៣១។[៤៩]

(៤៧),(៤៨).របាយការណ៍ស្តីពីការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតឡើងវិញជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ ឆ្នាំ២០១១ ទំព័រ១, ១២និង១៣

(៤៩).គ.ជ.ប សន្និបាតបូកសរុបការងារបោះឆ្នោតជ្រើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អាណត្តិទី២ ឆ្នាំ២០១៤ ខេត្តព្រះសីហនុ ថ្ងៃទី០៩-១០ ខែមិថុនា ឆ្នាំ២០១៤ ទំព័រ ៤, ៥

ដោយផ្អែកតាមបញ្ជីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាអាណត្តិទី២ ឆ្នាំ២០១៤ អ្នកបោះឆ្នោតដែលជាសមាជិក កបយ/ស ក្នុងតំណែងសរុបមានចំនួន ១១.៤៥៩ នាក់ មានការិយាល័យបោះឆ្នោតចំនួន ១៩៧ ដែលមានទីតាំងនៅទីប្រជុំជនក្រុង ខណ្ឌ។ មណ្ឌលបោះឆ្នោតរាជធានី ខេត្ត មានចំនួន២៥ និងមណ្ឌលបោះឆ្នោតក្រុង ស្រុក ខណ្ឌ មានចំនួន ១៩៧។ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាអាណត្តិទី២ ឆ្នាំ២០១៤បានប្រព្រឹត្តទៅដោយរលូនក្រោមអាកាសធាតុអំណោយផលល្អ បរិយាកាសស្ងប់ស្ងាត់ គ្មានអំពើហិង្សា និងគ្មានការគម្រាមកំហែង ឬបង្ខិតបង្ខំឡើយ។ អ្នកបោះឆ្នោតចំនួន ១១.៤៥៦នាក់ ស្មើនឹង ៩៩.៩៧% នៃចំនួនអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត បានទៅបោះឆ្នោតនៅតាមការិយាល័យបោះឆ្នោតក្នុងក្រុង ស្រុក ខណ្ឌ លើកលែងតែអ្នកបោះឆ្នោតចំនួន ០៣ រូប មិនបានទៅបោះឆ្នោត ដោយសារមូលហេតុផ្ទាល់ខ្លួន។[៥០]ក្រោយពីបានពិនិត្យឃើញថា ត្រឹមត្រូវហើយ នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៤ គ.ជ.ប បានផ្តល់សុពលភាពលើលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាអាណត្តិទី២ ឆ្នាំ២០១៤ ដែលរួមមានលទ្ធផលសំឡេងឆ្នោតលទ្ធផលបែងចែកអាសនៈនិងបេក្ខជនជាប់ឆ្នោត។[៥១]

(៥០).គ.ជ.ប សន្និបាតបូកសរុបការងារបោះឆ្នោតជ្រើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អាណត្តិទី២ ឆ្នាំ២០១៤ ខេត្តព្រះសីហនុ ថ្ងៃទី០៩-១០ ខែមិថុនា ឆ្នាំ២០១៤ ទំព័រ ៣៥ និង៣៨

(៥១).ឧបសម្ព័ន្ធ Vទំព័រទី ៦២ គ.ជ.ប សន្និបាតបូកសរុបការងារបោះឆ្នោតជ្រើសក្រុមប្រឹក្សារាជធានី ខេត្ត និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អាណត្តិទី២ ឆ្នាំ២០១៤ ខេត្តព្រះសីហនុ ថ្ងៃទី០៩-១០ ខែមិថុនា ឆ្នាំ២០១៤

# ជំពូកទី២
# ការដាក់បញ្ចូលស្ថាប័នរៀបចំការបោះឆ្នោតទៅ
# ជាស្ថាប័នមានចែងក្នុងរដ្ឋធម្មនុញ្ញ

# ជំពូកទី ២

# ការដាក់បញ្ចូលស្ថាប័នរៀបចំការបោះឆ្នោតទៅជាស្ថាប័នមានចែងក្នុងរដ្ឋធម្មនុញ្ញ

## ១. បញ្ហាប្រឈមក្រោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នៃនីតិកាលនីមួយៗ

នៅរាល់ពេលបោះឆ្នោតម្តងៗ អង្គការសង្គមស៊ីវិលផ្នែកសិទ្ធិមនុស្ស ក្រុមអង្គការឃ្លាំមើលការបោះឆ្នោត តែងលើកឡើងអំពីបញ្ហាភាពមិនប្រក្រតីផ្សេងៗ ដែលជាក្តីកង្វល់ដ៏ធំចំពោះស្ថានភាពសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ និងជោគវាសនាប្រទេសជាតិលើគន្លងប្រជាធិបតេយ្យ។ ឯកសារណែនាំអំពីរបៀបសង្កេតមើលភាពមិនប្រក្រតីក្នុងដំណើរការបោះឆ្នោតរបស់សហព័ន្ធអន្តរជាតិដើម្បីអ្នកសារព័ត៌មានមាន (International Federation Journalist =IFJ) បង្ហាញថា ការទិញ និងការលួចសន្លឹកឆ្នោត ការបោកបញ្ឆោតបំភាន់ បន្ទំបោះឆ្នោតពីរដង ការរាប់សន្លឹកឆ្នោតមិនត្រឹមត្រូវ និងការផ្តល់របាយការណ៍មិនពិតដល់ក្រុមអ្នកសារព័ត៌មាន ដែលនាំឱ្យមានការយល់ខុសជាដើមនោះ គឺជាចំណុចធំៗ នៃភាពមិនប្រក្រតីដែលតែងកើតមានក្នុងដំណើរការបោះឆ្នោតម្តងៗ។

ចំណុចសំខាន់មួយទៀត នៃភាពមិនប្រក្រតីដែលក្រុមអ្នកសារព័ត៌មាន និងក្រុមអ្នកសង្កេតការណ៍បោះឆ្នោត តែងផ្តោតការយកចិត្តទុកដាក់យ៉ាងពិនិត្យពិច័យនោះ គឺបញ្ហាផ្សេងៗ ទាក់ទងនឹងការផ្គត់ផ្គង់សម្ភារៈបោះឆ្នោត មធ្យោបាយរៀបចំទុកដាក់ និងដឹកជញ្ជូនជាដើម។ ក្នុងនោះបញ្ហាដែលតែងកើតមានជាញឹកញាប់ រួមមានការមិនមានចំនួនសន្លឹកឆ្នោត និងស្រោមសំបុត្រគ្រប់គ្រាន់ ការបាត់សន្លឹកឆ្នោតរបស់គណបក្សនយោបាយមួយចំនួន ទឹកខ្មៅជ្រលក់ម្រាមដៃអ្នកបោះឆ្នោតគ្មានគុណភាពមិននៅជាប់បានយូរ ដែលគេអាចលាងចេញបាន ហើយចូលទៅបន្លំបោះឆ្នោតបានម្តងទៀត។ ទន្ទឹមគ្នានេះ បញ្ហាខ្វះភាពសម្ងាត់នៃការបោះឆ្នោត បាត់វត្តមានមន្ត្រីបោះឆ្នោត បាត់បញ្ជីឈ្មោះអ្នកបោះឆ្នោត និងបន្ទប់បោះឆ្នោតងងឹត គ្មានអំពូលភ្លើងបំភ្លឺជាដើម។ឯកសារនានាស្តីពីការបោះឆ្នោតបង្ហាញថា នៅក្នុងការបោះឆ្នោតថ្នាក់ជាតិ សកម្មភាពដែលបង្កើតឱ្យមានភាពមិនប្រក្រតីអាចបណ្តាលឱ្យមានផលវិបាកដ៏អាក្រក់នានា មានការធ្វើរដ្ឋប្រហារ ឬការបាត់បង់លទ្ធិប្រជាធិបតេយ្យ និងរុញច្រានប្រទេសជាតិឱ្យធ្លាក់ទៅក្នុងរបបផ្តាច់ការជាដើម។

អ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិ ទទួលបន្ទុកផ្នែកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា **លោក សុរិយា ស៊ូប៊ែឌី (Surya Subedi)** ធ្លាប់ផ្តល់អនុសាសន៍ថា កម្ពុជាចាំបាច់ត្រូវតែធ្វើកំណែទម្រង់ គ.ជ.ប តាមរយៈការធ្វើឲ្យមានភាពឯករាជនៃប្រធាន គ.ជ.ប ថ្នាក់ជាតិ និងថ្នាក់ខេត្ត ហើយត្រូវតែបញ្ចូល

តំណាងមកពីគ្រប់គណបក្សនយោបាយ ដែលមានអាសនៈនៅក្នុងរដ្ឋសភា ដើម្បីឲ្យការបោះឆ្នោតនោះអាចទទួលយកបាន។ ប៉ុន្តែប្រមុខដឹកនាំរដ្ឋាភិបាល គណបក្សប្រជាជនកម្ពុជា និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គ.ជ.ប តែងបដិសេធនូវរាល់របាយការណ៍របស់អង្គការសង្គមស៊ីវិលជាតិ និងសហគមន៍អន្តរជាតិ ព្រមទាំងការលើកឡើងរបស់គណបក្សប្រឆាំង និងប្រជាពលរដ្ឋទាក់ទងនឹងបញ្ហាមិនប្រក្រតីក្នុងដំណើរការបោះឆ្នោតម្តងៗ។[៥២]

## ១.១ ហេតុការណ៍ដែលៗកើតឡើងក្រោយពេលប្រកាសលទ្ធផលឆ្នោតរបស់ គ.ជ.ប

ជាវប្បធម៌ទៅហើយ ដែលគណបក្សចាញ់ឆ្នោតតែងតែស្រែកថា អយុត្តិធម៌ ការបោះឆ្នោតប្រព្រឹត្តទៅមានភាពមិនប្រក្រតី មានការលួចបន្លំ និង គ.ជ.ប មិនឯករាជ្យ ជាដើម។ ចំណែកគណបក្សដែលឈ្នះឆ្នោតទទួលយកជាទីគាប់ចិត្តដោយពួកគេសារទរចំពោះលទ្ធផលដែលបានប្រកាសដោយ គ.ជ.ប ហើយពួកគេថា ដំណើរការរៀបចំការបោះឆ្នោតប្រព្រឹត្តទៅដោយឯករាជ្យ មិនដូចការលើកឡើងពីខាងបក្សចាញ់ឆ្នោតនោះទេ ។ វាមិនខុសពីកីឡាករតែងទាមទារយុត្តិធម៌ក្នុងការប្រកួត ហើយយុត្តិធម៌នេះពឹងផ្អែកយ៉ាងខ្លាំងទៅលើកម្រិតនៃអព្យាក្រឹត្យភាពរបស់អាជ្ញាកណ្តាល។ ដោយសារតែអាជ្ញាកណ្តាលក្នុងការបោះឆ្នោតនៅកម្ពុជា ត្រូវបានទស្សនិកជនជាច្រើនមើលឃើញថាលម្អៀង វប្បធម៌ឡាំប៉ាតែងតែកើតមានក្រោយពេលសម្រេចលទ្ធផល។

ចាប់តាំងពីការបោះឆ្នោតលើកទី១ ដែលរៀបចំដោយ អ៊ុនតាក់ នៅឆ្នាំ១៩៩៣ មកគណបក្សដែលចាញ់ឆ្នោតតែងតែអះអាងថាខ្លួនជាអ្នកឈ្នះ ជាហេតុដែលនាំឲ្យមានការជាប់គាំងនយោបាយ ហើយ ក៏ជាឱកាសដែលបក្សតូចៗចូលរួមបង្កើតរដ្ឋាភិបាលចម្រុះ ដើម្បីចែកអំណាចគ្នាដែរ។ ជាក់ស្តែងក្រោយការបោះឆ្នោតឆ្នាំ១៩៩៣ គណបក្សប្រជាជនកម្ពុជាប្រកាសមិនទទួលយកលទ្ធផលការបោះឆ្នោតដែលគណបក្សហ្វ៊ុនស៊ិនប៉ិច ជាអ្នកឈ្នះជាហេតុនាំឲ្យមានការការជាប់គាំងនយោបាយឈានដល់ការបង្កើតឱ្យមាននាយករដ្ឋមន្ត្រីពីររូប ដែលក្នុងប្រវត្តិសាស្ត្រមិនដែលមាន។ បន្ទាប់ពីការបោះឆ្នោតនៅឆ្នាំ១៩៩៨ សភាមួយថ្នាក់ទៀតត្រូវបានបង្កើតឡើង។ ស្ថាប័នព្រឹទ្ធសភា គឺជាផ្លែផ្កានៃការមូលមតិគ្នាខាងនយោបាយ សំដៅដោះស្រាយភាពជាប់គាំងខាងនយោបាយក្រោយការបោះឆ្នោត ដែលអង្គនីតិប្រតិបត្តិមិនអាចបង្កើតបានដោយសារលក្ខខណ្ឌសំឡេងភាគច្រើនដាច់ខាត ២/៣ នៅក្នុងរដ្ឋសភា។

(៥២).ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៣ ដោយកេសរណ្ណីយ្យា

## ១.២ ហេតុការណ៍កើតឡើងក្រោយពេលប្រកាសលទ្ធផលបោះឆ្នោតរបស់ គ.ជ.ប នៅឆ្នាំ ២០១៣

### ក. ការមិនទទួលស្គាល់លទ្ធផលរបស់គណបក្សសង្គ្រោះជាតិ

ខណៈដែលលទ្ធផលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រសម្រាប់អាណត្តិទី៥ ឆ្នាំ២០១៣ នៅថ្ងៃអាទិត្យ ទី២៨ កក្កដា នៅមិនទាន់ចេញសម្រេចជាផ្លូវការនៅឡើយ លទ្ធផលបឋមពីការរាប់សន្លឹកឆ្នោត គិតត្រឹមពាក់កណ្ដាលអាធ្រាត្រថ្ងៃទី២៨ កក្កដា បានបង្ហាញថា គណបក្សធំៗពីរ គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិទទួលបានលទ្ធផលប្រទាញប្រទង់គ្នា។ ប៉ុន្តែគណបក្សប្រជាជនកម្ពុជា ប្រកាសថា គណបក្សខ្លួនជាអ្នកឈ្នះការបោះឆ្នោត។ គណបក្សប្រជាជនកម្ពុជា បានចេញសេចក្ដីប្រ កាសលទ្ធផលឆ្នោតនៅរំលងអាធ្រាត្រថ្ងៃទី២៨ កក្កដា ថា គណបក្សប្រជាជនកម្ពុជាឈ្នះដាច់គណបក្សសង្គ្រោះជាតិ។ នៅក្នុងសេចក្ដីប្រកាសរបស់គណៈកម្មាធិការកណ្ដាលនៃគណបក្សប្រជាជនកម្ពុជា សរសេរថា «យោងតាមលទ្ធផលបឋមនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រសម្រាប់អាណត្តិទី៥នៅទូទាំងប្រទេសបានបង្ហាញយ៉ាងច្បាស់ថា គណបក្សប្រជាជនកម្ពុជាទទួលបានជ័យជម្នះរហូតទទួលបានអាសនៈភាគច្រើនដាច់ខាតក្នុងរដ្ឋសភានីតិកាលថ្មី ដែលមានបរិមាណគ្រប់គ្រាន់ក្នុងការរៀបចំរាជរដ្ឋាភិបាលនីតិកាលថ្មីនេះ»។ សេចក្ដីប្រកាសនេះ គឺក្រោយពេលដែលគណបក្សសង្គ្រោះជាតិ សាទរនឹងជ័យជម្នះដូចគ្នា។

ជាមួយគ្នានោះដែរ គណបក្សសង្គ្រោះជាតិ បានចេញសេចក្ដីថ្លែងការណ៍នៅពេលចាប់ផ្ដើមរាប់សន្លឹកឆ្នោតថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ដោយប្រកាសសាទរពីជ័យជម្នះនៃការបោះឆ្នោតក្នុងអាណត្តិទី៥ នេះ។ ប៉ុន្តែជាងមួយម៉ោងក្រោយមក គណបក្សនេះបានចេញសេចក្ដីប្រកាសមួយទៀត ដោយកែតម្រូវពីការឈ្នះឆ្នោត ទៅជាការអរគុណចំពោះអ្នកទៅបោះឆ្នោតវិញ។ អ្នកគាំទ្រគណបក្សសង្គ្រោះជាតិ ខ្លះមន្ទិលសង្ស័យថាអាចមានសម្ពាធអ្វីនៅពីក្រោយនៃរឿងសេចក្ដីប្រកាសដែលប្រែក្រឡាស់មួយរំពេចនេះ។ ក្នុងពេលដំណើរការរាប់សន្លឹកឆ្នោតនៅតាមការិយាល័យចាប់ផ្ដើមបានមួយសន្ទុះ ស្រាប់តែ លោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិ បានចេញសេចក្ដីថ្លែងការណ៍មួយជាសាធារណៈ ដោយចាត់ទុកថ្ងៃទី២៨ ខែកក្កដា ជាទិវាប្រវត្តិសាស្ត្រដែលគណបក្សសង្គ្រោះជាតិ បានឈ្នះការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៥ ឆ្នាំ២០១៣។ គណបក្សនេះក៏បានថ្លែងអំណរគុណ ដល់ពលរដ្ឋដែលបានបោះឆ្នោតគាំទ្រឲ្យគណបក្សសង្គ្រោះជាតិ ឲ្យឈ្នះការបោះឆ្នោត។

នៅយប់ថ្ងៃទី២៨ ខែកក្កដា លោក សម រង្ស៊ី បានថ្លែងនៅក្នុងសន្និសីទកាសែតដោយចាត់ទុកការចេញសេចក្តីថ្លែងការណ៍ដំបូងរបស់ខ្លួនថា ជាការយល់ច្រឡំ និងចេញដោយច្រឡំ។ លោក សម រង្ស៊ី បញ្ជាក់ថា ការបោះឆ្នោតលើកនេះ គឺប្រជាពលរដ្ឋជាអ្នកឈ្នះ គឺជាជ័យជម្នះលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ដោយការបោះឆ្នោតនោះបានប្រព្រឹត្តទៅដោយមានការចូលរួមកុះករពីប្រជាពលរដ្ឋ អត់មានអំពើហិង្សា ហើយមានភាពចាស់ទុំខាងនយោបាយ។ ខណៈសមត្ថកិច្ចកម្លាំងប្រដាប់អាវុធជាច្រើន បានដាក់ពង្រាយនៅតាមផ្លូវ ហើយមហាវិថី និងវិថីសំខាន់ៗ បានដាក់បារ៉ាស់បិទមិនឲ្យធ្វើចរាចរណ៍។ ផ្លូវមួយចំនួនក្នុងក្រុងមានសភាពស្ងប់ស្ងាត់ ហើយពលរដ្ឋខ្លះបានសម្រុកចេញទៅក្រៅក្រុងភ្លាមៗ នៅពេលដែលមានព័ត៌មានធ្លាយថា គណបក្សសង្គ្រោះជាតិ ឈ្នះឆ្នោត។ សភាពតានតឹងនេះ បានធូរស្រាលឡើងវិញបន្តិច ដោយផ្លូវមួយចំនួនត្រូវបានចរាចរឡើងវិញ ហើយកម្លាំងសមត្ថកិច្ចក៏បានដកថយនៅពេលដែល លោក សម រង្ស៊ី ធ្វើសន្និសីទកាសែតយ៉ាងប្រញាប់ កែប្រែលើសេចក្តីថ្លែងការណ៍របស់ខ្លួនពីជ័យជម្នះលើការបោះឆ្នោត។ ស្របពេលដែល លោក ខៀវ កាញារីទ្ធ អ្នកនាំពាក្យរដ្ឋាភិបាល និងជារដ្ឋមន្ត្រីក្រសួងព័ត៌មានក៏បានចេញប្រកាសលទ្ធផលស្មានដំបូងលើបណ្តាញព័ត៌មានសង្គមហ្វេសប៊ុក(Facebook) បង្ហាញថា គណបក្សប្រជាជនកម្ពុជា បាន ៦៨កៅអី ហើយគណបក្សសង្គ្រោះជាតិ បាន ៥៥កៅអី។[៥៣]

នៅថ្ងៃទី២៩ កក្កដា គណបក្សសង្គ្រោះជាតិ ចេញសេចក្តីថ្លែងការណ៍ និងធ្វើសន្និសីទកាសែត បដិសេធមិនទទួលស្គាល់លទ្ធផលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ដែលប្រកាសដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប)។ លោក សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិបានអះអាងនៅក្នុងសន្និសីទសារព័ត៌មានមួយនៅព្រឹកថ្ងៃទី២៩ ខែកក្កដា ថា ការបោះឆ្នោតអាណត្តិទី៥ នេះមានភាពមិនប្រក្រតីជាច្រើនកើតឡើង ដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធផលបោះឆ្នោត។ ករណីទាំងនោះមានដូចជា ការបំប៉ោងសំឡេងឆ្នោត ការមានតែឈ្មោះតែមិនមានមនុស្ស ឬហៅថា ឈ្មោះខ្មោច និងការបង្កើតសន្លឹកឆ្នោតលើសតម្រូវការជាដើម។ លើសពីនេះទៅទៀត លោក សម រង្ស៊ី បានអះអាងថា ចាប់ពីពេលនេះតទៅគ្មានអ្នកដឹកនាំណា ឬគណបក្សនយោបាយណាអាចធ្វើអ្វីបានតាមចិត្តដោយមិនមានការយល់ព្រមពីគណបក្សប្រឆាំងនោះឡើយ៖ *«ចាប់ពីថ្ងៃនេះទៅ ចាប់ពីពេលនេះទៅ ការធ្វើសេចក្តីសម្រេចទាក់ទងនឹងអនាគតប្រទេសគឺត្រូវការមានការចូលរួមពីគណបក្សសង្គ្រោះជាតិ។ ស្មារតីយុត្តិធម៌ចំពោះប្រជារាស្ត្រ កាតព្វកិច្ចរបស់យើងចំពោះប្រជារាស្ត្រ កតញ្ញូតាធម៌របស់យើងចំពោះប្រជារាស្ត្រ គឺមិនអនុញ្ញាតឱ្យយើងទទួលស្គាល់លទ្ធផលដែលយើងឮមកទល់នឹងព្រឹកមិញនេះទេ»*។[៥៤]

(៥៣). ការផ្សាយរបស់វិទ្យុអាស៊ីសេរី ដោយទេព សុព៉ារី ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣

(៥៤). ការផ្សាយរបស់វិទ្យុអាស៊ីសេរី ដោយ យ៉ង ចាន់តារា និង ទីន ហ្សាការីយ៉ា ថ្ងៃទី២៩ កក្កដា ២០១៣

ទាក់ទងនឹងបញ្ហានេះ លោក ផៃ ស៊ីផាន អ្នកនាំពាក្យនៃទីស្តីការគណៈរដ្ឋមន្ត្រី បានលើកឡើងថា ការប្រកាសមិនទទួលយកលទ្ធផលរបស់គណបក្សសង្គ្រោះជាតិជាសិទ្ធិរបស់គេ ហើយសម្រាប់គណបក្សដែលឈ្នះនឹងរៀបចំខ្លួនសម្រាប់ការដឹកនាំប្រទេសទៅថ្ងៃមុខ៖ *«អ្នកដែលបាត់បង់ក្តី សង្ឃឹមដែលគាំទ្រគណបក្សហ្នឹងជាអ្នកខាតបង់។ ខាងយើងខ្ញុំជាអ្នកឈ្នះ យើងនឹងបង្គ្រប់នូវអ្វីដែលជាឆន្ទៈរបស់មហាជន អ្វីដែលជាលទ្ធផល ហើយយើងយកការទុកចិត្តហ្នឹង ធ្វើឱ្យទៅជាការងារ ដើម្បីផ្តល់សេវាកម្មប្រសើរដល់មហាជននិងសមិទ្ធផលថ្មីបន្ថែមទៀតដើម្បីជោគជ័យទាំងអស់គ្នា»*។

បើទោះជាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនទាន់បង្ហាញលទ្ធផលបឋមដែលកំណត់ចំនួនអាសនៈរបស់គណបក្សនយោបាយក៏ដោយ ក៏សេចក្តីប្រកាសព័ត៌មានស្តីពីលទ្ធផលបឋម និងមិនផ្លូវការនៃការបោះឆ្នោតរបស់អង្គការខុមហ្វ្រែល បានបង្ហាញថា គណបក្សប្រជាជនទទួលបាន ៦៧អាសនៈ គណបក្សសង្គ្រោះជាតិទទួលបាន ៥៦អាសនៈ ខណៈដែលគណបក្សផ្សេងៗទៀត មិនទទួលបានអាសនៈណាមួយឡើយ។ លទ្ធផលបណ្តោះអាសន្នរបស់ គ.ជ.ប នឹងត្រូវចេញផ្សាយយ៉ាងយូរបំផុតត្រឹមថ្ងៃទី១០ ខែសីហា ហើយបើមិនមានបណ្តឹងលទ្ធផលផ្លូវការអាចនឹងត្រូវប្រកាសនៅថ្ងៃទី១៤ សីហា តែបើមានបណ្តឹងនឹងត្រូវប្រកាសនៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៣ ខាងមុខ។[៥៥]

ជាមួយគ្នានោះនៅយប់ថ្ងៃទី២៩ ខែកក្កដា លោក សម រង្ស៊ី ប្រកាសសាជាថ្មីនៅចំពោះមុខក្រុមអ្នកគាំទ្ររបស់លោកជាច្រើននាក់នៅខាងមុខស្នាក់ការគណបក្សថា បក្សសង្គ្រោះជាតិ ឈ្នះឆ្នោត ហើយបើសិនជាបក្សកាន់អំណាច មិនព្រមទទួលស្គាល់លទ្ធផលទេ នោះនឹងមានមហាបាតុកម្មទ្រង់ទ្រាយធំនៅទូទាំងប្រទេសកើតឡើង។ ក្នុងវីដេអូឃ្លីប (Video Clip) ជិត ៨នាទី ដែលបង្ហោះតាមបណ្តាញព័ត៌មានសង្គមហ្វេសប៊ុក (Facebook) លោក សម រង្ស៊ី បានថ្លែងទៅកាន់អ្នកគាំទ្ររបស់ខ្លួន ដោយអំពាវនាវកុំជឿលើការផ្សព្វផ្សាយឃោសនាតួលេខនៃលទ្ធផលបោះឆ្នោតរបស់គណបក្សមួយទៀត ដែលទំនងជាសំដៅទៅលើគណបក្សប្រជាជនកម្ពុជា និងតួលេខនៃលទ្ធផលបោះឆ្នោតដែលផ្សាយដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ដោយបញ្ជាក់ថា តួលេខទាំងនោះមិនពិតទេ។ ចំណែកមន្ត្រីជាន់ខ្ពស់គណបក្សកាន់អំណាចចាត់ទុកគម្រោងធ្វើបាតុកម្មរបស់លោក សម រង្ស៊ី ថាជាទង្វើអ្នកនយោបាយដែលគ្មានការទទួលខុសត្រូវ និងមិនអនុវត្តច្បាប់ដែលមានចែងនៅក្នុងប្រទេស។

(៥៥).ការផ្សាយរបស់វិទ្យុអាស៊ីសេរី ដោយ យ៉ង ចាន់តារា និង ទីន ហ្សាការីយ៉ា ថ្ងៃទី២៩ កក្កដា ២០១៣

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានព្រមានចំពោះគម្រោងធ្វើបាតុកម្មទាំងឡាយណាដែលប្រឆាំងនឹងលទ្ធផលឆ្នោត។ លោកបានគម្រាមប្រើវិធីមានបាតុកម្មគាំទ្រ ប្រឆាំងបាតុកម្មតវ៉ាទៀតផង។ ការប្រកាសរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បែបនេះក្រោយពីមេដឹកនាំគណបក្សសង្គ្រោះជាតិប្រកាសមិនទទួលស្គាល់លទ្ធផលបោះឆ្នោត ដោយសារគណបក្សនេះរកឃើញមានភាពមិនប្រក្រតីជាច្រើនករណីកើតឡើងនៅថ្ងៃបោះឆ្នោត ហើយថា បើពុំមានការដោះស្រាយណាមួយដែលធានានូវភាពត្រឹមត្រូវ យុត្តិធម៌ ដែលអាចទទួលយកបាននោះទេ នឹងមានការតវ៉ា ឬមហាបាតុកម្មទ្រង់ទ្រាយធំ ដើម្បីប្រឆាំងនឹងភាពមិនប្រក្រតី ឬការលួចបន្លំសន្លឹកឆ្នោត។ ភ្លាមនោះនៅថ្ងៃសុក្រ ទី២ សីហា អនុប្រធានគណបក្សសង្គ្រោះជាតិ លោក កឹម សុខា បានប្រតិកម្មទៅនឹងការអំពាវនាវរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នោះ។[៥៦]

ទាក់ទងបញ្ហានេះ មន្ត្រីសង្គមស៊ីវិល បានសម្តែងក្តីព្រួយបារម្ភចំពោះស្ថានការណ៍ក្រោយការបោះឆ្នោត ដោយខ្លាចកើតមានភាពចលាចល ឬអំពើហិង្សាណាមួយ ដែលពិបាកនឹងគ្រប់គ្រងស្ថានការណ៍នោះបាន បើទោះជាមានការអះអាងពី សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន យ៉ាងណាក៏ដោយចុះ។លោកបណ្ឌិតហង្ស ពុទ្ធា មានប្រសាសន៍ថា បើសិនជាមានកំសួលនៃការងើបឡើងពីមជ្ឈដ្ឋាននានាក្នុងប្រទេស ដើម្បីប្រឆាំងនឹងភាពមិនប្រក្រតីនៃលទ្ធផលឆ្នោត ហើយបើមានមួយក្រុមទៀតប្រឆាំងតប ដោយមានអ្នកនយោបាយឈរនៅពីក្រោយខ្នងនោះ អាចនឹងធ្វើឲ្យស្ថានការណ៍នយោបាយកាន់តែតានតឹង និងអាចមានភាពច្របូកច្របល់មួយក្នុងប្រទេស។[៥៧]

- **នាយករដ្ឋមន្ត្រីអះអាងថាអាចបង្កើតរដ្ឋាភិបាលដោយមិនត្រូវការបក្សប្រឆាំង**

បើទោះបីជាមេដឹកនាំបក្សប្រឆាំងនៅតែរក្សាជំហរធ្វើបាតុកម្មប្រឆាំងទៅនិងលទ្ធផលឆ្នោតដែលប្រកាសដោយ គ.ជ.ប ថាគណបក្សប្រជាជនកម្ពុជា ជាអ្នកឈ្នះដោយទទួលបាន៦៨ អាសនៈ ហើយគណបក្សសង្គ្រោះជាតិទទួលបាន៥៥ អាសនៈ។ លោក សម រង្ស៊ី បានចាត់ទុកជាលទ្ធផលមិនត្រឹមត្រូវ មានការលួចបន្លំ ហើយគណបក្សសង្គ្រោះជាតិជាឈ្នះ លទ្ធផលដែលគណបក្សប្រជាជនទទួលបាននោះជាលទ្ធផលបានមកពីការលួចបន្លំ។

យ៉ាងណាក៏ដោយចុះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រកាសថា គណបក្សប្រជាជនកម្ពុជាដែលទទួលបានអាសនៈច្រើននាំមុខក្នុងការបោះឆ្នោត នឹងអាចបង្កើតរដ្ឋាភិបាលដោយងាយ បើទោះបីជាគណបក្សសង្គ្រោះជាតិ ពហិការមិនចូលរួមកិច្ចប្រជុំសភាលើកដំបូងក៏ដោយ។ ថ្លែងនៅក្នុងពេលចុះជួបប្រជាពលរដ្ឋនៅក្នុងស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល នៅព្រឹកថ្ងៃទី២ ខែសីហា

(៥៦).ការផ្សាយរបស់វិទ្យុអាស៊ីសេរី ថ្ងៃទី០២ សីហា ២០១៣ ដោយ សេក បណ្ឌិត

(៥៧).ការផ្សាយរបស់វិទ្យុអាស៊ីសេរី ថ្ងៃទី០២ សីហា ២០១៣ ដោយ សេក បណ្ឌិត

សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន មាន ប្រសាសន៍ថា ការបង្កើតក្បាលម៉ាស៊ីនដឹកនាំប្រទេសទាំង រដ្ឋសភា និងរដ្ឋាភិបាល នឹងមិនជាប់គាំងឡើយ។ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន សម្អាងថា រដ្ឋធម្មនុញ្ញដែលបានឆ្លងកាត់វិសោធនកម្មជាច្រើនសារ និងនៅមានសុពលភាពក្នុងពេលបច្ចុប្បន្ន បានធានាថា គណបក្សដែលទទួលបានសំឡេងគាំទ្រដាច់ខាត អាចចាប់ផ្តើមកិច្ចប្រជុំសភាជាលើកដំបូងបាន ដោយពុំចាំបាច់ត្រូវការសំឡេង ២ភាគ៣ឡើយ។ ការអះអាងរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ធ្វើបន្ទាប់ពីមានការវែកញែកនៅក្នុងចំណោមអ្នកច្បាប់ និងមន្ត្រីនៃគណបក្សប្រឆាំង ដែលថា ការបង្កើតរដ្ឋាភិបាលថ្មីនៅក្រោយការបោះឆ្នោតអាណត្តិទី៥ នេះ អាចនឹងជាប់គាំង ក៏ដោយសារតែសភាពុំអាចបើកការប្រជុំលើកដំបូងរបស់ខ្លួនបាន។ លោក ហ៊ុន សែន បានជំរុញអោយគណបក្សប្រឆាំងត្រូវចូលរួមកិច្ចប្រជុំសភាទៅតាមការកោះហៅរបស់ព្រះមហាក្សត្រ។ អនុប្រធានគណបក្សសង្គ្រោះជាតិ លោក កឹម សុខា មានប្រសាសន៍ថា យ៉ាងណា រដ្ឋសភាត្រូវការវត្តមានសមាជិកទាំងអស់ដើម្បីដំណើរការកិច្ចប្រជុំលើកដំបូងរបស់ខ្លួន។ លោក កឹម សុខា បន្តថា ផ្លូវច្បាប់ គឺពុំមានចំណុចណាមួយដែលបញ្ជាក់ថា គេអាចដកហូតអាសនៈសមាជិកសភារបស់គណបក្សណាមួយឡើយ។ នៅក្នុងមាត្រា ៨២ថ្មីនៃរដ្ឋធម្មនុញ្ញ បានចែងថា រដ្ឋសភាបើកសម័យប្រជុំដំបូង ៦០ថ្ងៃយ៉ាងយូរ ក្រោយការបោះឆ្នោតតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។ រដ្ឋសភាត្រូវប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗត្រូវបោះឆ្នោតជ្រើសរើសដាច់ដោយឡែកពីគ្នានូវប្រធានអនុប្រធានរដ្ឋសភានិងសមាជិកទាំងអស់ នៃគណៈកម្មការនានារបស់រដ្ឋសភា ដោយមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ទាក់ទិននឹងទិដ្ឋភាពច្បាប់ក្រុមអង្គការមិនមែនរដ្ឋាភិបាលលើកឡើងថា គ្រប់ភាគីអាចបកស្រាយទៅតាមការយល់ឃើញរៀងៗខ្លួន ប៉ុន្តែត្រូវតម្កល់ផលប្រយោជន៍ជាតិ និងសំឡេងរបស់ពលរដ្ឋជាធំ។ ករណីនេះ អង្គការមិនមែនរដ្ឋាភិបាលអំពាវនាវអោយមានការសម្របសម្រួលដោះស្រាយបញ្ហាដោយសន្តិវិធី។[៥៨]

- **បក្សសង្គ្រោះជាតិប្រកាសរក្សាជំហរធ្វើមហាបាតុកម្មប្រឆាំងលទ្ធផលបោះឆ្នោត**

លោក សម រង្ស៊ី ថ្លែងនៅថ្ងៃទី៦ សីហា ថា លោកនឹងពុំមានជំនឿសោះឡើយចំពោះការរកយុត្តិធម៌របស់ គ.ជ.ប សម្រាប់គណបក្សសង្គ្រោះជាតិ ដែលលោកអះអាងថា បានឈ្នះការបោះឆ្នោតនៅក្នុងអាណត្តិទី៥នេះ។ លោក សម រង្ស៊ី បន្តថា យន្តការដែលនឹងត្រូវប្រើប្រាស់ដើម្បីដណ្តើមជ័យជម្នះនេះពីគណបក្សកាន់អំណាចរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន មកវិញ គឺត្រូវពឹងអន្តរជាតិ និងជម្រើសចុងក្រោយ គឺចលនាមហាបាតុកម្មប៉ុណ្ណោះ។ លោកគិតថា នេះជាទីចុងក្រោយសម្រាប់ស្រោចស្រង់ប្រទេសជាតិ

(៥៨). ការផ្សាយរបស់វិទ្យុអាស៊ីសេរី ថ្ងៃទី០២ សីហា ២០១៣ ដោយ សុ ជីវី

ហើយជំហរនេះនឹងមិនថយក្រោយឡើយ។[៥៩] ជាមួយគ្នានោះ លោក សម រង្ស៊ី ប្រធានគណបក្សសង្រ្គោះជាតិ បានដាក់លិខិតមួយទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិ ស្នើឲ្យអង្គការនេះបញ្ជូនអ្នកជំនាញមកកាន់ប្រទេសកម្ពុជា ដើម្បីធ្វើជាអ្នកសង្កេតការណ៍ស៊ើបអង្កេតភាពមិនប្រក្រតីក្នុងពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្រ្តអាណត្តិទី៥ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២៨ ខែកក្កដា កន្លងទៅ។លិខិតរបស់លោក សម រង្ស៊ី ចុះថ្ងៃទី៥ ខែសីហា តែចេញផ្សាយជាសាធារណៈនៅថ្ងៃទី៨ ខែសីហា ផ្ញើជូនលោក បាន គីមូន (Ban Ki-moon) អគ្គលេខាធិការអង្គការសហប្រជាជាតិ បានលើកឡើងថា ដំណើរការនៃការបោះឆ្នោតមិនត្រូវបានធ្វើឡើងក្នុងភាពសេរី និងត្រឹមត្រូវនោះទេ គឺដូចដែលអង្គការអន្តរជាតិ និងអង្គការក្នុងស្រុកដែលធ្វើការពាក់ព័ន្ធនឹងការបោះឆ្នោតបានរកឃើញ ហើយលោកបានបដិសេធចោលនូវលទ្ធផលនោះ។[៦០]

## ខ. គណបក្សសង្រ្គោះជាតិទាមទារឲ្យមានការបង្កើតគណៈកម្មការចម្រុះដើម្បីស៊ើបអង្កេត និងបោះឆ្នោតឡើងវិញ

បន្ទាប់ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានប្រកាសលទ្ធផលបោះឆ្នោតជ្រើសតាំងតំណាងរាស្រ្តនីតិកាលទី៥ គណបក្សសង្រ្គោះជាតិ បានចេញសេចក្តីថ្លែងការណ៍ និងធ្វើសន្និសីទកាសែត នៅថ្ងៃទី២៩ កក្កដា បដិសេធមិនទទួលស្គាល់លទ្ធផលឆ្នោតនិងទាមទារឲ្យមានការ បង្កើតនៅគណៈកម្មការចម្រុះស៊ើបអង្កេតមួយ។ នៅក្នុងសន្និសីទកាសែតនោះលោក កឹម សុខា បានលើកឡើងថា គណបក្សសង្រ្គោះជាតិស្នើឱ្យមានការបង្កើតគណៈកម្មការស៊ើបអង្កេតចម្រុះមួយ ដើម្បីអាចដោះស្រាយបញ្ហាទាំងឡាយទាក់ទងនឹងការបោះឆ្នោត។ គណៈកម្មការនោះត្រូវមានការចូលរួមពីគណបក្សប្រជាជនកម្ពុជា គណបក្សសង្រ្គោះជាតិ តំណាងអង្គការសហប្រជាជាតិ និងតំណាងអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិដែលធ្វើការងារពាក់ព័ន្ធនឹងការបោះឆ្នោតមិនមែនមានតែសមាសភាព គ.ជ.ប នោះទេ។ ជាមួយគ្នាផងដែរ ក្រុមមន្រ្តីអង្គការសង្គមស៊ីវិលប្រកាសគាំទ្រការបង្កើតគណៈកម្មការចម្រុះ ដើម្បីធ្វើការស៊ើបអង្កេតទៅលើភាពមិនប្រក្រតីនៃដំណើរការបោះឆ្នោតរបស់គណបក្សសង្រ្គោះជាតិ ប្រសិនបើគណៈកម្មការនោះ ត្រូវខាងអង្គការសង្គមស៊ីវិលយល់ឃើញថា ធ្វើឡើងដោយច្បាស់លាស់និងត្រឹមត្រូវ។ ក្រុមមន្រ្តីអង្គការសង្គមស៊ីវិលដែលរួមគ្នាឃ្លាំមើលការបោះឆ្នោត នៃបន្ទប់ស្ថានការណ៍ថ្ងៃបោះឆ្នោតឆ្នាំ២០១៣ ដែលរៀបចំឡើងដោយគណៈកម្មាធិការខុមហ្វ្រែល (Comfrel)បានឲ្យដឹងថា ពួកគាត់គាំទ្រឲ្យគណបក្សសង្រ្គោះជាតិ

(៥៩).ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី០៦ សីហា ២០១៣ ដោយម៉មមុនីរតន៍ និងឡេងម៉ាលី
(៦០).ការផ្សាយរបស់វិទ្យុអាស៊ីសេរី ថ្ងៃទី៨ សីហា ២០១៣ ដោយ ចេង ម៉េងជូ

បង្កើតគណៈកម្មការស៊ើបអង្កេតភាពមិនប្រក្រតីនៅថ្ងៃបោះឆ្នោត។ ប្រធានសមាគមសិទ្ធិមនុស្ស អាដហុក (Adhoc) និងជាប្រធានគណៈកម្មាធិការនាយកខុមហ្វ្រែល (Comfrel) លោក ធន សារ៉ាយ មានប្រសាសន៍នៅក្នុងសន្និសីទសារព័ត៌មាននៅបន្ទប់ស្ថានការណ៍ថ្ងៃបោះឆ្នោតឆ្នាំ២០១៣ នៅព្រឹកថ្ងៃទី២៩ កក្កដា ថា ករណីគណបក្សសង្គ្រោះជាតិ ប្រកាសមិនទទួលស្គាល់លទ្ធផលបោះឆ្នោតជារឿងរបស់គណបក្សសង្គ្រោះជាតិ ប៉ុន្តែករណីគណបក្សប្រឆាំងទាមទារឲ្យបង្កើតគណៈកម្មការចម្រុះស៊ើបអង្កេតភាពមិនប្រក្រតីនៃដំណើរការបោះឆ្នោតនេះ អង្គការសង្គមស៊ីវិលដែលជាសមាជិកនៃបន្ទប់ស្ថានការណ៍បោះឆ្នោតឆ្នាំ២០១៣យល់ស្រប។[៦១]

លោក សន ម៉ាក់ឃីនថូស (Sean McIntosh)មន្ត្រីកិច្ចការសាធារណៈនៃស្ថានទូតអាមេរិកប្រចាំកម្ពុជា នៅរសៀលថ្ងៃទី៣០ កក្កដា បានបង្ហាញពីទស្សនៈគាំទ្រដល់សំណើនេះ ក៏បានស្នើឱ្យមានការស៊ើបអង្កេតជុំវិញដំណើរការ និងលទ្ធផលបោះឆ្នោតដ៏ចម្រូងចម្រាសនេះដែរ។ ទាក់ទងនឹងបញ្ហានេះដែរ តំណាងជាន់ខ្ពស់នៃសហគមន៍អឺរ៉ុប អ្នកស្រី ខាតស្រ៊ីន អាសថុន (Catherine Ashton) បានចេញសេចក្តីថ្លែងការណ៍មួយបង្ហាញពីការសោកស្តាយចំពោះភាពមិនប្រក្រតីទាំងឡាយដែលកើតមានចំពោះការបោះឆ្នោត បើទោះបីជាសហគមន៍អឺរ៉ុបសាទរចំពោះភាពស្ងប់ស្ងាត់ និងសន្តិភាពនៅថ្ងៃបោះឆ្នោតក៏ដោយ។ ជាមួយគ្នានេះដែរ គណបក្សហ៊្វុនស៊ិនប៉ិច ដែលតាមលទ្ធផលបឋមបណ្តោះអាសន្នមិនទទួលបានអាសនៈនោះ ក៏បានចេញសេចក្តីថ្លែងការណ៍មួយគាំទ្រដល់ការបង្កើតគណៈកម្មការចម្រុះដែរ។ ខ្លឹមសារនៃសេចក្តីថ្លែងការណ៍នោះបានបញ្ជាក់ថា គណបក្សហ៊្វុនស៊ិនប៉ិចសូមប្រកាសនូវជំហរម៉ឺងម៉ាត់របស់ខ្លួន ទាមទារឱ្យបង្កើតគណៈកម្មការឯករាជ្យមួយ ដើម្បីត្រួតពិនិត្យភាពមិនប្រក្រតីដ៏ធ្ងន់ធ្ងរជាច្រើនក្នុងកិច្ចដំណើរការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៥ កន្លងមកនេះ។ ចំពោះការបង្កើតគណៈកម្មការចម្រុះនេះ លោក ទេព នីថា អគ្គលេខាធិការគណៈកម្មាធិការជាតិរៀបចំ ការបោះឆ្នោត (គ.ជ.ប) កន្លងមកបានលើកឡើងថា វាហួសពីសមត្ថភាពរបស់ គ.ជ.ប ដែលអាចសម្រេចបាន។[៦២]

ខណៈដែលមានការស្នើឱ្យមានការបង្កើតគណៈកម្មការចម្រុះមួយដើម្បីដោះស្រាយបញ្ហាទាំងឡាយ មិនទាន់បានទទួលការឆ្លើយតបពីខាង គ.ជ.ប នៅឡើយ ប៉ុន្តែសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានអះអាងថា លោកស្វាគមន៍ចំពោះការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ បើសិនជា គ.ជ.ប ពិនិត្យឃើញថា ជាការចាំបាច់។ ថ្លែងនៅក្នុងទស្សនកិច្ចពិនិត្យការដ្ឋានសង់ស្ពានអាកាសស្ទឹងមានជ័យ នៅរសៀលថ្ងៃទី៣១ កក្កដា សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានមានប្រសាសន៍ថា

(៦១). ការផ្សាយរបស់វិទ្យុអាស៊ីសេរី ថ្ងៃទី២៩ កក្កដា២០១៣ ដោយ យ៉ង ចាន់ដារា និង ទីន ហ្សាការីយ៉ា

(៦២).ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី៣០ កក្កដា ២០១៣ ដោយ យ៉ង ចាន់ដារ៉ា

*លោកស្វាគមន៍ចំពោះយន្តការដោះស្រាយបញ្ហាទាំងឡាយរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទាក់ទងនឹងដំណើរការ និងលទ្ធផលនៃការបោះឆ្នោត*។ លោកបានបញ្ជាក់ថា រាជរដ្ឋាភិបាល ពិសេសគណបក្សប្រជាជនកម្ពុជា គាំទ្រឱ្យមានការចូលរួមពីគណបក្សនយោបាយ និងសង្គមស៊ីវិល ហើយគណបក្សប្រជាជនកម្ពុជា បានត្រៀមខ្លួនរួចជាស្រេច ដើម្បីធ្វើការពិភាក្សានយោបាយក្នុងចំណោមគណបក្សដែលមានអាសនៈក្នុងសភា ហើយលោកបានសង្កត់ធ្ងន់ថា រាល់បញ្ហាទាំងឡាយដែលមាន គឺត្រូវតែមានការដោះស្រាយដោយភាគីខ្មែរគ្នាឯង មិនអាចឱ្យសហគមន៍អន្តរជាតិណាមកចូលរួមនៅក្នុងរឿងនេះទេ។[៦៣]ពាក់ព័ន្ធនឹងករណីខាងលើត្រូវបានប្រធានគណបក្សសង្គ្រោះជាតិ លោក សម រង្ស៊ី ស្វាគមន៍ចំពោះការឆ្លើយតបរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន លើសំណើបង្កើតគណៈកម្មការចម្រុះ ដើម្បីអង្កេតពីភាពមិនប្រក្រតីក្នុងដំណើរការបោះឆ្នោតសភាកាលពីថ្ងៃទី២៨ ខែកក្កដា។[៦៤]ទាក់ទិនបញ្ហានេះ លោក កែម ឡី អ្នកស្រាវជ្រាវការអភិវឌ្ឍសង្គម និងជាអ្នកវិភាគឯករាជ្យ មើលឃើញថា ភាពមិនប្រក្រតីដែលកើតមានក្នុងដំណើរការបោះឆ្នោត គួរតែផ្អែកពាក់ព័ន្ធ មានសង្គមស៊ីវិល គណបក្សនយោបាយ ឬ គ.ជ.ប ជាដើម ចូលរួមដោះស្រាយឲ្យបានត្រឹមត្រូវ ដើម្បីឲ្យពលរដ្ឋស្ងប់អារម្មណ៍ និងអាចទទួលយកបាន៖ *«សម្តេចនាយករដ្ឋមន្ត្រីគាត់ប្រកាសហ្នឹង គឺប្រាកដជាមានហើយ។ ទោះបីជាយើងសម្របសម្រួល កែតម្រូវលក្ខណៈបច្ចេកទេសហើយ ក៏ត្រូវតែមានការសម្របសម្រួលខាងផ្នែកនយោបាយដែរ។ ហើយខ្ញុំគិតថា ជាសញ្ញាល្អសម្រាប់ស្រុកខ្មែរ អាចរក្សាស្ថិរភាពសង្គមផង អាចរក្សាស្ថិរភាពនយោបាយសេដ្ឋកិច្ចផង។ ប៉ុន្តែមិនអាចផ្តល់យុត្តិធម៌ជូនប្រជាពលរដ្ឋទេ វាលែងតែយើងកែលំអភាពលម្អៀងខាងបច្ចេកទេសឲ្យអស់តាមដែលអាចធ្វើទៅបាន»*។[៦៥]

- **សង្គមស៊ីវិលស្វាគមន៍ជំហរបក្សប្រឆាំងបង្កើតគណៈកម្មការចម្រុះ**

ជំហរចុងក្រោយរបស់គណបក្សសង្គ្រោះជាតិ ត្រូវបានស្វាគមន៍ដោយក្រុមមន្ត្រីអង្គការសង្គមស៊ីវិល និងអ្នកវិភាគនយោបាយមួយចំនួន។ មន្ត្រីទាំងនោះចង់ឲ្យបញ្ចប់វប្បធម៌បែងចែកអំណាចនៅកម្ពុជាព្រោះថា បទពិសោធន៍កន្លងមក វាមិនបានផ្តល់អត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋឡើយ។សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីថ្ងៃទី៣១ ខែកក្កដា ស្នើឲ្យមានកិច្ចពិភាក្សាមួយរវាងមន្ត្រីគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ដើម្បីជជែកបែងចែកអំណាចនៅក្នុងរដ្ឋសភា។ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន អះអាងថា *ការបែងចែកអំណាចក្នុងរដ្ឋសភានេះ ដើម្បីជៀសវាងភាពទាល់ច្រកនយោបាយក្រោយការប្រកាសលទ្ធផលបោះឆ្នោត ប៉ុន្តែលោក*

(៦៣).ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី៣១ កក្កដា ២០១៣ ដោយ យ៉ង ចាន់ដារ៉ា

(៦៤), (៦៥). ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី០១ សីហា ២០១៣ ដោយ ដែន អយុធ្យា

*ទាមទារធ្វើនាយករដ្ឋមន្ត្រីបន្តទៀត ដោយអះអាងថា គណបក្សប្រជាជន ជាអ្នកឈ្នះឆ្នោត។* ឆ្លើយតបទៅនឹងការលើកឡើងរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន មន្ត្រីនាំពាក្យគណបក្សសង្គ្រោះជាតិ លោក យឹម សុវណ្ណ បង្ហាញជំហរថា គណបក្សសង្គ្រោះជាតិ មិនចាប់អារម្មណ៍នឹងការផ្តួចផ្តើមបង្កើតក្រុមការងារនឹងគណបក្សប្រជាជនកម្ពុជា ដើម្បីជជែកបញ្ហាបែងចែកអំណាចឡើយ។ គណបក្សសង្គ្រោះជាតិ ចង់ឲ្យមានការស៊ើបអង្កេតភាពមិនប្រក្រតីនៃការបោះឆ្នោត។ ទោះបីជាយ៉ាងណាក៏ដោយ លោក យឹម សុវណ្ណ បន្ថែមទៀតថា លទ្ធផលនៃការបោះឆ្នោតដែលពលរដ្ឋផ្តល់ជូនគណបក្សសង្គ្រោះជាតិ នឹងអនុញ្ញាតឲ្យគណបក្សនេះដើរតួនាទីយ៉ាងសំខាន់ក្នុងការបម្រើពលរដ្ឋ៖ *«ជំនាន់ដែលហ៊ុនស៊ិនប៊ិច តើឈរមូលដ្ឋានអ្វី? គណបក្សសង្គ្រោះជាតិ បានសំឡេងឡើងដល់កម្រិតមួយដែលគណបក្សប្រជាជនកម្ពុជា មិនអាចមើលរំលងបាន»*។ ចំពោះការលើកឡើងផ្ទុយគ្នារបស់ភាគីបក្សទាំងពីរ ត្រូវបានអ្នកវិភាគឯករាជ្យលោកបណ្ឌិត ឡៅ ម៉ុងហៃ មានប្រសាសន៍ថា គណបក្សនយោបាយនៅកម្ពុជា គួរបញ្ចប់វប្បធម៌បែងចែកអំណាចនៅកម្ពុជា។ លោកបន្តថា កម្ពុជាមិនអាចជួបភាពទាល់ច្រកនយោបាយណាមួយឡើយ ប្រសិនបើគណៈកម្មការឯករាជ្យមួយត្រូវបានបង្កើតឡើង ដើម្បីស៊ើបអង្កេតលទ្ធផលបោះឆ្នោត។[៦៦]

របាយការណ៍បណ្តោះអាសន្នបង្ហាញដោយអង្គការសង្គមស៊ីវិល បង្ហាញថា គណបក្សប្រជាជនកម្ពុជា ឈ្នះ ៦៧អាសនៈ ចំណែកគណបក្សសង្គ្រោះជាតិ ឈ្នះ ៥៦អាសនៈ។ ប៉ុន្តែ គណបក្សប្រជាជនកម្ពុជា អះអាងដោយខ្លួនឯងថា ឈ្នះឆ្នោត ៦៨អាសនៈ ហើយចំពោះគណបក្សសង្គ្រោះជាតិ វិញ អះអាងថា ឈ្នះបាន ៦៣អាសនៈ។ តាមលទ្ធផលបណ្តោះអាសន្នប្រកាសដោយអង្គការសង្គមស៊ីវិល បង្ហាញថា គណបក្សប្រជាជនកម្ពុជា ពិតជាត្រូវការគណបក្សសង្គ្រោះជាតិ ដើម្បីអាចបើកសភាពេញអង្គនៃនីតិកាលទី៥ ខាងមុខ។ មាត្រា ៨៨ ចែងថា ការប្រជុំរដ្ឋសភា នឹងយកជាការបាន លុះត្រាតែមានកូរ៉ុមលើសពីពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល សម្រាប់ការអនុម័តទាំងឡាយណាដែលតម្រូវឲ្យយកមតិភាគច្រើន ពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល។[៦៧]

- **យូមែន រ៉ៃថ៍ វ៉ច្ឆ(Human Rigth Watch) ទាមទារបង្កើតគណៈកម្មការស៊ើបអង្កេតភាពមិនប្រក្រតី**

នៅក្នុងរបាយការណ៍ស៊ើបអង្កេតដែលចេញផ្សាយនៅក្នុងថ្ងៃ៣១ ខែកក្កដា នេះដែរ បានឲ្យរដ្ឋាភិបាលអនុញ្ញាតឲ្យមានសង្គមស៊ីវិលឯករាជ្យ និងម្ចាស់ជំនួយ ស៊ើបអង្កេតពីភាពមិនប្រក្រតីក្នុងប្រតិបត្តិតំបន់អាស៊ីនៃអង្គការឃ្លាំមើលសិទ្ធិមនុស្ស យូមែន រ៉ៃថ៍ វ៉ច្ឆ លោក ប្រែដ អាដាម

(៦៦),(៦៧).ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី០២ សីហា ២០១៣ ដោយ យន់ សាមៀន

បានទាមទារដំណើរការបោះឆ្នោតនៅកម្ពុជា ដើម្បីជឿជាក់បានថា ការបោះឆ្នោតនឹងប្រព្រឹត្តទៅតាមច្បាប់ និងឈានទៅបង្កើតរដ្ឋាភិបាលថ្មីនាពេលខាងមុខ។ ឆ្លើយតបនឹងការលើកឡើងបែបនេះ អគ្គលេខាធិការ គណៈកម្មាធិការរៀបចំការបោះឆ្នោត (គ.ជ.ប) លោក ទេព នីថា មានប្រសាសន៍ថា ចំពោះសំណើរៀបចំអង្គភាពស៊ើបអង្កេតឯករាជ្យមួយដើម្បីអង្កេតទៅលើភាពមិនប្រក្រតីណាមួយ ទាក់ទងនឹងដំណើរការបោះឆ្នោតនោះ គ.ជ.ប នឹងប្រជុំពិភាក្សាសម្រេចនៅល្ងាចថ្ងៃទី៣១ ខែកក្កដា ហើយនឹងប្រកាសឲ្យដឹងនៅថ្ងៃទី១ ខែសីហា។[៦៨]

- **គ.ជ.ប បដិសេធ**

មន្ត្រីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) និងមន្ត្រីរដ្ឋាភិបាល ប្រកាសច្រានចោលរបាយការណ៍អង្កេតរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស យូមែន រ៉ៃថ៍ វ៉ច្ឆ(HRW) នេះ។ អគ្គលេខាធិការ គ.ជ.ប លោក ទេព នីថា មានប្រសាសន៍ថា គ.ជ.ប មិនអាចទទួលយកបានទេនូវអ្វីដែលបានលើកឡើងថា គ.ជ.ប អាចជាប់ពាក់ព័ន្ធនឹងគណបក្សកាន់អំណាចក្នុងការបន្លំសន្លឹកឆ្នោតនោះ ហើយរាល់ចំណុចអសកម្មទាំងឡាយ គ.ជ.ប នឹងដោះស្រាយតាមពាក្យបណ្ដឹងពីពលរដ្ឋប៉ុណ្ណោះ មិនមែនដោះស្រាយតាមរបាយការណ៍របស់ យូមែន រ៉ៃថ៍ វ៉ច្ឆ ទេ។[៦៩]

- **ការបង្កើតគណៈកម្មការស៊ើបអង្កេតរឿងបោះឆ្នោតត្រូវបរាជ័យ**

កិច្ចប្រជុំរវាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាមួយតំណាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ដើម្បីពិភាក្សាអំពីអាណត្តិតួនាទី និងភារកិច្ចរបស់គណៈកម្មការពិសេសនៅថ្ងៃទី៤ ខែសីហា ត្រូវបានលើកពេលដោយគ្មានថ្ងៃកំណត់។ ការលើកពេលនោះ ធ្វើឡើងបន្ទាប់ពីគណបក្សសង្គ្រោះជាតិ បដិសេធមិនចូលរួមកិច្ចប្រជុំ ដោយអះអាងថា សមាសភាពនៃគណៈកម្មការចំពោះកិច្ចដែលបានស្នើឡើងមានលក្ខណៈចង្អៀតនិងផ្ទុយពីគោលបំណងរបស់គណបក្សសង្គ្រោះជាតិ បន្ទាប់ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានច្រានចោលសំណើរបស់គណបក្សសង្គ្រោះជាតិ ដែលសុំឲ្យមានការដាក់បញ្ចូលសមាសភាពអង្គការសហប្រជាជាតិជាអាជ្ញាកណ្ដាល។[៧០] ជាមួយគ្នានោះដែរ លោក ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃយល់ថា ការស្នើសុំរបស់គណបក្សសង្គ្រោះជាតិ ប្រហែលជាមិនអាចទៅរួចទេ

---

(៦៨),(៦៩). ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី៣១ កក្កដា ២០១៣ ដោយ ចេង ម៉េងជូរ និង វណ្ណ វិចារ

(៧០). ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី០៤ សីហា ២០១៣ ដោយ ទេព សុភាវី

ព្រោះនេះជាយន្តការមួយបង្កើតឡើងដោយច្បាប់។[៧១]

## ២. ដំណោះស្រាយនយោបាយ

នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៣ ព្រះមហាក្សត្របានចេញព្រះរាជសារដោយអំពាវនាវឲ្យគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ដែលពលរដ្ឋបានបោះឆ្នោតគាំទ្រឲ្យមានអាសនៈក្នុងរដ្ឋសភានីតិកាលទី៥ បន្តពិភាក្សាគ្នារកដំណោះស្រាយដោយសន្តិវិធីចំពោះវិវាទ ឬបញ្ហាទាំងឡាយដែលនៅសេសសល់។[៧២]

### ២.១ កិច្ចព្រមព្រៀងនយោបាយថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤

ក្រោយពីការប្រកាសលទ្ធផលបោះឆ្នោតបណ្តោះអាសន្នដែលចេញដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប)នៅថ្ងៃទី១២ សីហា បង្ហាញថា គណបក្សប្រជាជនកម្ពុជាទទួលបានសំឡេងគាំទ្រច្រើនជាងគណបក្សសង្គ្រោះជាតិ។ លទ្ធផលបានបង្ហាញថា គណបក្សប្រជាជនកម្ពុជាបានសំឡេងគាំទ្រចំនួនជាង ៣លានសំឡេង (៣.២៣៥.៩៦៩) ឈ្នះដាច់គណបក្សសង្គ្រោះជាតិដែលមានសំឡេងគាំទ្រជាង ២លានសំឡេង (២.៩៤៦.១៧៦)។[៧៣] ភ្លាមៗនោះផងដែរមេដឹកនាំគណបក្ស សង្គ្រោះជាតិប្រកាសថា លទ្ធផលឆ្នោតពិតប្រាកដត្រឹមត្រូវ គឺគណបក្សនេះឈ្នះគណបក្សប្រជាជនកម្ពុជា បើសិនជា គ.ជ.ប មានជំហរឯករាជ្យ និងយុត្តិធម៌នោះ។ ហើយគណបក្សសង្គ្រោះជាតិ រកឃើញថា គណបក្សខ្លួនអាចទទួលបានសំឡេងឆ្នោតយ៉ាងតិច ៦៣កៅអី ឈ្នះគណបក្សប្រជាជនកម្ពុជា។ ក៏ប៉ុន្តែសង្គមស៊ីវិលដែលធ្វើការពាក់ព័ន្ធនឹងការបោះឆ្នោត បានស្រង់យកសំឡេងឆ្នោតបណ្តោះអាសន្នដែលប្រកាសដោយគ.ជ.ប នោះ យកទៅគណនារកចំនួនអាសនៈឃើញថា គណបក្សប្រជាជនកម្ពុជា ទទួលបាន ៦៨កៅអី គណបក្សសង្គ្រោះជាតិ បាន៥៥កៅអី។ ចំនួននេះ ដូចគ្នានឹងការប្រកាសក្រៅផ្លូវការរបស់គណបក្សប្រជាជនកម្ពុជា កាលពីថ្ងៃទី២៨ កក្កដា គឺនៅក្រោយបោះឆ្នោតចប់ភ្លាមៗ ហើយថា លទ្ធផលនោះនឹងគ្មានការផ្លាស់ប្តូរទេ។[៧៤] បក្សប្រឆាំងនៅតែរក្សាជំហរមិនទទួលយកលទ្ធផលដែលប្រកាសដោយ គ.ជ.ប ហើយអះអាងថាបក្សខ្លួនជាអ្នកឈ្នះការបោះឆ្នោតទទួលបាន ៦៣ អាសនៈ ចំណែកបក្សប្រជាជនទទួលយកលទ្ធផលដែលបានប្រកាសដោយ គ.ជ.ប ។ កម្តៅនយោបាយនៅតែបន្ត ស្របពេលដែលបក្សប្រឆាំងរក្សាជំហរប្រមូលផ្តុំអ្នកគាំទ្ររបស់ខ្លួនដើម្បីធ្វើបាតុកម្មប្រឆាំងលទ្ធផលឆ្នោត។

---

(៧២).ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី០៧ សីហា ២០១៣ ដោយ កេសរណ្ណ័យ្យា

(៧៣). ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី០២ សីហា ២០១៣ ដោយ ទេព សុភ័ាវី និង ដែន អយុធ្យា

(៧៤). ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី១៦ សីហា ២០១៣ ដោយ សេក បណ្ឌិត និង អ៊ូន ឈិន

នៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៣ ក្រុមការងាររបស់គណបក្សសង្គ្រោះជាតិ និងគណបក្សប្រជាជនកម្ពុជា បានជួបប្រជុំគ្នានៅមន្ទីររដ្ឋសភាដើម្បីរួមគ្នាបង្កើតគណៈកម្មការត្រួតពិនិត្យពីភាពមិនប្រក្រតីនៃការបោះឆ្នោតជាតិ ប៉ុន្តែកិច្ចប្រជុំនេះមិនមានលទ្ធផលទេ។ ក្រោយមកនៅល្ងាចថ្ងៃទី២០ សីហា នៅមន្ទីររដ្ឋសភា ជំនួបរកដំណោះស្រាយពីភាពមិនប្រក្រតីនៃការបោះឆ្នោតសភាអាណត្តិទី៥ រវាងក្រុមកាងារ គណបក្សប្រជាជនកម្ពុជា ដឹកនាំដោយ លោក ព្រាំ សុខា និងគណបក្សសង្គ្រោះជាតិ ដឹកនាំដោយ លោក សុន ឆ័យ ដែលមានសមាជិកម្ខាងៗចំនួន ៥នាក់ បានជួបប្រជុំគ្នាជាលើកទី២ ត្រូវបរាជ័យ។[៧៥] ជំនួបលើកទី២ត្រូវបានបរាជ័យ គណបក្សសង្គ្រោះជាតិ ចាប់ផ្តើមធ្វើមហាបាតុកម្មអហិង្សារបស់ខ្លួន នៅព្រឹកថ្ងៃទី៧ ខែកញ្ញា ដូចការគ្រោងទុក ដែលមានប្រជាពលរដ្ឋនិងព្រះសង្ឃចូលរួមប្រមាណជាង ៣ម៉ឺននាក់ នៅទីលានប្រជាធិបតេយ្យ រាជធានីភ្នំពេញ។ ជាមួយគ្នានោះថ្នាក់ដឹកនាំគណបក្សប្រឆាំង ព្រមានថា បាតុកម្មនឹងមានជាបន្តបន្ទាប់ទៀត បើសិនពុំមានការបង្កើតគណៈកម្មការចម្រុះឯករាជ្យ ដើម្បីធ្វើការស៊ើបអង្កេត និងដោះស្រាយពីភាពមិនប្រក្រតីនៃការបោះឆ្នោតនោះទេ។[៧៦] ស្របពេលដែលមហាបាតុកម្មបក្សសង្គ្រោះជាតិកើតឡើង ពីរថ្ងៃក្រោយមក នៅថ្ងៃទី០៩ កញ្ញា សហរដ្ឋអាមេរិកអំពាវនាវដល់មេដឹកនាំគណបក្សធំៗពីដែលឈ្នះអាសនៈក្នុងការបោះឆ្នោតសភាអាណត្តិទី៥ ត្រូវបន្តជួបពិភាក្សាដើម្បីដោះស្រាយវិវាទបោះឆ្នោតឲ្យបានឆាប់ និងត្រូវតម្កល់ផលប្រយោជន៍ជាតិជាធំ។[៧៧]គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ បានកំណត់សមាសភាពមន្ត្រីបច្ចេកទេសចរចាម្ខាង ៥រូប ដើម្បីចូលរួមពិភាក្សាអំពីការកែទម្រង់ប្រព័ន្ធបោះឆ្នោត ដែលគ្រោងធ្វើនៅវិមានរដ្ឋសភា នៅថ្ងៃទី៥ ខែវិច្ឆិកា។ ការចរចាលើកនេះ ភាគីទាំងសងខាងសង្ឃឹមដូចគ្នាថា នឹងអាចទម្លុះភាពទាល់ច្រកផ្នែកនយោបាយ ហើយនឹងឈានទៅរកកិច្ចប្រជុំថ្នាក់ដឹកនាំកំពូលរវាងគណបក្សទាំងពីរ។ គណបក្សប្រជាជនកម្ពុជារួមមានលោក ព្រាំ សុខា ជាប្រធានក្រុម និងសមាជិក ៤រូបទៀតមានលោក សក់ សេដ្ឋា លោក កើត រិទ្ធលោក សំ សឿន និងលោក ម៉េង លី ចំណែកគណបក្សប្រជាជនកម្ពុជាមាន លោក សុន ឆ័យ ជាប្រធានក្រុម លោក គួយ ប៊ុនរឿន លោក អេង ឆៃអ៊ាង លោក យឹម សុវណ្ណ និងលោក យ៉ែម បុញ្ញឫទ្ធិ។[៧៨] ការចរចាគ្នារវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ កំពុងស្ថិតនៅភាពជាប់គាំងជាថ្មីទៀត ខណៈលោក កឹម សុខា អនុប្រធានគណបក្សសង្គ្រោះជាតិបានលើកឡើងថា គណបក្សសង្គ្រោះជាតិ ចង់ឲ្យមានការចរចាតែការចរចានោះ គឺគណបក្សប្រជាជនកម្ពុជា ត្រូវទទួលយកសំណើ ឬរបៀបវារៈរបស់

---

(៧៥).ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី២០ សីហា ២០១៣ ដោយ ដែន អយុធ្យា

(៧៦). ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី០៧ កញ្ញា ២០១៣

(៧៧). ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី០៩ កញ្ញញា ២០១៣ ដោយ ដែន អយុធ្យា

(៧៨).ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី០៣ វិច្ឆិកា ២០១៣ ដោយ ទេព សុរ៉ាវី

គណបក្សសង្គ្រោះជាតិ អំពីការស៊ើបអង្កេតលទ្ធផលបោះឆ្នោត។ បើមិនដូច្នោះទេ គណបក្សសង្គ្រោះជាតិ មិនព្រមចូលចរចានោះឡើយ ហើយគណបក្សសង្គ្រោះជាតិ នឹងដឹកនាំធ្វើកូដកម្មនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៣ ។[៧៩]

- **បក្សប្រឆាំងបញ្ជាក់ជំហរធ្វើបាតុកម្មរហូតវិបត្តិនយោបាយត្រូវបានដោះស្រាយ**

នៅក្នុងសេចក្ដីថ្លែងការណ៍របស់គណបក្សប្រឆាំង បានបង្ហាញថា មហាបាតុកម្មអហិង្សាដឹកនាំដោយគណបក្សសង្គ្រោះជាតិ រយៈពេលប៉ុន្មានថ្ងៃចុងក្រោយនេះ ចំនួនបាតុករបានកើនឡើងជាលំដាប់ រហូតដល់ប្រមាណ ៥សែននាក់ ហើយមហាបាតុកម្មនេះ បានប្រព្រឹត្តទៅដោយអហិង្សាសន្តិវិធី និងដោយមានសណ្ដាប់ធ្នាប់របៀបរៀបរយល្អ។ គណបក្សសង្គ្រោះជាតិ បញ្ជាក់ក្នុងលិខិតពីភាពជោគជ័យដ៏ធំធេងដែលកើតចេញពីឆន្ទៈដ៏មោះមុតរបស់ពលរដ្ឋ ដើម្បីទាមទារឲ្យមានការកែទម្រង់ប្រព័ន្ធបោះឆ្នោត និងទាមទារឲ្យមានការបោះឆ្នោតឡើងវិញ។ ជាពិសេស គណបក្សសង្គ្រោះជាតិបញ្ជាក់ជំហរបង្ហាញកម្លាំងធ្វើបាតុកម្មរហូតដល់វិបត្តិនយោបាយបានដោះស្រាយរួច។[៨០]ជាមួយនឹងគម្រោងធ្វើមហាបាតុកម្មនោះ អនុប្រធានគណបក្សសង្គ្រោះជាតិ លោក កឹម សុខា បានប្រកាសនៅថ្ងៃរសៀលថ្ងៃទី២ មករា លុបចោលជំនួបចរចាជាមួយគណបក្សប្រជាជនកម្ពុជា ដែលមានគម្រោងជួបគ្នានៅថ្ងៃទី៣ ខែមករា។ មហាបាតុកម្មរបស់បក្សប្រឆាំងត្រូវបានបរាជ័យទាំងស្រុងបន្ទាប់ពីកងកម្លាំងអាជ្ញាធររបស់រដ្ឋាភិបាលបង្ក្រាបបាតុកររបស់គណបក្សសង្គ្រោះជាតិ នៅទីលានប្រជាធិបតេយ្យ នៅថ្ងៃទី៤ ខែមករា និងហាមមិនឱ្យមានបាតុកម្មទៀតនោះ ក្រោយ ១ថ្ងៃនៃការបាញ់បង្ក្រាបពីកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋាភិបាលកាលពីថ្ងៃទី៣ ខែមករា នៅតាមផ្លូវវេងស្រេង រាជធានីភ្នំពេញ ដែលបណ្ដាលឲ្យកម្មករចំនួន ៥នាក់បានស្លាប់ និងរបួសជាង ៣០នាក់។ វិបត្តិនយោបាយដែលឈានរហូតដល់មានការបាញ់សម្លាប់ប្រជាពលរដ្ឋកម្មករខណៈចលនាទាមទារតម្លើងប្រាក់ខែរបស់កម្មករមានការកើតឡើងស្របពេលជាមួយមហាបាតុកម្មបក្សប្រឆាំងត្រូវបានប្រធានកិត្តិយសគណបក្សប្រជាជនកម្ពុជា និងជាប្រធានរដ្ឋសភាសម្ដេច ហេង សំរិនមានប្រសាសន៍ថាសកម្មភាពប្រទូស្ដរ៉ាយទាំងឡាយ គឺបង្កឡើងដោយបក្សប្រឆាំង ដែលធ្វើឲ្យប៉ះពាល់លទ្ធិប្រជាធិបតេយ្យ។[៨១]

(៧៩). ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី២១ វិច្ឆិកា ២០១៣ ដោយ ទីន ហ្សាការីយ៉ា

(៨០).ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី៣០ ធ្នូ ២០១៣ ដោយ ទេព សុវ៉ាវី

(៨១). ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី៧ មករា ២០១៤ ដោយ វណ្ណ វិចារ

- **ការចាប់ខ្លួនបេក្ខជនតំណាងរាស្ត្របក្សប្រឆាំង និងសកម្មជនបក្ស**

នៅព្រឹកថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤ រដ្ឋាភិបាលព័ទ្ធពង្រាយបន្លាលួសជុំវិញទីលានប្រជាធិបតេយ្យខណៈប្រធានបក្សសង្គ្រោះជាតិ លោក សម រង្ស៊ី ជិះឡានកាត់នោះទៅដុតធូបនៅវត្តភ្នំ ហើយលោកប្រកាសទាមទារសុំឲ្យរដ្ឋាភិបាលបើកទីលានប្រជាធិបតេយ្យឡើងវិញ។[៨២]

ព្រឹត្តិការណ៍មួយបានកើតឡើងនាព្រឹកថ្ងៃទី១៥ ខែកក្កដា នៅពេលដែលបេក្ខជនតំណាងរាស្ត្របក្សប្រឆាំងព្យាយាមរំដោះទីលាននេះពីការហ៊ុមព័ទ្ធដោយសំណាញ់របងលួសបន្លារបស់អាជ្ញាធររដ្ឋាភិបាល។ អំពើហិង្សានោះ បានបណ្តាលឲ្យក្រុមសន្តិសុខសាលារាជធានីភ្នំពេញ និងសកម្មជនគាំទ្របក្សប្រឆាំងរាប់សិបនាក់រងរបួសធ្ងន់ស្រាលទាំងសងខាង។ បេក្ខជនតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ ៤នាក់ គឺ អ្នកស្រី មូរ សុខហួរ លោក ម៉ែន សថាវរិទ្ធ និងលោក កែវ ភីរម្យ ត្រូវអាជ្ញាធរចាប់ខ្លួននៅនឹងកន្លែងកើតហេតុ ពេលដឹកបេក្ខជនតំណាងរាស្ត្រ ៣នាក់ ទៅដល់ស្នងការនគរបាលរាជធានីភ្នំពេញ កងនគរបាលក៏បានចាប់ខ្លួន លោក ហូរ វ៉ាន់ មួយរូបទៀត។ ចំណែកមនុស្សរបួសវិញមានចំនួនជាង ៥០នាក់។ ក្នុងចំណោមអ្នករបួសជាង ៥០នាក់នោះ ភាគីកងសន្តិសុខអាជ្ញាធរមានចំនួន ៣៨នាក់ និងភាគីសកម្មជនគាំទ្រគណបក្សសង្គ្រោះជាតិ មានចំនួន ១៤នាក់។ នេះជាលទ្ធផលកើតឡើងក្រោយពេលមានអំពើហិង្សាវាយគ្នាដោយដំបងឈើ រវាងសកម្មជនគណបក្សសង្គ្រោះជាតិ និងកងសន្តិសុខការពារទីលានប្រជាធិបតេយ្យ។[៨៣] នៅយប់ថ្ងៃអង្គារ ទី១៥ ខែកក្កដា ព្រះរាជអាជ្ញាសាលាដំបូងរាជធានីភ្នំពេញ បានចោទប្រកាន់តំណាងរាស្ត្រជាប់ឆ្នោតគណបក្សសង្គ្រោះជាតិ ៤រូប ពីបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋតាមមាត្រា ៤៩៤ និង ៤៩៥។[៨៤] លោក រៀល ខេមរិន្ទ្រ ដែលសមត្ថកិច្ចទើបចាប់ខ្លួនពីខេត្តកំពង់ចាម និងជំនួយការផ្ទាល់លោកស្រី មូរ សុខហួរ លោក អឿន ណារិទ្ធ ត្រូវបានចាប់ខ្លួននៅបឹងត្របែក នៅម៉ោងជាង ១០ព្រឹក នៅថ្ងៃទី១៦ ខែកក្កដា ហើយបញ្ជូនទៅសាកសួរនៅតុលាការសាលាដំបូងរាជធានីភ្នំពេញ។នៅល្ងាចថ្ងៃទី១៦ ខែកក្កដា នោះផងដែរ ចៅក្រមបានសម្រេចបញ្ជូនខ្លួនបេក្ខជនតំណាងរាស្ត្រជាប់ឆ្នោតគណបក្សសង្គ្រោះជាតិទាំង ៥ រូបនិងជំនួយការផ្ទាល់លោកស្រី មូរ សុខហួរ ទៅឃុំខ្លួននៅគុកព្រៃស។[៨៥]នាថ្ងៃបន្ទាប់តំណាងរាស្ត្រជាប់ឆ្នោតគណបក្សសង្គ្រោះជាតិ ចំនួន ២រូបទៀត គឺលោក ឡុង រី និងលោកនុត រំដួល ត្រូវបានសមត្ថកិច្ចចាប់បញ្ជូនខ្លួនទៅកាន់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ នៅរសៀលថ្ងៃទី១៧ ខែកក្កដា។

(៨២).ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី៣០ មេសា ២០១៤ ដោយ រោហារ ជាតិ

(៨៣). ការផ្សាយរបស់វិទ្យុអាស៊ីសេរី ថ្ងៃទី១៥ កក្កដា២០១៤ ដោយ សេក បណ្ឌិត និង វណ្ណ វិចារ

(៨៤). ការផ្សាយរបស់វិទ្យុអាស៊ីសេរី ថ្ងៃទី១៥ កក្កដា ២០១៤ ដោយ យន់ សាមៀន

(៨៥).ការផ្សាយរបស់វិទ្យុអាស៊ីសេរី ថ្ងៃទី១៦ កក្កដា ២០១៤ដោយ សេក បណ្ឌិត ឡេង ម៉ាលី និង រោហារ ជាតិ

នៅព្រឹកថ្ងៃទី ១៨ លោក ឡុង រី និង លោក នុត រំដួល ត្រូវបានបញ្ជូនទៅឃុំខ្លួននៅគុកព្រៃស បន្ទាប់ពីចៅក្រមសាកសួរអស់រយៈពេលជាង ១ម៉ោង ពីករណីផ្ទុះហិង្សារវាងកងសន្តិសុខរបស់រដ្ឋាភិបាល និងក្រុមអ្នកគាំទ្របក្សប្រឆាំង នៅស្ពាននាគ ក្បែរទីលានប្រជាធិបតេយ្យកាលពីថ្ងៃទី ១៥ កក្កដា។[៨៦]

- **កិច្ចព្រមព្រៀងនយោបាយថ្ងៃទី២២ កក្កដា ២០១៤**

គណបក្សទាំងពីរបានបញ្ចប់បញ្ហាជម្លោះនយោបាយហើយនៅថ្ងៃទី២២ កក្កដា នេះ បន្ទាប់ពីអូសបន្លាយពេលជិត ១ឆ្នាំកន្លងមក។ ការព្រមព្រៀងគ្នារវាងថ្នាក់ដឹកនាំកំពូលក្នុងការចរចានេះ នៅបន្ទាប់បេក្ខជនតំណាងរាស្ត្រជាប់ឆ្នោតគណបក្សសង្គ្រោះជាតិ ចំនួន ៧នាក់ និងសកម្មជនមួយរូបទៀត ត្រូវតុលាការចាប់ខ្លួនដាក់ពន្ធនាគារ។[៨៧]

កិច្ចព្រមព្រៀងនេះធ្វើឡើងមិនបានប៉ុន្មានថ្ងៃក្រោយតុលាការក្រុងភ្នំពេញ បានចេញដីកាឃុំខ្លួនបេក្ខជនតំណាងរាស្ត្រទាំង៧រូប និងមន្ត្រីកិច្ចការសាធារណៈម្នាក់។ ជាមួយគ្នានោះនៅថ្ងៃទី១៩ ខែកក្កដា ថ្លែងនៅទៅកាន់សកម្មជននិងអ្នកគាំទ្ររាប់ពាន់នាក់ដែលចូលរួមស្វាគមន៍ដំណើរវិលត្រឡប់មកវិញលោក សម រង្ស៊ី ប្រកាសចរចាជាមួយថ្នាក់ដឹកនាំកំពូលបក្សប្រជាជនកម្ពុជា។ របៀបវារៈនៃកិច្ចចរចានោះ រួមមាន ការដោះលែងអ្នកតំណាងរាស្ត្រ និងសកម្មជនដែលកំពុងជាប់គុក សេរីភាពក្នុងការបញ្ចេញមតិតាមរយៈការបើកទីលានប្រជាធិបតេយ្យឡើងវិញ និងការកែទម្រង់ការបោះឆ្នោត។[៨៨] នៅវេលាម៉ោង៤ និង៤០នាទី ល្ងាចថ្ងៃទី២២ កក្កដា ដដែលនោះបេក្ខជនតំណាងរាស្ត្រជាប់ឆ្នោតគណបក្សសង្គ្រោះជាតិចំនួន ៧រូប និងសកម្មជនមួយរូបដែលជាប់ពន្ធនាគារព្រៃ ស មួយអាទិត្យមកហើយនោះត្រូវបានដោះលែងឱ្យនៅក្រៅឃុំ។[៨៩] សេចក្តីថ្លែងការណ៍រួមមាន ៧ចំណុច បានចេញផ្សាយជាសាធារណៈ ក្រោយពេលអ្នកដឹកនាំគណបក្សឈ្នះឆ្នោតទាំងពីរ បានជួបចរចាគ្នាជាង ៥ម៉ោង បង្ហាញថាគណបក្សទាំងពីរយល់ព្រមចូលធ្វើការជាមួយគ្នានៅក្នុងរដ្ឋសភា ដើម្បីដោះស្រាយបញ្ហានានា និងមានការបែងចែកតួនាទីឲ្យគណបក្សប្រឆាំងនៅក្នុងរដ្ឋសភាផង។ ថ្នាក់ដឹកនាំកំពូលនៃគណបក្សទាំងពីរ នឹងចូលគាល់ព្រះមហាក្សត្រនៅថ្ងៃទី២៤ កក្កដា ដើម្បីថ្វាយអំពីលទ្ធផលនៃការចរចានេះ បន្ទាប់មកបេក្ខជនតំណាងរាស្ត្រជាប់ឆ្នោតរបស់គណបក្សសង្គ្រោះជាតិ ទាំង ៥៥រូប នឹងចូលស្បថនៅក្នុងព្រះបរមរាជវាំង។[៩០]

(៨៦).ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី១៧ កក្កដា ២០១៤ ដោយ យាង សុជាមេត្តា

(៨៧). ការផ្សាយរបស់វិទ្យុអាស៊ីសេរី ថ្ងៃទី២២ កក្កដា ២០១៤ ដោយ ទីន ហ្សាការីយ៉ា

(៨៨). (ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី១៩ កក្កដា ២០១៤ ដោយ វណ្ណ វិចារ និង ឡេង ម៉ាលី

(៨៩). ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី២២ កក្កដា ២០១៤ ដោយ ឡេង ម៉ាលី

(៩០). ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី២២ កក្កដា ២០១៤ ដោយ ទីន ហ្សាការីយ៉ា

កិច្ចព្រមព្រៀងបន្ទាប់ពីចរចារវាងគណបក្សទាំងពីរនោះ មានចំនួន ៧ប្រការសំខាន់ៗ ក្នុងនោះរួមមាន សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មាន ៩រូប ក្នុងនោះ ៤រូបជ្រើសរើសដោយគណបក្សប្រជាជនកម្ពុជា និង៤រូបផ្សេងទៀត ជ្រើសរើសដោយគណបក្សសង្គ្រោះជាតិ ហើយសមាសភាព១ទៀត គឺត្រូវជ្រើសរើសដោយមានការព្រមព្រៀងគ្នារវាងគណបក្ស ដែលមានអាសនៈក្នុងរដ្ឋសភា។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានថវិកាស្វយ័តសម្រាប់ដំណើរការ។ ក្នុងករណីដែលខកខានមិនបានរៀបចំសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលមានស្រាប់ ត្រូវបន្តការងាររបស់ខ្លួន និងមានសមត្ថកិច្ចដើម្បីចាត់ចែងរៀបចំការបោះឆ្នោតតាមច្បាប់។ ចំពោះការរៀបចំក្បាលម៉ាស៊ីនរដ្ឋសភាវិញ ការបែងចែកតួនាទីដឹកនាំនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាតាមរូបមន្ត ៧ ទល់ ៦ ដោយត្រូវបង្កើតបន្ថែម គណៈកម្មការជំនាញថ្មីមួយទៀត ហើយមានសមាសភាពប្រធានសភាមកពីគណបក្សប្រជាជនកម្ពុជា អនុប្រធានទី១មកពីគណបក្ស សង្គ្រោះជាតិ និងអនុប្រធានសភាទី២ មកពីគណបក្សប្រជាជនកម្ពុជា។ គណៈកម្មការបង្កើតថ្មីជាគណៈកម្មការទី១០ មានឈ្មោះថា គណៈកម្មការអង្កេត បោសសម្អាត និងប្រឆាំងអំពើពុករលួយ ដោយបំបែកពីគណៈកម្មការទី៤ ហើយដូរឈ្មោះគណៈកម្មការទី៤ មកជាគណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ។ គណៈកម្មការដែលគណបក្សប្រជាជនកម្ពុជា ធ្វើជាប្រធាន និងធ្វើជាលេខាធិការ រួមមាន គណៈកម្មការទី២ គណៈកម្មការទី៤ គណៈកម្មការទី៥ គណៈកម្មការទី៦ និងគណៈកម្មការទី៩។ គណៈកម្មការដែលគណបក្សសង្គ្រោះជាតិ ធ្វើជាប្រធាន និងធ្វើជាលេខាធិការ រួមមាន គណៈកម្មការទី១ គណៈកម្មការទី៣ គណៈកម្មការទី៧ គណៈកម្មការទី៨ និង គណៈកម្មការទី១០។ គណៈកម្មការនីមួយៗមានសមាជិក ៩រូប ហើយគណៈកម្មការណាដែលគណបក្សណាធ្វើជាប្រធាន សមាជិកមកពីគណបក្សនោះមាន ៥រូប និងគណបក្សផ្សេងទៀត ៤រូប។ ចំពោះស្ថាប័នព្រឹទ្ធសភាវិញ គណបក្សទាំងពីរក៏ព្រមព្រៀងគ្នារៀបចំក្បាលម៉ាស៊ីនឡើងវិញដែរ។[៩១] ចំពោះកាលបរិច្ឆេទបោះឆ្នោតឃុំសង្កាត់ និងបោះឆ្នោតជាតិអាណត្តិទី៦ តំណាងគណបក្សប្រជាជនកម្ពុជា លោក ព្រុំ សុខាមានប្រសាសន៍ថា មិនមានការបោះឆ្នោតឡើងវិញ ចំពោះការបោះឆ្នោតអាណត្តិទី៥ តែគណបក្សទាំងពីរព្រមព្រៀងរៀបចំបញ្ជីឈ្មោះបោះឆ្នោតជាថ្មី និងរៀបចំការបោះឆ្នោតអាចថានៅមុនអាណត្តិសម្រាប់ការបោះឆ្នោតអាណត្តិទី៦ អាស្រ័យលើការរៀបចំបញ្ជីឈ្មោះឆ្នោតថ្មីរួចរាល់។ រីឯទីលានប្រជាធិបតេយ្យវិញលោក ព្រុំ សុខា លើកឡើងថា រដ្ឋាភិបាលនឹងបើកឡើងវិញនៅបន្ទាប់ពីបេក្ខជនតំណាងរាស្ត្រជាប់ឆ្នោត

(៩១). កិច្ចព្រមព្រៀងនយោបាយថ្ងៃទី២២ កក្កដា ២០១៤

គណបក្សសង្គ្រោះជាតិ ចូលស្បថក្នុងព្រះបរមរាជវាំង និងចូលប្រជុំសភានៅពេលឆាប់ៗខាងមុខនេះ។[៩២]

លោក ប្រ៊ែដ អាដាម (Brad Adams) នាយកប្រតិបត្តិទទួលបន្ទុកផ្នែកអាស៊ី នៃអង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ យូមែន រ៉ៃត៍ វ៉ច្ឆ(Human Rights Watch) និងជាអតីតមន្ត្រីច្បាប់នៃអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ឲ្យដឹងថា កិច្ចព្រមព្រៀងនយោបាយរវាងគណបក្សសង្គ្រោះជាតិ និងគណបក្សប្រជាជនកម្ពុជា កាលពីថ្ងៃទី២២ កក្កដា គឺជាកិច្ចព្រមព្រៀងមួយដែល អាក្រក់បំផុតនឹងមិនជួយឲ្យប្រទេសកម្ពុជា មានការបោះឆ្នោតប្រកបដោយសេរី យុត្តិធម៌ និងតម្លាភាព នៅថ្ងៃអនាគត ដូចដែលពលរដ្ឋកម្ពុជា ទន្ទឹងរង់ចាំចង់បាននោះឡើយ។ លោកបញ្ជាក់ថា រូបមន្តនៃការជ្រើសរើសសមាសភាព គ.ជ.ប ដែលបានព្រមព្រៀងគ្នា គឺគណបក្សប្រជាជនកម្ពុជាមានប្រៀបលើគណបក្សសង្គ្រោះជាតិ ដាច់។[៩៣]

## ២.២ ការឈានទៅដល់ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញដើម្បីដាក់ គ.ជ.ប ជាស្ថាប័នរដ្ឋធម្មនុញ្ញ

នៅក្នុងសេចក្តីព្រាងរបស់គណបក្សសង្គ្រោះជាតិ ផ្ញើទៅលោក ស ខេង កាលពីថ្ងៃទី៣០ ខែកក្កដា នោះ គឺគណបក្សសង្គ្រោះជាតិ ចង់ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ មាត្រា ៧៦ និងបង្កើតជំពូកទី ១៥ថ្មី នៃរដ្ឋធម្មនុញ្ញអំពីអង្គការរៀបចំការបោះឆ្នោត ក្នុងនោះទាមទារឲ្យសមាជិកកំពូល គ.ជ.ប មាន អភ័យឯកសិទ្ធិ មានថវិកាស្វ័យភាពរបស់ខ្លួនជាដើម។ នៅក្នុងលិខិតរបស់លោក ឧបនាយករដ្ឋមន្ត្រី ស ខេង ឆ្លើយតបទៅលោក សម រង្ស៊ី ជាប្រធានគណបក្សសង្គ្រោះជាតិវិញនោះ គឺយោងទៅលើសេចក្តីព្រាងរបស់គណបក្សប្រជាជនកម្ពុជា កាលពីថ្ងៃទី២២កក្កដា ដែលគណបក្សទាំងពីរធ្លាប់បានពិភាក្សាគ្នាហើយមិនត្រូវរ៉ូវគ្នានោះ។ នៅក្នុងសេចក្តីព្រាងរបស់គណបក្សប្រជាជនកម្ពុជាអំពីការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ មាត្រា៧៦នេះ មិន បានបញ្ជាក់អំពី សមាជិកគ.ជ.ប ដាក់ឲ្យមានអភ័យឯកសិទ្ធិនោះឡើយ និងមានករណីជាច្រើនទៀត ដែលខុសគ្នា។[៩៤]

នៅថ្ងៃទី១៨ ខែសីហា ក្រុមការងារវិសោធនកម្មច្បាប់បោះឆ្នោតរបស់គណបក្សសង្គ្រោះជាតិ និងគណបក្សប្រជាជនកម្ពុជា ឯកភាពគ្នាធ្វើសេចក្តីព្រាងច្បាប់ចំនួនពីរ ទី១ គឺការស្នើនិងធ្វើសេចក្តី

(៩២). ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី២២ កក្កដា ២០១៤ ដោយ ទីន ហ្សាការីយ៉ា
(៩៣). (ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី២៥ កក្កដា ២០១៤ ដោយ ជី វិតា
(៩៤). ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី១ សីហា ២០១៤ ដោយ ទីន ហ្សាការីយ៉ា

ព្រាងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំបោះឆ្នោត ទី២ សេក្តី ព្រាងស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត។ សេចក្តីព្រាងច្បាប់បោះឆ្នោតថ្មីនេះ មាន ១០ជំពូក ដោយ មិនទាន់ចែកចេញជាមាត្រាច្បាប់ឡើយ។[៩៥] ខណៈដែលបក្សទាំងពីរទើបចាប់ផ្តើមធ្វើការពិភាក្សាគ្នា លើច្បាប់បោះឆ្នោត នៅថ្ងៃទី២២ ខែសីហា ព្រឹទ្ធសភាជប៉ុន សន្យាថានឹងជួយធ្វើកំណែទម្រង់ការ បោះឆ្នោតនៅកម្ពុជា នៅក្នុងនីតិកាលទី៦ខាងមុខ ដើម្បីឲ្យការបោះឆ្នោតប្រកបដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដែលអាចទទួលយកគ្រប់ភាគី។[៩៦]

(៩៥). ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី១៨ សីហា ២០១៤ ដោយ វណ្ណ វិចារ

(៩៦). ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី ២២ សីហា២០១៤ ដោយ ទីន ហ្សាការីយ៉ា

# ជំពូកទី៣
# ស្ថាប័នជាតិរៀបចំការបោះឆ្នោតថ្មី ក្រោយកំណែទម្រង់

# ជំពូកទី ៣

# ស្ថាប័នជាតិរៀបចំការបោះឆ្នោតថ្មី ក្រោយកំណែទម្រង់

## ១. រចនាសម្ព័ន្ធរបស់ គ.ជ.ប

### ១.១ សមាសភាពសមាជិក គ.ជ.ប

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសមាសភាព ០៩ (ប្រាំបួន) រូប ដែលរួមមានៈ ប្រធាន ០១ (មួយ) រូប អនុប្រធាន ០១ (មួយ) រូប និងសមាជិក ០៧ (ប្រាំពីរ) រូប ។[៩៧] សមាសភាព ភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវជ្រើសរើស ក្នុងចំណោមឥស្សរជនខ្មែរទាំងពីរ ភេទ ដែលមានលក្ខណៈសម្បត្តដូចខាងក្រោមៈ

- មានសញ្ជាតិខ្មែរពីកំណើត និងមានសញ្ជាតិខ្មែតែមួយគត់ ក្នុងពេលបំពេញការងារនៅ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- មានអាយុយ៉ាងតិច៣៥ (សាមសិបប្រាំ) ឆ្នាំ គិតដល់ថ្ងៃតែងតាំង
- មានសិទ្ធិបោះឆ្នោត
- មានសញ្ញាបត្រចាប់ពីថ្នាក់ឧត្តមសិក្សាឡើងទៅ
- មានបទពិសោធន៍ការងារយ៉ាងតិច ១០ (ដប់ប្រាំ)ឆ្នាំ
- មិនត្រូវជាសហព័ទ្ធ ឬញាតិលោហិត ឬញាតិពន្ធរហូតដល់ថ្នាក់ទី៣ របស់ប្រធាន អនុប្រធាន គណបក្សនយោបាយ ដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត។[៩៨]

សមាសភាពប្រធាន អនុប្រធាន និងសមាជិក ទាំង ០៩(ប្រាំបួន) រូប នោះរួមមានៈ

| | |
|---|---|
| ១. ឯកឧត្តម សុិក ប៊ុនហុក | ប្រធាន |
| ២. ឯកឧត្តម គួយ ប៊ុនរឿន | អនុប្រធាន |
| ៣. ឯកឧត្តម មាន សទិ | សមាជិក |
| ៤. ឯកឧត្តម រ៉ុង ឈុន | សមាជិក |
| ៥. ឯកឧត្តម ឌុច សុន | សមាជិក |
| ៦. ឯកឧត្តម ហ៊ីង ធីឫទ្ធិ | សមាជិក |

(៩៧),(៩៨). មាត្រា ៤ មាត្រា៥ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឆ្នាំ២០១៥

៧. ឯកឧត្តម ឯម សូផាត សមាជិក
៨. ឯកឧត្តម ហង្ស ពុទ្ធា សមាជិក
៩. លោកជំទាវ តែ ម៉ានីរ៉ុង សមាជិកា

សមាសភាព ទាំង ០៩(ប្រាំបួន) រូប នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវជ្រើសរើសដោយ ៖ ០៤ (បួន) រូប ជ្រើសដោយគណបក្សដឹកនាំរដ្ឋាភិបាល ០៤(បួន) ជ្រើសរើសដោយគណបក្សដែលមានអាសនៈក្នុងរដ្ឋសភា ដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល និង ០១ (មួយ) រូប ទៀត ជ្រើសរើសដោយមានការព្រមព្រៀងគ្នារវាងគណបក្សទាំងអស់ដែលមានអាសនៈក្នុងរដ្ឋសភា ។

ផ្អែកតាមគោលការណ៍ខាងលើនេះ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ត្រូវធ្វើការសម្របសម្រួលជាមួយគណបក្សនយោបាយទាំងអស់ ដែលមានអាសនៈក្នុងរដ្ឋសភាដើម្បីប្រកាសជ្រើសរើសបេក្ខជនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាសាធារណៈ ប្រកបដោយលក្ខណៈបើកចំហរ និងតម្លាភាព ក្នុងរយៈពេលយ៉ាងតិច ១០(ដប់)ថ្ងៃ។ បន្ទាប់មកគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវសម្របសម្រួលជាមួយគណបក្សនយោបាយទាំងអស់ដែលមានអាសនៈក្នុងរដ្ឋសភាដើម្បីពិនិត្យជ្រើសរើសសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពីក្នុងចំណោមជនដែលបានដាក់ពាក្យស្នើសុំ ដោយផ្អែកតាមលក្ខណៈសម្បិត្ត ដូចមានចែងក្នុងមាត្រា៥ នៃច្បាប់នេះ។[៩៩]

ផ្អែកតាមសមាសភាពដែលបានជ្រើសរើសខាងលើនេះ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវរៀបចំបញ្ជីសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដាក់ជូនរដ្ឋសភា ដើម្បីបោះឆ្នោតទុកចិត្តតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ ប្រធាន អនុប្រធាន និងសមាជិក គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវតែងតាំងដោយព្រះរាជក្រឹត្យយ៉ាងយូរ ៦ (ប្រាំមួយ) ខែ បន្ទាប់ពីរដ្ឋសភាថ្មីចូលកាន់ដំណែង។ ប្រធាន អនុប្រធាន និងសមាជិក គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់តំណែង។[១០០]

ប្រធាន អនុប្រធាន និងសមាជិក គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានអាណត្តិ ៥ (ប្រាំ) ឆ្នាំ ហើយត្រូវផុតអាណត្តិនៅពេលសមាសភាពថ្មីចូលកាន់តំណែង ។[១០១] មុខងារជាប្រធាន អនុប្រធាន និងសមាជិក គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានវិសមិតភាពជាមួយការបំពេញមុខតំណែងក្នុងមុខងារសាធារណៈ និងជាមួយមុខងារជាសមាជិកនៃស្ថាប័នដ៏ទៃទៀត

(៩៩),(១០០),(១០១) មាត្រា ៧ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឆ្នាំ២០១៥

ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។ ប្រធាន អនុប្រធាន និងសមាជិក គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបានព្យួរសិទ្ធិជាបណ្ដោះអាសន្ន រហូតដល់ថ្ងៃបញ្ចប់មុខតំណែង ។

ប្រធាន អនុប្រធាន និងសមាជិក គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលជាសមាជិកនៃគណបក្សនយោបាយ ត្រូវសុំលាលែងពីគណបក្សនយោបាយ ហើយអាចចូលជាសមាជិកគណបក្សនយោបាយវិញ ក្នុងរយៈពេលយ៉ាងតិច ០២ (ពីរ) ឆ្នាំ បន្ទាប់ពីបញ្ចប់អាណត្តិការងារ ឬបាត់បង់មុខតំណែង ឬ ត្រូវបណ្ដេញចេញ ដូចមានចែងក្នុងមាត្រា ៧ មាត្រា ៩ និងមាត្រា ១០ នៃច្បាប់នេះ ។

ប្រធាន អនុប្រធាន និងសមាជិក គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលជាសមាជិកឬ/និងជាអ្នកដឹកនាំនៃអង្គការមិនមានរដ្ឋាភិបាល សមាគម សហជីព ឬ/និងក្រុមហ៊ុនពាណិជ្ជកម្ម ឬ/និងមន្ត្រីរាជការ ត្រូវសុំលាលែងពីអង្គការមិនមានរដ្ឋាភិបាល សមាគម សហជីព ឬ/និងក្រុមហ៊ុនពាណិជ្ជកម្ម ឬ/និងត្រូវដាក់ពាក្យសុំទៅបម្រើការងារនៅក្របខ័ណ្ឌដើម រហូតដល់ថ្ងៃចប់អាណត្តិ។[១០២]

ប្រធាន អនុប្រធាន និងសមាជិក គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបាត់បង់មុខតំណែងក្នុងករណីដូចខាងក្រោម ៖

- សាមីខ្លួន ទទួលមរណភាព
- សាមីខ្លួន សុំលាឈប់ជាលាយលក្ខណ៍អក្សរ
- សាមីខ្លួន សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច
- សាមីខ្លួន ត្រូវផ្ដន្ទាទោសឲ្យជាប់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ ។[១០៣]

ប្រធាន អនុប្រធាន និងសមាជិក គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវមានគណនេយ្យភាពចំពោះមុខរដ្ឋសភា។ ការសម្រេចចិត្តបណ្ដេញចេញពីប្រធាន ឬអនុប្រធាន ឬសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាសមត្ថកិច្ចរបស់រដ្ឋសភា។[១០៤] ក្នុងករណីដែលប្រធាន ឬអនុប្រធាន ឬសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបាត់បង់ពីមុខតំណែង គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវសម្របសម្រួលជាមួយគណបក្សនយោបាយពាក់ព័ន្ធ ដើម្បីប្រកាសជ្រើសរើសជាសាធារណៈ នូវបេក្ខភាពបេក្ខជនដែលត្រូវជំនួសមុខតំណែងដែលទំនេរ

(១០២),(១០៣ )(១០៤) .មាត្រា ៨ មាត្រា ៩ មាត្រា ១០ ច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រកបដោយលក្ខណៈបើកចំហរ និងតម្លាភាពក្នុងរយៈពេល០៥(ប្រាំ) ថ្ងៃ។ បន្ទាប់មកគណបក្សពាក់ព័ន្ធត្រូវជ្រើសរើសសមាសភាពថ្មីពីក្នុងចំណោមអ្នកដែលបានដាក់ពាក្យក្នុងរយៈពេលយ៉ាងតិច ០៣ (បី)ថ្ងៃ ដាក់ទៅគណៈកម្មាធិការធិការអចិន្ត្រៃយ៍រដ្ឋសភា ដើម្បីគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភារៀបចំដាក់សមាសភាពថ្មីនេះ ជូនរដ្ឋសភាបោះឆ្នោតទុកចិត្តតាមសម្លេងភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ ក្នុងករណីដែលមានការរៀបចំបោះឆ្នោត និងយ៉ាងយូរ០៥ (ប្រាំ) ក្នុងករណីដែលគ្មានការបោះឆ្នោត។

ករណីបក្សនយោបាយពាក់ព័ន្ធខកខានមិនបានជ្រើសរើសសមាសភាពថ្មីតាមការកំណត់ខាងលើគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាត្រូវធ្វើការជ្រើសរើសបេក្ខភាពបេក្ខជនដែលត្រូវជំនួសមុខតំណែងដែលទំនេរនោះ ដោយផ្អែកតាមលក្ខណៈសម្បត្តដូចមានចែងក្នុងមាត្រា៥ នៃច្បាប់នេះពីក្នុងចំណោមអ្នកដែលបានដាក់ពាក្យ ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ ប្រកបដោយលក្ខណៈបើកចំហរ និងមានតម្លាភាពក្នុងរយៈពេលយ៉ាងតិច០២ (ពីរ) ថ្ងៃ ដើម្បីដាក់ជូនរដ្ឋសភាបោះឆ្នោតទុកចិត្តតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ក្នុងរយៈពេលយ៉ាងយូរ០២(ពីរ) ថ្ងៃ ក្នុងករណីមានការបោះឆ្នោត និងយ៉ាងយូរ០៣(បី) ក្នុងករណីដែលគ្មានការបោះឆ្នោត។បែបបទនីតិវិធីនៃការដាក់ពាក្យ ការជ្រើសរើស និងការរៀបចំបញ្ជីបេក្ខជនដាក់ជូនរដ្ឋសភាត្រូវកំណត់ដោយគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ។[១០៥]

ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវមានឋានៈ និងបុព្វសិទ្ធិស្មើនិងឧបនាយករដ្ឋមន្ត្រី។ អនុប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវមានឋានៈ និងបុព្វសិទ្ធិស្មើនិងទេសរដ្ឋមន្ត្រី។ សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវមានឋានៈ និងបុព្វសិទ្ធិស្មើនិងរដ្ឋមន្ត្រី។[១០៦] ប្រធាន និងអនុប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលបានការធានាការពារសន្តិសុខ សុវត្ថិភាពផ្ទាល់ខ្លួន និងគ្រួសារ ក្នុងករណីចាំបាច់ តាមសំណូមពររបស់សាមីខ្លួន។

ប្រធាន និងអនុប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មិនត្រូវទទួលខុសត្រូវខាងបទព្រហ្មទណ្ឌ ឬបទរដ្ឋប្បវេណីណាមួយ ចំពោះការសម្រេចដែលបានធ្វើក្នុងក្របខ័ណ្ឌសមត្ថកិច្ចនិងមុខងាររបស់ខ្លួនឡើយ។[១០៧]

(១០៥),(១០៦),(១០៧) មាត្រា ១១ មាត្រា ១២ មាត្រា ១៣ ច្បាប់ស្តីពីរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## ក.ការជ្រើសរើសសមាជិក គ.ជ.ប របស់គណបក្សមានអាសនៈក្នុងរដ្ឋសភា

កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ គណបក្សជាប់ឆ្នោតទាំងពីរព្រមព្រៀងគ្នាជ្រើសរើសសមាសភាពសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតតាមរូបមន្ត ៤-៤-១។ បក្សកាន់អំណាចដាក់សមាជិក ៤នាក់ បក្សប្រឆាំង ៤នាក់ និងបុគ្គលឯករាជ្យ ១នាក់។

សេចក្តីជូនដំណឹងរបស់អគ្គលេខាធិការរដ្ឋសភា ចេញថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ បញ្ជាក់ថា ឥស្សរជនដែលមានបំណងឈរឈ្មោះជាបេក្ខជនចូលរួមក្នុងការជ្រើសរើស អាចទៅដាក់ពាក្យជារៀងរាល់ថ្ងៃចាប់ពីថ្ងៃប្រកាសនេះរហូតដល់ថ្ងៃទី៦ ខែមេសា។ លក្ខណៈសម្បត្តិរបស់បេក្ខជនក្នុងនោះត្រូវមានកម្រិតវប្បធម៌ចាប់ពីឧត្តមសិក្សាឡើងទៅ មានសញ្ជាតិខ្មែរ អាយុយ៉ាងតិច ៣៥ឆ្នាំ មានសិទ្ធិបោះឆ្នោត មានបទពិសោធន៍ការងារយ៉ាងតិច ១០ឆ្នាំ មិនត្រូវជាសហព័ន្ធញាតិលោហិតរហូតដល់ថ្នាក់ទី៣ របស់ប្រធាន អនុប្រធានគណបក្សនយោបាយ ដែលចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត។ ប្រសិនបើមានសញ្ជាតិផ្សេងក្រៅពីសញ្ជាតិខ្មែរ ត្រូវប្រកាសពីការបោះបង់សញ្ជាតិបរទេសនោះ។ ការទទួលពាក្យមានរយៈពេល ១០ថ្ងៃ ដោយគិតចាប់ពីថ្ងៃជូនដំណឹង។[១០៨]

## ខ.ការជ្រើសតាំងសមាជិក គ.ជ.ប តាមការព្រមព្រៀងរបស់គណបក្សមានអាសនៈក្នុងរដ្ឋសភា

អ្នកដឹកនាំគណបក្សសង្គ្រោះជាតិ បានផ្ញើលិខិតអបអរចំពោះអ្នកស្រី ពុង ឈីវកេក ប្រធានអង្គការការពារសិទ្ធិមនុស្សលីកាដូ ដែលព្រមទទួលតំណែងជាសមាជិកទី៩ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតហៅកាត់ថា គ.ជ.ប។ ការស្នើតែងតាំងអ្នកស្រី ពុង ឈីវកេក នេះមានសញ្ញាយល់ព្រមពីសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន អនុប្រធានគណបក្សប្រជាជនកម្ពុជា ផងដែរ។ លិខិតរបស់អ្នកស្រី ពុង ឈីវកេក ផ្ញើជូនគណបក្សជាប់ឆ្នោតទាំងពីរមានខ្លឹមសារថា អ្នកស្រីសង្ឃឹមថា សមាជិក គ.ជ.ប នឹងមានការការពារដោយអភ័យឯកសិទ្ធិ ការធានាឲ្យមានស្វ័យភាពក្នុងការធ្វើសេចក្តីសម្រេចចិត្ត ហើយគួរតែមានសិទ្ធិជ្រើសរើសបុគ្គលិកជំនាញដើម្បីបំពេញការងារព្រមទាំងមានថវិកាស្វយ័ត ហើយមានសិទ្ធិចាត់ចែងថវិកាជំនួយពីក្នុងនិងក្រៅប្រទេស។ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ប្រធានអង្គការលីកាដូ (Licadho) អ្នកស្រី ពុង ឈីវកេក បានចេញសេចក្តីថ្លែងការណ៍មួយ បដិសេធតំណែងជាសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) ដែលគណបក្សនយោបាយឈ្នះឆ្នោតទាំងពីរបានប្រកាសកន្លងទៅ ថាប្រគល់ជូនអ្នកស្រី។ ក្រោយពីមានការបដិសេធនេះ

(១០៨).សេចក្តីជូនដំណឹងរបស់រដ្ឋសភាថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៥

ដំណឹងអំពីបេក្ខភាពថ្មីក៏ត្រូវបានសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងលោក សម រង្ស៊ី បង្ហាញជាសាធារណៈ។ នៅក្នុងលិខិតដែលចុះហត្ថលេខាដោយ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ផ្ញើទៅ លោក សម រង្ស៊ី បានឲ្យដឹងថា តាមការឆ្លងឆ្លើយគ្នារវាងលោក និងលោក សម រង្ស៊ី តាមសារទូរស័ព្ទនៅថ្ងៃទី២៩ ខែមីនា គណបក្សទាំងពីរបានឯកភាពគ្នាជ្រើសរើសយក លោក ហាង្ស ពុទ្ធា នាយកប្រតិបត្តិនៃគណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ ហៅកាត់ថា និកហ្វិច ធ្វើជាបេក្ខភាពទី៩ នៃគ.ជ.ប។ លិខិតមានហត្ថលេខាសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន អនុប្រធានគណបក្សប្រជាជនកម្ពុជា និងចុះកាលបរិច្ឆេទថ្ងៃទី២៩ ខែមីនា ។ សេចក្តីថ្លែងការណ៍មានខ្លឹមសារថា កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៤ កន្លងទៅគណបក្សនយោបាយឈ្នះឆ្នោតទាំងពីរ បានឯកភាពគ្នាជ្រើសរើសអ្នកស្រីជាសមាជិកទី៩ របស់ គ.ជ.ប ដែលតំណាងភាពឯករាជ្យនៅក្នុងសមាសភាពសមាជិក គ.ជ.ប ថ្មី។ សមាជិក គ.ជ.ប ថ្មី មានសមាជិកមកពីគណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភា ចំនួន ៨រូប ដោយ ៤រូបមកពីគណបក្សប្រជាជនកម្ពុជា និង ៤រូបទៀតមកពីគណបក្ស សង្គ្រោះជាតិ។ ទាក់ទងនឹងបេក្ខភាពទី៩ ថ្មីនេះ ក្នុងលិខិតរបស់គណបក្សទាំងពីរ បានឯកភាពគ្នារៀបចំលិខិតរួមគ្នាជាផ្លូវការមួយផ្ញើជូនទៅគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ដើម្បីបញ្ជាក់អំពីការព្រមព្រៀងគ្នាលើសំណើនេះ។[១០៩]

លោក ហាង្ស ពុទ្ធា នាយកប្រតិបត្តិគណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ដើម្បីការបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា ហៅកាត់ថា និកហ្វិច (NICFEC) បានដាក់ពាក្យសុំធ្វើជាសមាជិកទី៩ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប)។ លោកសន្យានឹងខិតខំប្រឹងប្រែងធ្វើការងារបោះឆ្នោតដើម្បីកែទម្រង់ការបោះឆ្នោតនៅកម្ពុជា ឲ្យមានលក្ខណៈសេរី និងយុត្តិធម៌។ លោក ហាង្ស ពុទ្ធា បញ្ជាក់ថា បទពិសោធន៍ការងាររយៈពេល ១៧ឆ្នាំ ពាក់ព័ន្ធផ្នែកសង្គម និងការបោះឆ្នោត នឹងផ្តល់លទ្ធភាពឲ្យលោកជួយធ្វើកំណែទម្រង់ផ្នែកបោះឆ្នោតនៅកម្ពុជា។ កាលពីថ្ងៃអង្គារ ទី៣១ ខែមីនា ឆ្នាំ២០១៥ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន និងលោក សម រង្ស៊ី បានឯកភាពគ្នាជ្រើសរើសយកលោក ហាង្ស ពុទ្ធា នាយកអង្គការឃ្លាំមើលការបោះឆ្នោតហៅថា និកហ្វិច ធ្វើជាបេក្ខភាពទី៩ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។[១១០]

(១០៩). ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី៣១ មីនា ២០១៥ ដោយ ខែ សុណង

(១១០). (ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី០១ មេសា ២០១៥ ដោយ យន់ សាមៀន)

**គ.រដ្ឋសភាបោះឆ្នោតផ្តល់សេចក្តីទុកចិត្ត ប្រធាន អនុប្រធាន សមាជិក និង សមាជិកា របស់ គ.ជ.ប**

នៅក្នុងសម័យប្រជុំនីតិកាលទី៥ របស់រដ្ឋសភា នៅព្រឹកថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៥ អង្គសភាបានអនុម័តជាកញ្ចប់នូវសមាជិកទាំង ៩រូប ដោយសំឡេងគាំទ្រ ១១៣ លើ ១១៧សំឡេង។ សមាជិកទាំង ៩រូបដែលសភាបោះឆ្នោតអនុម័តនោះ គឺលោក សិក ប៊ុនហុក មកពីគណបក្សប្រជាជនកម្ពុជា ធ្វើជាប្រធាន គ.ជ.ប និងលោក គួយ ប៊ុនរឿន មកពីគណបក្សសង្គ្រោះជាតិ ជាអនុប្រធាន គ.ជ.ប ថ្មីនេះ។ ចំពោះសមាជិក គ.ជ.ប វិញ មាន លោក មាន សទិ លោក រ៉ុង ឈុន លោក ឌុច សុន លោក ហ៊ីង ធីឫទ្ធិ លោក ឯម សូផាត អ្នកស្រី តែ ម៉ានីរ៉ុង និងលោកបណ្ឌិត ហង្ស ពុទ្ធា។[១១១]

នៅថ្ងៃជាមួយគ្នានោះ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ជំរុញឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ថ្មី ត្រូវផ្តាច់ខ្លួនចេញពីគណបក្សនយោបាយ ទោះបីជាសមាសភាពទាំង ៨រូបជ្រើសចេញពីគណបក្សជាប់ឆ្នោតទាំងពីរក៏ដោយ។ ក្រៅពីនេះទៀត ទាំងលោក សម រង្ស៊ី និងសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានឯកភាពគ្នាមិនចង់ឲ្យការបោះឆ្នោតនៅពេលខាងមុខមានបញ្ហាទៀតនោះឡើយ ដោយលោកទាំងពីរជំរុញឲ្យស្ថាប័នរៀបចំការបោះឆ្នោតថ្មីនេះ ត្រូវប្រកាន់ជំហរឯករាជ្យ អព្យាក្រឹត មិនត្រូវស្ថិតនៅក្រោមឥទ្ធិពលគណបក្សនយោបាយណាមួយនោះឡើយ។ បន្ថែមលើសនេះ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន មានប្រសាសន៍ថា លទ្ធផលឈានមកដល់បង្កើតគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតថ្មីនេះបាន គឺដោយសារតែវប្បធម៌សន្ទនាដែលផ្តួចផ្តើមពីរូបលោក និងលោក សម រង្ស៊ី នៅក្រោយពីកិច្ចព្រមព្រៀងនយោបាយកាលពីថ្ងៃទី២២ ខែកក្កដា។[១១២] បន្ទាប់ពីរដ្ឋសភាបានបោះឆ្នោតផ្តល់សេចក្តីទុកចិត្តដល់សមាជិក.ជ.ប ថ្មី៩រូបហើយនៅរសៀលថ្ងៃទី១១ ខែមេសា ពួកគេនាំគ្នាស្បថចូលកាន់តំណែងនៅក្នុងព្រះបរមរាជវាំង។ ពិធីសម្បថនេះ ធ្វើឡើងពីរថ្ងៃមុនពេលពិធីផ្ទេរតំណែងពីប្រធាន គ.ជ.ប ចាស់ដែលប្រព្រឹត្តទៅនៅថ្ងៃទី១៣ ខែមេសា។[១១៣]

## ១.២ រចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប

### - អគ្គលេខាធិការដ្ឋាន

អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប មានតួនាទីជាជំនួយការជូន គ.ជ.ប ក្នុងការរៀបចំចាត់ចែង

(១១១,១១២). ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី០៩ មេសា ២០១៥ ដោយ ទីន ហ្សាការីយ៉ា

(១១៣).ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី១១ មេសា ២០១៥ ដោយ យ៉ាង សុជាមេត្តា

និងគ្រប់គ្រងការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ព្រមទាំងការបោះឆ្នោតផ្សេងទៀត តាមការកំណត់នៃច្បាប់។[១១៤]

អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប មានភារកិច្ចដូចតទៅៈ

ក. អនុវត្តច្បាប់បោះឆ្នោត បទបញ្ជានិងនីតិវិធីសម្រាប់ការបោះឆ្នោត បទបញ្ជាផ្ទៃក្នុង សេចក្តីសម្រេច និងសេចក្តីណែនាំនានារបស់ គ.ជ.ប ។

ខ. លើកសំណើជូន គ.ជ.ប ដើម្បីពិនិត្យ សម្រេច អំពី ៖

- តម្រូវការនៃធនធានមនុស្ស
- ផែនការមេចុះឈ្មោះអ្នកបោះឆ្នោត ធ្វើបញ្ជីបោះឆ្នោត និងបច្ចុប្បន្នភាពនៃបញ្ជីបោះឆ្នោត ផែនការសម្រាប់ការបោះឆ្នោត និងប្រតិទិនសម្រាប់ការបោះឆ្នោត
- ផែនការប្រតិបត្តិ
- ផែនការគ្រប់គ្រង និងចាត់ចែងថវិកា
- គម្រោងថវិកាប្រចាំឆ្នាំ និងថវិកាសម្រាប់ការបោះឆ្នោត
- ផែនការបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត
- ផែនការផ្សព្វផ្សាយអប់រំសាធារណជន
- ផែនការផ្សព្វផ្សាយច្បាប់ ផែនការចុះបញ្ជីគណបក្សនយោបាយ ផែនការទទួលពាក្យបណ្តឹង និងការសហការចាត់ចែងការងារសន្តិសុខបោះឆ្នោត
- ផែនការសវនកម្ម
- របាយការណប្រចាំខែ ប្រចាំត្រីមាស ប្រឆាំឆមាស និងប្រចាំឆ្នាំ ព្រមទាំងរបាយការណ៍អំពីដំណើរការបោះឆ្នោត

គ. ទទួលរ៉ាប់រងនូវកិច្ចការរដ្ឋបាល និងសេវាកម្មនានាជូន គ.ជ.ប ព្រមទាំងទំនាក់ទំនងផ្សេងៗក្រៅ គ.ជ.ប ។

ឃ. បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ភារកិច្ចពី គ.ជ.ប ។[១១៥]

អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប ដឹកនាំដោយអគ្គលេខាធិការ១ (មួយ) រូប មានឋានៈនិងបុព្វសិទ្ធិស្មើនិងរដ្ឋលេខាធិការ និងអគ្គលេខាធិការរងមួយចំនួនជាជំនួយការតាមការចាំបាច់ មានឋានៈនិងបុព្វសិទ្ធិស្មើនិងអនុរដ្ឋលេខាធិការ ដែលតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើររបស់ប្រធាន

(១១៤). ម ៤ អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

(១១៥).ម ៥ អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន នៃគណៈ កម្មាធិការជាតិរៀបចំការបោះឆ្នោត

គ.ជ.ប បន្ទាប់ពីបានយោបល់យល់ស្របតាមសម្លេងភាគច្រើនដាច់ខាតនៃសមាសភាព គ.ជ.ប ទាំងមូល។[១១៦]

អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប មានលេខាធិការដ្ឋានមួយជំនួយការ សម្រាប់ជួយការងាររបស់អគ្គលេខាធិការ និងអគ្គលេខាធិការរង។[១១៧] អគ្គលេខាធិការនៃ គ.ជ.ប មានត្រាសម្រាប់ប្រើប្រាស់ក្នុងការបំពេញការងាររបស់ខ្លួន។[១១៨]

**ក. លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន**

លេខាធិការដ្ឋាននៃអគ្គលេខាធិការដ្ឋាន ជាជំនួយការនៃអគ្គលេខាធិការ និងអគ្គលេខាធិការរង។ ប្រធានលេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប មានឋានៈស្មើនឹងប្រធាននាយកដ្ឋាន ដែលត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់ គ.ជ.ប ។[១១៩] អគ្គលេខាធិការ អគ្គលេខាធិការរង និង បុគ្គលិកទាំងអស់ត្រូវមានគណនេយ្យភាពតាមឋានានុក្រមចំពោះ គ.ជ.ប ។[១២០]

**ខ. នាយកដ្ឋានរដ្ឋបាល**

នាយកដ្ឋានរដ្ឋបាលមានតួនាទីលើការងារគ្រប់គ្រងរដ្ឋបាល និងគ្រប់គ្រងបុគ្គលិក និង ចាត់ចែងឯកសារ ការរៀបចំកិច្ចប្រជុំសន្និបាត សិក្ខាសាលា ការធ្វើរបាយការណ៍នានារបស់អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប ។ នាយកដ្ឋានរដ្ឋបាលមានភារកិច្ចដូចតទៅៈ

- ចាត់ចែងការងាររដ្ឋបាលទូទៅនៃ គ.ជ.ប
- លើកគម្រោងអំពីតម្រូវការនៃធនធានមនុស្ស
- រៀបចំការជ្រើសរើស និងគ្រប់គ្រងមន្ត្រីរាជការ
- លើកគម្រោងនិងផ្គត់ផ្គង់សម្ភារបរិក្ខាការិយាល័យសម្រាប់ គ.ជ.ប ប្រចាំឆ្នាំក្នុងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងក្នុងពេលបោះឆ្នោត
- ថែទាំ និងគ្រប់គ្រងអគារ និងទ្រព្យសម្បត្តិ សម្ភារបរិក្ខារបស់ គ.ជ.ប
- បូកសរុបរបាយការណ៍សកម្មភាពរបស់អគ្គលេខាធិការដ្ឋាន ប្រចាំខែ ប្រចាំត្រីមាស និងឆ្នាំ
- បូកសរុប និងធ្វើសេចក្តីព្រាងរបាយការណ៍ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងបោះឆ្នោត
- រក្សាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ទីស្តីការ គ.ជ.ប

(១១៦). ម ៧ (១១៧, ១១៩). ម ៨ (១១៨). ម ១០ (១២០). ម៩ អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- សហាការជាមួយនាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោតអំពីការបណ្តុះបណ្តាលការងាររដ្ឋបាលដល់មន្ត្រីរាជការ

- សហាការជាមួយនាយកដ្ឋានហិរញ្ញវត្ថុអំពីការងារសាពើរភ័ណ្ឌ

- បំពេញភារកិច្ចផ្សេងៗទៀតដែល គ.ជ.ប ប្រគល់ឲ្យ។[១២១]

**គ. នាយកដ្ឋានប្រតិបត្តិការ**

នាយកដ្ឋានប្រតិបត្តិការ មានតួនាទីលើការងាររៀបចំការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងចាត់ចែងដំណើរការនៃការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផល និងការប្រកាសលទ្ធផលនៃការបោះឆ្នោត។ នាយកដ្ឋាប្រតិបត្តិ មានភារកិច្ចដូចតទៅះ

-រៀបចំផែនការការងារ និងប្រតិទិននៃកិច្ចប្រតិបត្តិការបោះឆ្នោត

-ប៉ាន់ស្មានស្ថិតិប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោត និងកំណត់ចំនួនទីតាំងការិយាល័យបោះឆ្នោត

- ចាត់ចែងលើកគម្រោងផែនការ ថវិកាដើម្បីផ្គត់ផ្គង់សម្ភារឯកសារ និងសេវាផ្សេងៗសម្រាប់បម្រើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត

- ធ្វើគម្រូទម្រង់បែបបទសម្រាប់ពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត

- ចាត់ចែងលើកគម្រោងផែនការ និងតម្រូវការមន្ត្រីចុះឈ្មោះបោះឆ្នោត មន្ត្រីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងផ្តល់ឯកសារនេះ ជូននាយកដ្ឋានរដ្ឋបាល

- ចាត់ចែងគ្រប់គ្រងឯកសារ សម្ភារគ្រប់គ្រងឯកសារនៅឃ្លាំង គ.ជ.ប

- ចាត់ចែងនិងសម្របសម្រួលរាល់កិច្ចប្រតិបត្តិការនៅគ្រប់ដំណាក់កាលនៃការបោះឆ្នោត

- តាមដានសរុបព័ត៌មានដែលទទួលបានតាមវិទ្យុទាក់ទង ទូរស័ព្ទ ទូរសារ អំពីបញ្ហាពាក់ព័ន្ធនឹងដំណើរការបោះឆ្នោត និងរាយការណ៍ជាប្រចាំជូនអគ្គលេខាធិការ និងគ.ជ.ប

- ត្រួតពិនិត្យគុណភាពសម្ភារៈ ឯកសារបោះឆ្នោត ការវេចខ្ចប់ និងការដឹកជញ្ជូនសម្ភារបោះឆ្នោតឲ្យចំគោលដៅ ប្រកបដោយសន្តិសុខ និងសុវត្ថិភាព

- ចាត់ចែងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោត និងបញ្ចូលទិន្នន័យលទ្ធផលទៅក្នុងកុំព្យូទ័រ និងគ្រប់គ្រងរក្សាកំណត់ហេតុនៃការបូកសរុបលទ្ធផលនៃការបោះឆ្នោត

(១២១). ម ១១ អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បំពេញភារកិច្ចផ្សេងៗដែល គ.ជ.ប ប្រគល់ឲ្យ។[១២២]

**ឃ. នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត**

នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតមានតួនាទីលើការងារបច្ចេកទេសចុះឈ្មោះបោះឆ្នោត ការទទួល ការបញ្ជូន និងគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោតក្នុងប្រព័ន្ធកុំព្យូទ័រព្រមទាំងរក្សាទុកនូវរាល់ឯកសារពាក់ព័ន្ធនិងបញ្ជីបោះឆ្នោត ប្រកបដោយសុវត្ថិភាព។

នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត មានភារកិច្ចដូចតទៅៈ

- គ្រប់គ្រងថែរក្សាបញ្ជីបញ្ចូលទិន្នន័យ និងសម្ភារបរិក្ខាកុំព្យូទ័រសម្រាប់ការចុះឈ្មោះបោះឆ្នោត

- គ្រប់គ្រងចាត់ចែងទទួលទិន្នន័យបញ្ជូនពីឃុំ សង្កាត់ តាមអនឡាញ(Online) និងឯកសារអ្នកចុះឈ្មោះបោះឆ្នោត

- គ្រប់គ្រង់ផ្ទៀងផ្ទាត់ទិន្នន័យពីឃុំ សង្កាត់ និងសុំយោបល់សម្រេចពី គ.ជ.ប ក្នុងករណីពិនិត្យឃើញមានភាពមិនត្រឹមត្រូវក្នុងបញ្ជីបោះឆ្នោត

- រៀបចំចាត់ចែងផលិតបញ្ជីបោះឆ្នោតដំបូង

- គ្រប់គ្រងនិងផលិតបញ្ជីបោះឆ្នោតផ្លូវការ និងបណ្ណព័ត៌មានអ្នកបោះឆ្នោតសម្រាប់ឲ្យការបោះឆ្នោតនីមួយៗ និងការបោះឆ្នោតផ្សេងទៀត តាមការកំណត់ដោយច្បាប់

- ផ្តល់របាយការណ៍គ្រប់គ្រាន់ពាក់ព័ន្ធ នឹងចំនួនអ្នកបោះឆ្នោត (ចុះឈ្មោះបោះឆ្នោតថ្មី លុប កែតម្រូវទិន្នន័យ ស្ទួន ឈ្មោះ ភេទ អាយុ) ជូនគ.ជ.ប ដើម្បីពិនិត្យ និងសម្រេច

- ផលិត CD ផ្ទុកបញ្ជីបោះឆ្នោតជាទម្រង់ PDF ជូន លធ.ខប និងទុកជាឯកសារ

- បង្ហោះបញ្ជីបោះឆ្នោតជាផ្លូវការតាមគេហទំព័ររបស់ គ.ជ.ប

- សហការជាមួយនាយកដ្ឋានប្រតិបត្តិការ អំពីការរៀបចំបញ្ជីទីតាំងការិយាល័យបោះឆ្នោត និងស្ថិតិតួលេខអ្នកបោះឆ្នោតតាមការិយាល័យបោះឆ្នោតនីមួយៗ

- បំពេញភារកិច្ចផ្សេងៗទៀត ដែល គ.ជ.ប ប្រគល់ឲ្យ ។[១២៣]

---

(១២២). ម ១២ អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

(១២៣). ម ១៣ អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

### ខ. នាយកដ្ឋានហិរញ្ញវត្ថុ

នាយកដ្ឋានហិរញ្ញវត្ថុ មានតួនាទីលើការងារហិរញ្ញវត្ថុរបស់ គ.ជ.ប ។

នាយកដ្ឋានហិរញ្ញវត្ថុមានភារកិច្ចដូចតទៅ៖

- គ្រប់គ្រងសកម្មភាពហិរញ្ញវត្ថុ និងបន្ទុកគណនីរបស់ គ.ជ.ប
- គ្រប់គ្រងចំណូល-ចំណាយរបស់ គ.ជ.ប ទាំងមូល
- រៀបចំគ្រប់គ្រង ការបែងចែក និងការត្រួតពិនិត្យកិច្ចការហិរញ្ញវត្ថុ នៃ គ.ជ.ប
- គ្រប់គ្រង ត្រួតពិនិត្យទ្រព្យសម្បត្តិ និងចុះបញ្ជីសារពើភ័ណ្ឌរបស់ គ.ជ.ប
- ធ្វើគម្រោងផែនការរបស់ គ.ជ.ប
- រៀបចំគ្រប់គ្រងថវិកា បែងចែកថវិកា និងបញ្ជិកាគណនេយ្យ នៃ គ.ជ.ប ទាំងមូល និងគ្រប់គ្រងលំដាប់ថ្នាក់
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងបញ្ជិកាគណនេយ្យនៃ គ.ជ.ប ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- ត្រួតពិនិត្យសក្ខីបត្រចំណាយ និងឯកសារទូទាត់ថវិការបស់គណៈកម្មាធិការរាជធានី ខេត្តរៀបចំការបោះឆ្នោត និងគណៈកម្មាធិការឃុំ សង្កាត់ រៀបចំការបោះឆ្នោត
- ត្រួតពិនិត្យការអនុវត្តន៍នីតិវិធីនៃលទ្ធកម្មសាធារណៈរបស់ គ.ជ.ប
- បំពេញភារកិច្ចផ្សេងៗទៀត ដែល គ.ជ.ប ប្រគល់ឲ្យ។[១២៤]

### ច. នាយកដ្ឋានបណ្តុះបណ្តាលនិងអប់រំអ្នកបោះឆ្នោត

នាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត មានតួនាទីលើការបណ្តុះបណ្តុះបណ្តាលមន្ត្រីរាជការនៃ គ.ជ.ប និងភាគីពាក់ព័ន្ធ និងអប់រំអ្នកបោះឆ្នោត។ នាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត មានភារកិច្ចដូចតទៅ៖

- លើកគម្រោងផែនការ និងបង្កើតកម្មវិធីបណ្តុះបណ្តាលដល់មន្ត្រីរាជការនៃ គ.ជ.ប មន្ត្រីចុះបញ្ជីបោះឆ្នោត មន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់និងគ្រប់ភាគីពាក់ព័ន្ធ
- ចងក្រង និងផលិតឯកសារបណ្តុះបណ្តាលសម្រាប់ការចុះឈ្មោះបោះឆ្នោតនិងការបោះឆ្នោត
- លើកគម្រោងផែនការ កម្មវិធីអ្នកបោះឆ្នោត និងសិក្សាស្រាវជ្រាវរកខ្លឹមសារសំខាន់ៗ ដើម្បីផលិតសម្ភារៈ និងរូបភាពអប់រំសម្រាប់អ្នកបោះឆ្នោតទៅតាមដំណាក់កាលនៃការបោះឆ្នោត

(១២៤). ម ១៤ អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បូកសរុបវាយតម្លៃអំពីកម្រិតយល់ដឹងរបស់អ្នកបោះឆ្នោតជូន គ.ជ.ប

- សហការត្រួតពិនិត្យ និងផ្តល់យោបល់រាល់ខ្លឹមសារនិងរូបភាពផ្សេងៗសម្រាប់អប់រំអ្នកបោះឆ្នោតដែលស្នើឡើងដោយអង្គការមិនមែនរដ្ឋាភិបាលនិងភាគីពាក់ព័ន្ធ

- បំពេញភារកិច្ចផ្សេងៗ ដែល គ.ជ.ប ប្រគល់ឲ្យ។

### ឆ. នាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ

នាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ មានតួនាទីលើការងារទំនាក់ទំនងជាមួយស្ថាប័នជាតិ-អន្តរជាតិ ទាក់ទងនឹងការបោះឆ្នោត និងផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងការបោះឆ្នោតជូនសាធារណជន។ នាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ មានភារកិច្ចដូចតទៅៈ

- ផ្សព្វផ្សាយព័ត៌មានជាសាធារណៈ ដើម្បីលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ អំពីការបោះឆ្នោតតាមគ្រប់មធ្យោបាយផ្សេងៗ

- រៀបចំសៀវភៅណែនាំស្តីពីការឃោសនាបោះឆ្នោត សេចក្តីថ្លែងការណ៍ ប្រកាសព័ត៌មាន សេចក្តីជូនដំណឹង និងគោលការណ៍ផ្សេងៗ

- រៀបចំ និងផលិតឯកសារផ្សព្វផ្សាយអប់រំសាធារណជន

- ផ្សព្វផ្សាយលទ្ធផលនៃការចុះឈ្មោះបោះឆ្នោត បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតផ្លូវការ និងលទ្ធផលនៃការបោះឆ្នោត

-តាមដានសកម្មភាពឃោសនារបស់គណបក្សនយោបាយការផ្សព្វផ្សាយរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងតាមប្រព័ន្ធផ្សព្វផ្សាយសង្គមពាក់ព័ន្ធនឹងការបោះឆ្នោត

- រៀបចំសន្និសីទសារព័ត៌មាន និងកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធ ថតសកម្មភាពវីដេអូ រូបភាព សំឡេង និងធ្វើកំណត់ហេតុប្រជុំ-សន្និសីទ

- ចងក្រងឯកសារវីដេអូ រូបភាព សំឡេង CD Data និងឯកសារផ្សេងៗជាសៀវភៅ

- គ្រប់គ្រងគេហទំព័រ(Website) និងប្រព័ន្ធផ្សព្វផ្សាយរបស់ គ.ជ.ប

- ទទួលពាក្យ និងរៀបចំសម្គាល់ខ្លួនសម្រាប់អ្នកសារព័ត៌មានជាតិ-អន្តរជាតិ ដែលចូលរួមយកព័ត៌មានបោះឆ្នោត

- យកព័ត៌មានតាមរាជធានី ខេត្ត និងព័ត៌មានតាមកម្មវិធីផ្សេងៗ របស់ស្ថាប័នពាក់ព័ន្ធនឹងការបោះឆ្នោតតាមការចាត់តាំងរបស់ គ.ជ.ប

-ទំនាក់ទំនងនិងផ្លាស់ប្តូរព័ត៌មានជាមួយស្ថាប័នជាតិ-អន្តរជាតិអំពីការបោះឆ្នោត

- បកប្រែឯកសារពីភាសាខ្មែរទៅភាសាអង់គ្លេស និងពីភាសាអង់គ្លេសមកជាភាសា

ខ្មែរ ដើម្បីធ្វើការផ្សព្វផ្សាយ

- បំពេញភារកិច្ចផ្សេងៗដែល គ.ជ.ប ប្រគល់ឲ្យ ។[១២៥]

### ង. នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម

នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មច្បាប់ មានតួនាទីសិក្សាស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ ចុះបញ្ជីគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោត និងទទួលពាក្យបណ្តឹងពាក់ព័ន្ធនឹងការបោះឆ្នោត ព្រមទាំងសហការលើផ្នែកសន្តិសុខសុវត្ថិភាពបោះឆ្នោត។ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មច្បាប់ មានភារកិច្ចដូចតទៅ៖

- សិក្សាស្រាវជ្រាវ និងជូនយោបល់ខាងផ្នែកច្បាប់ដល់ គ.ជ.ប
- ចងក្រង និងបោះពុម្ពឯកសារច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃ គ.ជ.ប ច្បាប់បោះឆ្នោត និងលិខិតបទដ្ឋានផ្សេងទៀតពាក់ព័ន្ធនឹងការបោះឆ្នោត
- រៀបចំកម្មវិធីផ្សព្វផ្សាយច្បាប់ និងបទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត
- រៀបចំសៀវភៅណែនាំនីតិវិធីសម្រាប់ការដាក់ ការទទួល និងការដោះស្រាយ ពាក្យបណ្តឹងសម្រាប់ការបោះឆ្នោត សេចក្តីព្រាងក្រមសីលធម៌ និងឯកសារផ្សេងៗទាក់ទងនឹងការងារអ្នកសង្កេតការណ៍ បេក្ខជនឈរឈ្មោះបោះឆ្នោត និងគណបក្សនយោបាយ
- អនុវត្តនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង
- អនុវត្តនីតិវិធីនៃការចុះបញ្ជីគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត
- អនុវត្តនីតិវិធីនៃការផ្លាស់ប្តូរសមាជិកព្រឹទ្ធសភា និងតំណាងរាស្ត្ររបស់គណបក្សនយោបាយ តាមសំណើសុំ
- ចាត់ចែងការងារចុះបញ្ជីបេក្ខជនបម្រុងនៃសមាជិកព្រឹទ្ធសភា តំណាងរាស្ត្រ ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំសង្កាត់
- ចុះឈ្មោះអ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងតំណាង ឬភ្នាក់ងារគណបក្សនយោបាយក្នុងការបោះឆ្នោត
- សហការលើកិច្ចការសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈសម្រាប់ការបោះឆ្នោត

(១២៥). ម ១៦ អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បំពេញភារកិច្ចផ្សេងៗទៀត ដែល គ.ជ.ប ប្រគល់ឲ្យ។[១២៦]

**ឈ. នាយកដ្ឋានសវនកម្មផ្ទៃក្នុង**

នាយកដ្ឋានសវនកម្មផ្ទៃក្នុង មានតួនាទីលើការងារសវនកម្មលើនាយកដ្ឋាន និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋាន។ នាយកដ្ឋានសវនកម្មផ្ទៃក្នុង មានភារកិច្ចដូចតទៅ៖

- រៀបចំផែនការសវនកម្មប្រចាំឆ្នាំជូនប្រធាន គ.ជ.ប ពិនិត្យនិងសម្រេច

- ត្រួតពិនិត្យកម្មវិធី និងសកម្មភាពកិច្ចសហប្រតិបត្តិការរបស់អង្គភាពនានាក្នុងគោលដៅអនុវត្តឲ្យបានត្រឹមត្រូវតាមគោលការណ៍ នីតិវិធី និងបែបបទការងាររបស់ គ.ជ.ប

- ត្រួតពិនិត្យដើម្បីឲ្យមានការគោរពដាច់ខាតនូវបទបញ្ញត្តិផ្សេងៗជាធរមានពាក់ព័ន្ធនិងប្រតិបត្តិការហិរញ្ញវត្ថុ គណនេយ្យ រដ្ឋបាល បុគ្គលិក និងបច្ចេកទេសរបស់ គ.ជ.ប

- កំណត់វិធានការកែលម្អលើកិច្ចប្រតិបត្តិការ និងលើកអនុសាសន៍ដល់អង្គភាពពាក់ព័ន្ធ

- ធ្វើរបាយការណ៍ជូន គ.ជ.ប ដោយមានសេចក្តីសន្និដ្ឋាន អនុសាសន៍ និងដំណោះស្រាយ កែលម្អសមស្រប ហើយត្រូវផ្ញើរបាយការណចតចម្លងទៅអាជ្ញាធរសវនកម្មជាតិ

- បំពេញភារកិច្ចផ្សេងៗទៀត ដែល គ.ជ.ប ប្រគល់ឲ្យ។[១២៧]

**ញ. លេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត**

លេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត នៅក្នុងចន្លោះពីការបោះឆ្នោតមួយទៅការបោះឆ្នោតមួយ ត្រូវបានហៅថា លេខាធិការដ្ឋានរាជធានី ខេត្ត រៀបចំការបោះឆ្នោត(លធ.ខប) មានភារកិច្ចដូចតទៅ៖

- ទំនាក់ទំនងជាមួយអាជ្ញាធររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់

-ទទួលឈ្មោះប្រជាពលរដ្ឋដែលទទួលមរណភាព ដែលត្រូវបានដកហូតជាបណ្តោះអាសន្ននៅសិទ្ធិបោះឆ្នោត ដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ដែលបានផ្លាស់លំនៅដ្ឋាន ឬទីសំណាក់ចេញទៅឃុំ សង្កាត់ផ្សេងពីស្មៀនឃុំ សង្កាត់ រៀងរាល់២(ពីរ)ខែម្តង។ ក្នុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតត្រូវសហការជាមួយក្រុមចុះឈ្មោះបោះឆ្នោតនៃឃុំ សង្កាត់ នីមួយៗដើម្បីលុបឈ្មោះប្រជាពលរដ្ឋទាំងនោះចេញពីបញ្ជីបោះឆ្នោត

(១២៦) ម ១៧ (១២៧). ម ១៨ អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

-ទទួលឈ្មោះប្រជាពលរដ្ឋដែលមិនបានចុះឈ្មោះពីមុនមកដែលទើបដល់អាយុបោះឆ្នោត ដែលបានផ្លាស់លំនៅដ្ឋាន ឬទីសំណាក់ចូលថ្មីស្មៀនឃុំ សង្កាត់ រៀងរាល់២(ពីរ)ខែម្តង

- ពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីចាត់ឲ្យក្រុមចុះឈ្មោះបោះឆ្នោតធ្វើការចុះឈ្មោះចល័តស្របតាមបទបញ្ជា និងនីតិវិធី

- សហការជាមួយឃុំ សង្កាត់ ធ្វើការប៉ាន់ស្មានចំនួនប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ចំនួនពលរដ្ឋអាយុ១៨(ដប់ប្រាំបី)ឆ្នាំឡើងទៅ ចំនួន និងទីតាំងការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗ

- រាយការណ៍ជូន គ.ជ.ប អំពីដំណើរការចុះឈ្មោះបោះឆ្នោត

- ទទួលសម្ភារបរិក្ខារនៃ គ.ជ.ប និងឃុំ សង្កាត់

- ជំនួយការឲ្យ គ.ជ.ប ក្នុងការជ្រើសរើសក្រុមចុះឈ្មោះបោះឆ្នោតនៃឃុំ សង្កាត់នីមួយៗ

- ជំនួយការឲ្យ គ.ជ.ប ក្នុងការដោះស្រាយបញ្ហានានាដែលអាចកើតមាននៅក្នុងរាជធានី ខេត្ត នីមួយៗ

- ជំនួយការឲ្យគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត ក្នុងដំណាក់កាលបោះឆ្នោត

- បំពេញភារកិច្ចផ្សេងៗ ដែល គ.ជ.ប ប្រគល់ឲ្យ។[១២៨]

នាយកដ្ឋាននីមួយៗ ចំណុះអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប ដឹកនាំដោយប្រធាន១(មួយ) រូប និងអនុប្រធានមួយចំនួនជាជំនួយការ តាមការចាំបាច់។ នាយកដ្ឋាននីមួយៗមានមានការិយាល័យមួយចំនួនចំណុះតាមការចាំបាច់។ ការិយាល័យនីមួយៗ ត្រូវដឹកនាំដោយប្រធាន១(រូប) និងមានអនុប្រធានការិយាល័យមួយចំនួនជាជំនួយការ តាមការចាំបាច់។[១២៩]

## ២. ការវិវត្តនៃបច្ចេកទេសការងាររបស់ គ.ជ.ប

### ១.១ ការផ្តល់ជំនួយរបស់បរទេសសម្រាប់ការងារបោះឆ្នោត

#### ក.ជំនួយប្រទេស ជប៉ុន

មិនត្រឹមតែផ្តល់ជំនួយផ្នែកសម្ភារប៉ុណ្ណោះទេ ជប៉ុនក៏នឹងផ្តល់នូវជំនួយផ្នែកបច្ចេកទេសផងដែរសម្រាប់ គ.ជ.ប ថ្មីនេះ។ នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៤ ព្រឹទ្ធសភាជប៉ុន សន្យាថានឹង

(១២៨).ម ១៩ (១២៩). ម ២០ អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ជួយធ្វើកំណែទម្រង់ការបោះឆ្នោតនៅកម្ពុជា ដើម្បីជួយដល់ការកំណែទម្រង់នេះត្រូវបណ្តុះបណ្តាលធនធានមនុស្សឲ្យចេះរៀបចំការបោះឆ្នោតតាមប្រព័ន្ធអេឡិចត្រូនិក និង ស្នើសុំជំនួយថវិកា ដើម្បីរៀបចំកិច្ចការនេះនៅក្នុងនីតិកាលទី៦ខាងមុខ ដើម្បីឲ្យការបោះឆ្នោតប្រកបដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដែលអាចទទួលយកគ្រប់ភាគី។[១៣០]

### ខ.ជំនួយសហភាពអឺរ៉ុប

នៅក្នុងជំនួបប្រជុំថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៥ ភាគីសហភាពអឺរ៉ុបដែលដឹកនាំដោយឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបលោក Jean Francois Cautain និងភាគីជប៉ុនដឹកនាំដោយឯកអគ្គរាជទូតជប៉ុនលោក Yuji KUMAMARA ។ ជាមួយគ្នានោះ សហភាពអឺរ៉ុបគ្រោងនឹងចំណាយថវិកាប្រមាណជា ១០ លានអឺរ៉ូ ដើម្បីជួយធ្វើកំណែទម្រង់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឈានទៅលុបបំបាត់ភាពមិនប្រក្រតីក្នុងការបោះឆ្នោតនៅកម្ពុជា។[១៣១]

### គ.ជំនួយប្រទេស ចិន

សេចក្តីប្រកាសព័ត៌មានរបស់ គ.ជ.ប ឲ្យដឹងថា សម្ភារៈដែល គ.ជ.ប ទទួលបានពីរដ្ឋាភិបាលចិន ចាប់តាំងពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦ និងថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦ មានចំនួន ៣៣មុខ រួមមាន រថយន្ត ម៉ូតូ ម៉ាស៊ីនភ្លើង និងសម្ភារជាច្រើនមុខផ្សេងទៀត ដែលសម្ភារៈទាំងអស់នេះគិតជាទឹកប្រាក់សរុបជិត ១២លានដុល្លារសហរដ្ឋអាមេរិក ។ នៅព្រឹកថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៦ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានទទួលជំនួយពីរដ្ឋាភិបាលចិន ចំនួន៣៣មុខ សម្រាប់ប្រើប្រាស់ក្នុងកិច្ចការងារបោះឆ្នោតខាងមុខនេះ។ ជំនួយពីរដ្ឋាភិបាលចិន ផ្តល់ដល់ គ.ជ.ប នេះ រួមមាន ៖ រថយន្ត៨៤គ្រឿង ម៉ូតូ២៩គ្រឿង វិទ្យុទំនាក់ទំនង២៤០០គ្រឿង ម៉ាស៊ីនថតរូប២៧គ្រឿង ទូរទស្សន៍ ១០គ្រឿង កំព្យូទ័រលើតុនិងយួរដៃចំនួន៨០គ្រឿង ម៉ាស៊ីនស្កេន២គ្រឿង ព្រីនធឺរ៧៥គ្រឿង កេសសម្រាប់ដាក់សម្ភារ ២៤០០កេស វីដេអូ Conferenc២៦ ប្រព័ន្ធវីភីធើ២៨គ្រឿង បង្គោលអង់តែកម្ពស់ ៣៥ម៉ែត្រ ២គ្រឿង ស្ទីឌីយោសម្លេង ១ប្រូយិចទ័ត(Projector)៣៧គ្រឿង ឧបករណ៍បំពង់សំឡេង ៨ គ្រឿង និងសម្ភារៈការិ យាល័យជាច្រើនប្រភេទទៀត។ សម្ភារដែលរដ្ឋាភិបាលចិនផ្តល់មកគ.ជ.ប ទាំងនេះ គិតជាទឹកប្រាក់១១,៧៣០,០៣៦ ដុល្លារអាមេរិក។ ជាមួយគ្នានោះផងដែរ ឯកអគ្គរដ្ឋទូតចិនប្រចាំកម្ពុជា លោក ស្យុង ប៉ (Xiong Bo) សម្តែងក្តីជឿជាក់ថា ការរៀបចំការបោះឆ្នោតនៅកម្ពុជា

(១៣០). ការផ្សាយរបស់វិទ្យុអាស៊ីសេរីថ្ងៃទី២២ សីហា ២០១៤ ដោយ ទីន ហ្សាការីយ៉ា

(១៣១). ផ្សាយដោយកាសែតភ្នំពេញប៉ុស្តិ៍ថ្ងៃទី២៣ មិថុនា ២០១៥ ដោយ ផាត់ ស៊ាងលី

នឹងមានដំណើរការដោយរលូន។[១៣២]

## ១.២ ប្រព័ន្ធសុក្រឹតភាពសម្រាប់ប្រព័ន្ធចុះឈ្មោះអ្នកបោះឆ្នោត

ការចុះឈ្មោះបោះឆ្នោតថ្មីគឺដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មីមួយ ដែលធានាបាននូវភាពពេញលេញ ភាពត្រឹមត្រូវ និងមានសុពលភាព និងដើម្បីឲ្យប្រជាពលរដ្ឋខ្មែរមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ហើយមានសិទ្ធិបោះឆ្នោត។ គ.ជ.ប នឹងធ្វើការសាកល្បងចុះឈ្មោះតាមរយៈប្រព័ន្ធអេឡិចត្រូនិចសម្រាប់ការចុះឈ្មោះបោះឆ្នោត។ ដោយសារតែលក្ខណៈបច្ចេកទេស ក្នុងការបញ្ជូនទិន្នន័យតាមប្រព័ន្ធអ៊ីនធឺណិតរបស់មន្ត្រីចុះឈ្មោះបោះឆ្នោតនៅតាមការិយាល័យឃុំ សង្កាត់ ដែលបានផ្ញើមក គ.ជ.ប ដោយធ្វើការចុចពីរដងមក គ.ជ.ប ហើយធ្វើឱ្យបញ្ជីឈ្មោះកើនឡើង ចំនួនឈ្មោះស្ទួន។

(១៣២). ការផ្សាយរបស់គេហទំព័រ ថ្មីៗថ្ងៃទី២០ ធ្នូ ២០១៦ ដោយ រឿន ភារុន

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

សរុបជារួម ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវខាងលើ យើងអាចនិយាយបានថា ស្ថាប័នជាតិរៀបចំការបោះឆ្នោតពិតជាមានសារៈសំខាន់ណាស់ ក្នុងការធ្វើឱ្យមាននៅលំនឹងនៃលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្សពេញលេញនៅកម្ពុជា ដោយខ្លួនជាអ្នកធានាឱ្យខាងតែបានលើទំនុកចិត្ត យុត្តិធម៌ តម្លាភាព ដល់គ្រប់គណបក្សនយោបាយដែលបានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោត។ ចាប់តាំងពីកម្ពុជាស្គាល់ការបោះឆ្នោតជាលើកដំបូងក្នុងកំឡុងឆ្នាំ១៩៩៣ រួចមក កម្ពុជាបានវិវត្តខ្លួនកាន់តែប្រសើរឡើង ដោយឆ្នាំ១៩៩៨ កម្ពុជាអាចរៀបចំការបោះឆ្នោតមួយដោយខ្លួនឯង បើទោះបីជាបរិយាកាសនាពេលនោះ មិនទទួលបានការសាទរ ១០០% មជ្ឈដ្ឋានមួយចំនួនយ៉ាងណាក្តី។ ក្រោយការបោះឆ្នោតបញ្ហាចេះតែកើតមានឡើងមិនចប់មិនហើយពីអាណត្តិមួយទៅអាណត្តិមួយ ដោយ គ.ជ.ប ត្រូវបានចោទប្រកាន់ពីគណបក្សនយោបាយដែលចាញ់ឆ្នោត និងមជ្ឈដ្ឋានក្រៅរដ្ឋាភិបាលមួយចំនួនថា លួចបន្លំសន្លឹកឆ្នោត មានភាពលម្អៀង មិនឯករាជ្យ អព្យាក្រឹត តម្លាភាព និងយុត្តិធម៌នោះទេ ដោយមជ្ឈដ្ឋានទាំងនោះលើកឡើងថា ស្ថិតក្រោមឥទ្ធិពលអ្នកនយោបាយ ជាពិសេសគឺគណបក្សកាន់អំណាចតែម្តង ការនេះជាបញ្ហាដែលមានការជាប់គាំងនយោបាយនៅឆ្នាំ២០១៣។ ដើម្បីឱ្យមានដំណោះនៃការភាពជាប់គាំងនយោបាយ ស្ថាប័នជាតិរៀបចំការបោះឆ្នោតឈប់ជាបញ្ហាក្នុងការបោះឆ្នោតតទៅទៀត គណបក្សជាប់ឆ្នោតទាំងពីរគឺគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ បានមូលមាត់មូលកគ្នា តាមរយៈការចរចារនយោបាយបានឈានដល់ការកែប្រែគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតតាមរយៈកិច្ចព្រមព្រៀងនយោបាយថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤។ ជាការពិតទោះបីជាយ៉ាងណាបញ្ហាអាចនឹងមាន ប្រសិនបើ គ.ជ.ប មិនអាចអនុវត្តន៍អំណាចរបស់ខ្លួនឱ្យបានពេញលេញដូចដែលច្បាប់បានកំណត់នោះទេ ដោយមានការជ្រៀតជ្រែកពីមជ្ឈដ្ឋានខាងក្រៅ ជាពិសេសគឺការទទួលរងនូវឥទ្ធិពលនយោបាយពីមជ្ឈដ្ឋានណាមួយដែលមានឥទ្ធិពល ហើយគ.ជ.ប នឹងត្រូវបានបាត់បង់ការជឿជាក់ពីមជ្ឈដ្ឋានទូទៅផងដែរ។ ផ្ទុយទៅវិញ បើ គ.ជ.ប ប្រកាន់ភ្ជាប់ទៅតាមគោលការណ៍ច្បាប់ដូចបានកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគ.ជ.ប ព្រមទាំងគោលការណ៍មួយជាច្រើនដូចដែល គ.ជ.ប ដាក់ចេញនោះ ប្រាកដណាស់ គ.ជ.ប នឹងទទួលបាននូវការសាទរពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិទាំងក្នុង-ក្រៅប្រទេស ហើយពិតណាស់កម្ពុជានឹងពុំមានការជាប់គាំងនយោបាយតទៅទៀតហើយ ព្រោះ គ.ជ.ប ឯករាជ្យ អព្យាក្រឹត សច្ចៈ យុត្តិធម៌ និងតម្លាភាព។

# អនុសាសន៍

# អនុសាសន៍

ថ្វីត្បិត គ.ជ.ប ត្រូវបានកើតចេញពីគណបក្សនយោបាយដែលជាប់ឆ្នោតមានអាសនៈក្នុងរដ្ឋសភា ហើយបានកំណត់ក្នុងរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ជាតិ ព្រមទាំងមានបាវចនា ឯករាជ្យ អព្យាក្រឹត សច្ចៈ យុត្តិធម៌ តម្លាភាព ក៏ពិតមាន។ ក៏ប៉ុន្តែ គ.ជ.ប គួរធ្វើកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងរបស់ខ្លួនប្រកបដោយឯករាជ្យ មិនពុករលួយ បក្សពួកនិយម និងធ្វើការចំណាយថវិកាឱ្យចំគោលដៅ ប្រកបដោយតម្លាភាព និងគណនេយ្យភាព។ គ.ជ.ប ត្រូវអនុវត្តច្បាប់ដោយតម្លាភាពចំពោះគ្រប់ភាគីគណបក្សនយោបាយទាំងអស់ ដោយពុំមានភាពរុញរា ជាពិសេសនាយកដ្ឋានច្បាប់របស់ខ្លួនតែម្តង។ កន្លងមកយើងសង្កេតឃើញថា ភាពមិនប្រក្រតីមួយចំនួនដែលបានកើតឡើងពីមជ្ឈដ្ឋានខាងក្រៅបង្កឱ្យភាពការប៉ះពាល់ដល់ច្បាប់បោះឆ្នោតនោះ គ.ជ.ប តែងតែមានវិធានការភ្លាមៗ ក៏ប៉ុន្តែ គ.ជ.ប ហាក់មានភាពរុញរាក្នុងការចាត់វិធានការ ឬ ដាស់តឿនជូន គណបក្សកាន់អំណាចឡើយ នេះជាបញ្ហា។ គ.ជ.ប គួរដើរតួជាដើមបណ្តឹងចំពោះករណីណាដែល គ.ជ.ប ពិនិត្យយល់ទៅឃើញថាផ្ទុយនឹងច្បាប់ កុំចាំបាច់ទល់តែមានបណ្តឹងមកពីគណបក្សនយោបាយទើបមានវិធានការនោះ។ ដើម្បីឱ្យដំណើរការប្រកបដោយគណនេយ្យភាព ក្នុងគោលដៅលុបបំបាត់អំពើពុករលួយជាប្រព័ន្ធ គ.ជ.ប ចាំបាច់ត្រូវធ្វើវិសោធនកម្មផ្នែកហិរញ្ញវត្ថុ ព្រោះថាកាលណាការចំណាយថវិកាមិនមានគណនេយ្យភាព នាំឱ្យមានការចំនាយមិនចំគោលដៅ ជាហេតុនាំឱ្យមានភាពយឺតយ៉ាវក្នុងដំណើរការការងារ។ ពិសេសជានេះទៅគឺពិនិត្យមើលបច្ចុប្បន្នភាពការងារបុគ្គលិក ក្នុងគោលដៅពន្លឿនគុណភាពមន្ត្រីតាមផ្នែកនីមួយៗ ធ្វើការងារឱ្យបានឆាប់និងទាន់ពេលវេលា៕

# ឯកសារយោង

# ឯកសារយោង

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
- បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ១៩៩៣
- ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត, ២៦ មីនា ២០១៥
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ២០១៥
- ច្បាប់ចែងអំពីការបោះឆ្នោតនៃអង្គការសហប្រជាជាតិសម្រាប់ប្រទេសកម្ពុជា,ខែ សីហា ១៩៩២
- អនុក្រឹត្យស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ,លេខ ១០៦ អនក្រ.បក, ១០ សីហា ២០១៥

- **ឯកសារបោះពុម្ពដោយ គ.ជ.ប**
  - គ.ជ.ប, *សៀវភៅ ស ស្តីពីការបោះឆ្នោតសកលជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៥ នៃ រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា, ថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ២០១៣*
  - គ.ជ.ប, *របាយការណ៍ស្តីពីការបូកសរុបវាយតម្លៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី២ សម័យកាលបោះឆ្នោតថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ១៩៩៨* , ភ្នំពេញ, ១៩ កុម្ភៈ ១៩៩៩
  - គ.ជ.ប, *របាយការណ៍ស្តីពីការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់ សម័យបោះឆ្នោត ថ្ងៃទី ០៣ កុម្ភៈ ២០០២*
  - គ.ជ.ប, *សន្និបាតបូកសរុបការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៣ ឆ្នាំ ២០០៣*
  - គ.ជ.ប, *របាយការណ៍ស្តីពីការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសតាំង តំណាងរាស្ត្រ អាណត្តិទី៤ ឆ្នាំ២០០៨*
  - គ.ជ.ប, *របាយការណ៍ស្តីពីការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី ២ សម័យបោះឆ្នោតថ្ងៃអាទិត្យ មេសា ២០០៧*
  - គ.ជ.ប, *របាយការណ៍ស្តីពីការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សា អាណត្តិទី១ ឆ្នាំ២០០៩*
  - គ.ជ.ប, *របាយការណ៍ស្តីពី ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតឡើងវិញ ជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ ឆ្នាំ២០១១*
  - គ.ជ.ប, *សន្និបាតបូកសរុបការងារបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ឆ្នាំ ២០១៣ ខេត្តព្រះសីហនុ ថ្ងៃទី២១-២២ ខែវិច្ឆិកា ឆ្នាំ២០១៣*

- គ.ជ.ប, *របាយការណ៍បូកសរុបការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត និង ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ អាណត្តិទី២ ឆ្នាំ២០១៤ ខេត្តព្រះសីហនុ ថ្ងៃទី០៩-១០ មិថុនា ២០១៤*

- **វេបសាយ**

  - វិទ្យុអាស៊ីសេរី http://www.rfa.org/khmer (ចូលទស្សនាថ្ងៃទី ១០ មីនា ២០១៧)
  - កាសែតភ្នំពេញប៉ុស្តិ៍ http://www.m.postkhmer.com (ចូលទស្សនាថ្ងៃទី ២០ មីនា ២០១៧)
  - គេហទំព័រថ្មីៗ http://www.thmeythmey.com (ចូលទស្សនាថ្ងៃទី ២០ មីនា ២០១៧)
  - អង្គការទិន្នន័យអំពីការអភិវឌ្ឍ https://opendevelopmentcambodia.net/km/tag/elections/ (ចូលទស្សនាថ្ងៃទី ១៨ មីនា ២០១៧)

# ឧបសម្ព័ន្ធ

FROM : CHEA SIM OFFICE PHONE NO. : 855 23 426058 Jan. 30 1998 05:02PM P1

នស/រកត/០១៩៨/០៤២

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ព្រះរាជក្រឹត្យ

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី

*******

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី២០ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៨៣ ចុះថ្ងៃទី ២៤ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខនស.រកត.០៨៩៧.១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស.រកម.១១៩៧.០៧ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ស្តីពីគណបក្សនយោបាយ

-បានឃើញព្រះរាជក្រមលេខ ន. ស. រកម. ១២៩៧. ០៦ ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-យោងតាមសេចក្តីក្រាបបង្គំទូលស្នើសុំ ពីឯកឧត្តមនាយករដ្ឋមន្ត្រីទី១ និង សម្តេចនាយករដ្ឋមន្ត្រីទី ២

-យោងលិខិតលេខ ០៦ សេ ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ ១៩៩៨ ស្តីពីលទ្ធផលនៃការបោះឆ្នោតសំងាត់ការទុកចិត្តលើសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

# ព្រះរាជបង្គាប់

មាត្រា១: តែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ២ ដែលមានសមាសភាពដូចតទៅនេះ :

| | | |
|---|---|---|
| ១- ឯកឧត្តម | ជេង ផុន | ប្រធាន |
| ២- ឯកឧត្តម | នៅ កាស៊ី | អនុប្រធាន |
| ៣- ឯកឧត្តម | ង៉ូ កុងនួន | សមាជិក |
| ៤- ឯកឧត្តម | យូ គន | សមាជិក |
| ៥- ឯកឧត្តម | តា ចំពីត់ | សមាជិក |
| ៦- ឯកឧត្តម | ព្រហ្ម ញាណវិចិត្រ | សមាជិក |
| ៧- ឯកឧត្តម | កែ ឡុងឌី | សមាជិក |
| ៨- ឯកឧត្តម | អ៊ឹង គីមហេង | សមាជិក |
| ៩- ឯកឧត្តម | ម៉ាយ គីម | សមាជិក |
| ១០- ឯកឧត្តម | ទិព ចន្ទវិបុល | សមាជិក |
| ១១- ឯកឧត្តម | ជា ចំរើន | សមាជិក |

មាត្រា២ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ :

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមករា ឆ្នាំ ១៩៩៨

ក្នុងព្រះបរមនាម និង តាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

អ៊ឹង ហួត ហ៊ុន សែន

# ព្រះរាជក្រឹត្យ

នស/រកត/០៥.៩៩/៩៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

០០០

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា១ : តែងតាំងលោកឧត្តម អ៊ឹម សួស្តី ជាអគ្គលេខាធិការ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានឋានៈ និងបុព្វសិទ្ធិស្មើអនុរដ្ឋលេខាធិការ ។

មាត្រា២ : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តព្រះរាជក្រឹត្យនេះ [illegible] ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ មានអានុភាពចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

លេខ : ៩៦ ច.ល នរោត្តម សីហនុ

ធ្វើនៅថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៩៩

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ១៩៩៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

# ព្រះរាជក្រឹត្យ

នស/រកត/០៦៩៨/៣៤

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម

## ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខជស/រកត/០៨៩៧,១៨៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ន.ស.រកម ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- យោងតាមសំណើរបស់ព្រឹទ្ធាចារ្យ ចេង ផុន ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ០៥-៥៥៨ / ៩៨ ចុះថ្ងៃទី ០៨ ខែឧសភា ឆ្នាំ ១៩៩៨
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា លេខ ៧៥ លស ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ១៩៩៨

## ត្រាស់បង្គាប់

មាត្រា ១ : តែងតាំង

១ - ឯកឧត្តម អ៊ឹម សូស្ថិ ជាអគ្គលេខាធិការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានឋានៈនិងបុព្វសិទ្ធិ ស្មើអគ្គនាយកក្រសួង ។

២ - ឯកឧត្តម ស៊ិន ម៉ុនហុក ជាទីប្រឹក្សាអមឯកឧត្តមប្រធានគណកម្មាធិការជាតិរៀបចំការបោះឆ្នោត ទទួលបន្ទុកការងារបណ្តុះបណ្តាលនិងអប់រំសាធារណៈជន មានឋានៈ និង បុព្វសិទ្ធិ ស្មើនឹងអនុរដ្ឋលេខាធិការ ។

៣ - ឯកឧត្តម ស៊ឹង ភំសាន្ត ជាទីប្រឹក្សារបស់ឯកឧត្តមប្រធានគណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត ទទួលបន្ទុកជាអ្នកនាំពាក្យរបស់ប្រធានគណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត មានឋានៈនិងបុព្វសិទ្ធិ ស្មើនឹងអនុរដ្ឋលេខាធិការ ។

៤ - ឯកឧត្តម ទែម ទុឡ្សារ ជាទីប្រឹក្សារបស់ឯកឧត្តមប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទទួលបន្ទុកកិច្ចការលេខាធិការដ្ឋាន និង តាមដានសកម្មភាពប្រតិបត្តិការ នៃការងារបោះឆ្នោត មានឋានៈនិងបុព្វសិទ្ធិ ស្មើនឹងអនុរដ្ឋលេខាធិការ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុក អនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

---

ធ្វើនៅសៀមរាប ថ្ងៃទី១៦ ខែ មិថុនា ឆ្នាំ [illegible]

ព្រះរាជហត្ថលេខា

នរោត្តម សីហនុ

លេខ : ១៣៧៥ច រប

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៩៨

[illegible]ជាតិធរ

[illegible]វ៉ាន់

# ព្រះរាជក្រឹត្យ

នស/រកត/១០០២/៣០០

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

-បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៨/០៤២ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ២

-បានទ្រង់យល់លិខិតលេខ ៩៣៥ រស របស់រដ្ឋសភា ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០២ ស្តីពីលទ្ធផលនៃការបោះឆ្នោត សម្តែងការយល់ព្រមលើ សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះ ឆ្នោត

-បានទ្រង់យល់សំណើរបស់សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៣ ដែលមានសមាសភាពដូចតទៅនេះ :

១- ឯកឧត្តម អ៊ឹម សួស្តី ប្រធាន

២- ឯកឧត្តម ទៀ នាយលាង អនុប្រធាន

៣- ឯកឧត្តម ទាន សារ៉ាដិ សមាជិក

៤- លោកជំទាវ ទុយ ទើត សមាជិកា

៥- លោកជំទាវ ស៊ុន ជុំប្រុ សមាជិកា

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងឯកឧត្តម លោកជំទាវ ដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុក អនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពី ថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែតុលា ឆ្នាំ ២០០២

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

ពរល-០២.១០.០០៣១៧

បានក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

លេខ : ៧១៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០១០៣/០៣១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម នេព នីថា ជាអគ្គលេខាធិការ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងជាទីប្រឹក្សា របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលមានឋានៈនិងបុព្វសិទ្ធិ ស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ : រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ: ១៩ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមករា ឆ្នាំ២០០៣

អគ្គលេខាធិការរាជរដ្ឋាភិបាល

រកល.០៣.០១.០៣១

ទាំព្រះរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៣

នស/រកត/០៧០៦/៣០៥

# ព្រះរាជក្រឹត្យ

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតូបជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីច្បាប់វិសោធនកម្មច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មមាត្រា ១៣ថ្មី នៃច្បាប់ស្តីពីច្បាប់វិសោធនកម្មច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០០២/៣០០ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០២ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៣
- បានទ្រង់យល់លិខិតលេខ ៧៧១ រស ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៥ របស់រដ្ឋសភា ស្តីពីលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងសមាសភាពគណៈគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានទ្រង់យល់សំណើរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលមានសមាសភាពដូចតទៅនេះ :

១-ឯកឧត្តម អ៊ឹម សូស្តី ប្រធាន

២-លោកជំទាវ ស៊ុន ជុំបូ អនុប្រធាន

៣-លោកជំទាវ កុយ ទើត សមាជិកា

៤-ឯកឧត្តម ឃ្លោក ប៊ុតឌី សមាជិក

៥-ឯកឧត្តម ហាទ៉ាណា ស៊ីទិល័យ សមាជិក

៦-ឯកឧត្តម មាន សនិ សមាជិក

៧-ឯកឧត្តម ឯម សូផាត សមាជិក

៨-ឯកឧត្តម សោម ច័ន្ទឌីណា សមាជិក

៩-ឯកឧត្តម ម៉ៅ សុគារិទ្ធ សមាជិក

**មាត្រា២** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និង ឯកឧត្តម លោកជំទាវ ដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤** : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៦*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*នស.០៦០៧.៣២៦*

បានក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ : ២ ៧៩៦.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០០៦

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ខួនស៊ុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/១០១២/៩៤៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
-បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីច្បាប់វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
-បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០៦០៦/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៣ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
-បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
-បានទ្រង់យល់សម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៤ នាថ្ងៃព្រហស្បតិ៍ទី១១ ខែតុលា ឆ្នាំ២០១២ ស្តីពីលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងប្រធាន អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចំនួន៩រូប
-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលមានសមាសភាពដូចតទៅ៖

| | | |
|---|---|---|
| ១-ឯកឧត្តម | **អ៊ឹម សូស្ថី** | ប្រធាន |
| ២-លោកជំទាវ | **ស៊ីន ជុំបូ** | អនុប្រធាន |
| ៣-ឯកឧត្តម | **ហាង៉ាណា ស៊ីទិល័យ** | សមាជិក |
| ៤-ឯកឧត្តម | **មាន សាធិ** | សមាជិក |
| ៥-ឯកឧត្តម | **ឯម សូផាត** | សមាជិក |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

៦-ឯកឧត្តម សោម ច័ន្ទឌីណា សមាជិក

៧-ឯកឧត្តម ម៉ៅ សុភារិទ្ធ សមាជិក

៨-ឯកឧត្តម ស៊ិន ឌីម សមាជិក

៩-ឯកឧត្តម សោ សុភរី សមាជិក។

មាត្រា ២ : សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកត.១០១២/៩៩៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១២

លេខ: ៤៩០០ប.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១២

អគ្គលេខាធិការរងទីស្ដីការគណៈរដ្ឋមន្ត្រី

ស៊យ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៥/៣២៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតួមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឲ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុង នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៥ នៃរដ្ឋសភា នាថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ ថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានទ្រង់យល់លទ្ធផល នៃការបោះឆ្នោតទុកចិត្តប្រធាន អនុប្រធាន និងសមាជិក សមាជិកា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយអង្គសភា កាលពីថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១៥
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា។

## ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំងជាប្រធាន អនុប្រធាន និងសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតសម្រាប់អាណត្តិថ្មី ដែលមានរាយនាមដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម | ស៊ិក ប៊ុនហុក | ប្រធាន |
| ២- ឯកឧត្តម | គួយ ប៊ុនរឿន | អនុប្រធាន |
| ៣- ឯកឧត្តម | មាន សទិ | សមាជិក |
| ៤- ឯកឧត្តម | រ៉ុង ឈុន | សមាជិក |
| ៥- ឯកឧត្តម | ឌុច សុន | សមាជិក |
| ៦- ឯកឧត្តម | ហ៊ីង ធីឫទ្ធិ | សមាជិក |
| ៧- ឯកឧត្តម | ឯម សុផាត | សមាជិក |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៨- លោកជំទាវ តែ ម៉ានីរ៉ុន                    សមាជិកា

៩- ឯកឧត្តម ហាន់ ពុទ្ធា                    សមាជិក

**មាត្រា២ :** បទប្បញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣ :** សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស/រកត/០៤១៥/៣៣០

ធ្វើនៅ, ថ្ងៃទី ១០ ខែ មេសា ឆ្នាំ២០១៥

លេខ: ៣៤៣ ស.ណ

សំណៅដែលបានចម្លងត្រឹមត្រូវជាការចែកផ្សាយ

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ មេសា ឆ្នាំ២០១៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊យ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០១១៦/០៩៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៥/៣២៧ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៥/៦៤៨ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីរាជការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ទាប់ពីបានយោបល់យល់ស្របពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំង ៖

១- ឯកឧត្តម **ទេព នីថា** ជាអគ្គលេខាធិការ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានឋានៈ និងបុព្វសិទ្ធិស្មើនឹងរដ្ឋលេខាធិការ

២- ឯកឧត្តម **ម៉ៅ សុភារិទ្ធ** ជាអគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានឋានៈ និងបុព្វសិទ្ធិស្មើនឹងអនុរដ្ឋលេខាធិការ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

៣- ឯកឧត្តម **សោម សូរីដា** ជាអគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានឋានៈ និងបុព្វសិទ្ធិស្មើនឹងអនុរដ្ឋលេខាធិការ

៤- ឯកឧត្តម **នី ចរិយា** ជាអគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានឋានៈ និងបុព្វសិទ្ធិស្មើនឹងអនុរដ្ឋលេខាធិការ

៥- ឯកឧត្តម **ម៉ុក ដារ៉ា** ជាអគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានឋានៈ និងបុព្វសិទ្ធិស្មើនឹងអនុរដ្ឋលេខាធិការ។

**មាត្រា២** : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣** : ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត.០១១៦.០៣៦

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៦*

លេខ ៦ ស.ណ

សំណៅដែលមានអត្ថន័យស្មើនឹងសារការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី ខែមករា ឆ្នាំ២០...

...រដ្ឋាភិបាល

សយ សុខា

# សេចក្តីប្រកាសរួមនៃកិច្ចប្រជុំ
## រវាងក្រុមការងារគណបក្សប្រជាជនកម្ពុជា និងក្រុមការងារគណបក្សសង្គ្រោះជាតិ

*(វិមានព្រឹទ្ធសភា ថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០១៤)*

អនុវត្តតាមស្មារតីសេចក្តីប្រកាសរួមនៃជំនួបកំពូលរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣ ក្រុមការងារគណបក្សប្រជាជនកម្ពុជា និងក្រុមការងារគណបក្សសង្គ្រោះជាតិ បានជួបពិភាក្សាគ្នា នៅវិមានព្រឹទ្ធសភា នាថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ២០១៤ ដោយបានព្រមព្រៀងគ្នាលើចំណុចសំខាន់ៗដូចខាងក្រោម ៖

១-ស្នើបង្កើតគណៈកម្មការចម្រុះមួយដោយមានសមាសភាពស្មើគ្នា មកពីគណបក្សដែលមានអាសនៈក្នុងរដ្ឋសភា ដើម្បីសិក្សា និងរៀបចំក្របខណ្ឌកំណែទម្រង់ការបោះឆ្នោតនាពេលខាងមុខ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ សំដៅធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅប្រកបដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។

២-ដើម្បីរៀបចំក្របខណ្ឌកំណែទម្រង់ការបោះឆ្នោតនេះ គណៈកម្មការចម្រុះត្រូវរៀបចំឱ្យមានសិក្ខាសាលាជាតិមួយ ដើម្បីបើកទូលាយឱ្យមានការចូលរួមយោបល់ និងអនុសាសន៍នានាពីសំណាក់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ រួមទាំងដៃគូអភិវឌ្ឍន៍ គណបក្សនយោបាយដែលបានចុះបញ្ជី សង្គមស៊ីវិលដែលមានជំនាញលើការងារបោះឆ្នោត ព្រមទាំងតួអង្គពាក់ព័ន្ធ។ ទន្ទឹមនេះ ត្រូវបង្កលក្ខណៈឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការផ្តល់មតិយោបល់សម្រាប់ការកែទម្រង់ការបោះឆ្នោត ជាអាទិ៍ តាមរយៈវេទិកាសាធារណៈ។

៣-ក្នុងកិច្ចដំណើរការនៃកំណែទម្រង់ការបោះឆ្នោតនេះ ត្រូវបង្កលក្ខណៈឱ្យមានការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍ និងអង្គការជាតិ និងអន្តរជាតិនានា។

ក្រុមការងារទាំងពីរនឹងរាយការណ៍អំពីលទ្ធផលនៃកិច្ចប្រជុំនេះ ជូនថ្នាក់ដឹកនាំគណបក្សរៀងៗខ្លួន ហើយបានឯកភាពបន្តជួបគ្នាលើកក្រោយទៀត ដើម្បីឈានទៅដល់ជំនួបកំពូលរវាងគណបក្សទាំងពីរ។

ប្រធានក្រុមការងារគណបក្សប្រជាជនកម្ពុជា

**ប្រាំ សុខា**

ប្រធានក្រុមការងារគណបក្សសង្គ្រោះជាតិ

**សុន ឆ័យ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្តីប្រកាសរួម
# នៃកិច្ចប្រជុំគណៈកម្មការចម្រុះ
# ដើម្បីសិក្សា និងរៀបចំក្របខ័ណ្ឌកំណែទម្រង់ការបោះឆ្នោត នាពេលខាងមុខ

*(វិមានព្រឹទ្ធសភា ថ្ងៃទី០៣ ខែមិនា ឆ្នាំ២០១៤)*

-អនុវត្តតាមស្មារតីសេចក្តីថ្លែងការណ៍រួម នៃជំនួបកំពូលរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣។

-អនុវត្តតាមស្មារតីសេចក្តីប្រកាសរួម នៃកិច្ចប្រជុំរវាងក្រុមការងារគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤។

គណៈកម្មការចម្រុះមកពីគណបក្សទាំងពីរដែលមានអាសនៈក្នុងរដ្ឋសភា បានជួបប្រជុំគ្នាជាលើកដំបូង នៅថ្ងៃទី០៣ ខែមិនា ឆ្នាំ២០១៤ នៅវិមានព្រឹទ្ធសភា ហើយបានឯកភាពលើចំណុចដូចខាងក្រោម៖

១-ការរៀបចំ ការចុះឈ្មោះអ្នកបោះឆ្នោត និងបញ្ជីឈ្មោះអ្នកបោះឆ្នោត ដើម្បីធានានិងការពារសិទ្ធិបោះឆ្នោតរបស់ប្រជាពលរដ្ឋគ្រប់រូប។

២-រៀបចំបង្កើតច្បាប់ ស្តីពីហិរញ្ញវត្ថុរបស់គណបក្សនយោបាយ។

៣-ក្របខ័ណ្ឌកំណែទម្រង់ការបោះឆ្នោតផ្សេងៗទៀត ដូចជា៖

-ការកែទម្រង់ស្ថាប័នរៀបចំការបោះឆ្នោត

-យន្តការនៃការដោះស្រាយវិវាទ នៃការបោះឆ្នោត

-ប្រព័ន្ធផ្សព្វផ្សាយ និងគោលនយោបាយផ្សព្វផ្សាយសម្រាប់គណបក្សនយោបាយ

-...។ល។

គណៈកម្មការចម្រុះបានឯកភាពនឹងយកទៅពិភាក្សាលើកក្រោយទៀតនៅថ្ងៃច័ន្ទ ទី១០ ខែមិនា ឆ្នាំ២០១៤ វេលាម៉ោង ០៩:០០ ព្រឹក នៅវិមានព្រឹទ្ធសភា។

**តំណាងគណៈកម្មការចម្រុះ**

**ប៊ិន ឈិន** **សុន ឆ័យ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សេចក្តីប្រកាសរួម**
**នៃកិច្ចប្រជុំគណៈកម្មការចម្រុះ**
**ដើម្បីសិក្សា និងរៀបចំក្របខ័ណ្ឌកំណែទម្រង់ការបោះឆ្នោត នាពេលខាងមុខ**
*(វិមានព្រឹទ្ធសភា ថ្ងៃទី១៧ ខែមិនា ឆ្នាំ២០១៤)*

-អនុវត្តតាមស្មារតីសេចក្តីថ្លែងការណ៍រួម នៃជំនួបកំពូលរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣។

-អនុវត្តតាមស្មារតីសេចក្តីប្រកាសរួម នៃកិច្ចប្រជុំរវាងក្រុមការងារគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤។

-អនុវត្តតាមស្មារតីសេចក្តីប្រកាសរួម នៃកិច្ចប្រជុំគណៈកម្មការចម្រុះ ដើម្បីសិក្សា និងរៀបចំក្របខ័ណ្ឌកំណែទម្រង់ការបោះឆ្នោត នាពេលខាងមុខ កាលពីថ្ងៃទី០៣ ខែមិនា ឆ្នាំ២០១៤ និងតាមស្មារតី នៃកិច្ចប្រជុំរវាងក្រុមការងារគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ កាលពីថ្ងៃទី១០ ខែមិនា ឆ្នាំ២០១៤។

គណៈកម្មការចម្រុះមកពីគណបក្សទាំងពីរដែលមានអាសនៈក្នុងរដ្ឋសភា បានជួបប្រជុំគ្នានៅថ្ងៃទី១៧ ខែមិនា ឆ្នាំ២០១៤ វេលាម៉ោង៩:០០ នាទីព្រឹក នៅវិមានព្រឹទ្ធសភា និងបានព្រមព្រៀងបញ្ចូលក្នុងក្របខ័ណ្ឌកំណែទម្រង់ការបោះឆ្នោតនូវប្រធានបទសរុបចំនួន១៤ ដូចខាងក្រោម៖

-ការរៀបចំ ការចុះឈ្មោះអ្នកបោះឆ្នោត និងបញ្ជីឈ្មោះអ្នកបោះឆ្នោត ដើម្បីធានាសិទ្ធិបោះឆ្នោតរបស់ប្រជាពលរដ្ឋគ្រប់រូប
-រៀបចំបង្កើតច្បាប់ ស្តីពីហិរញ្ញវត្ថុរបស់គណបក្សនយោបាយ
-កំណែទម្រង់ស្ថាប័នរៀបចំការបោះឆ្នោត
-អព្យាក្រឹត្យភាព និងសុចរិតភាព នៃអង្គការសង្គមស៊ីវិល
-ប្រព័ន្ធផ្សព្វផ្សាយ និងមធ្យោបាយផ្សព្វផ្សាយរបស់គណបក្សនយោបាយ
-យន្តការ នៃការដោះស្រាយវិវាទ
-ការសង្កេតការណ៍បោះឆ្នោត
-អព្យាក្រឹត្យភាព នៃមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ



-កាលបរិច្ឆេទ នៃការបោះឆ្នោត
-បទបញ្ជា និងនីតិវិធី នៃការបោះឆ្នោត
-កែសម្រួល និងពង្រឹងទោសប្បញ្ញត្តិ នៅក្នុងច្បាប់បោះឆ្នោត
-ការឃោសនាបោះឆ្នោត
-ការបោះឆ្នោតមេភូមិ
-ការស្ទង់មតិ ។

គណៈកម្មការចម្រុះបានឯកភាពនឹងជួបពិភាក្សាលើកក្រោយទៀតនៅថ្ងៃទី២៤ ខែមិនា ឆ្នាំ២០១៤ វេលាម៉ោង០៩:០០ នាទីព្រឹក នៅវិមានព្រឹទ្ធសភា ដើម្បីពិភាក្សាកំណត់អាទិភាពនៃប្រធានបទកំណែទម្រង់ការបោះឆ្នោត ព្រមទាំងបែបបទនៃការរៀបចំសិក្ខាសាលាថ្នាក់ជាតិ និងវេទិកាសាធារណៈ។

**តំណាងគណៈកម្មការចម្រុះ**

**ប៊ិន ឈិន** **សុន ឆ័យ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កំណត់ហេតុ
## ស្តីពី
## នៃកិច្ចប្រជុំក្រុមការងារពិសោធនកម្មច្បាប់បោះឆ្នោត
## របស់គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ

នៅថ្ងៃទីបួន ខែសីហា ឆ្នាំពីរពាន់ដប់បួន វេលាម៉ោងប្រាំបួនព្រឹក នៅវិមានរដ្ឋសភា ក្រុមការងារពិសោធនកម្មច្បាប់បោះឆ្នោតរបស់គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ បានប្រជុំពិភាក្សា នៅលើគោលការណ៍មួយចំនួន ដែលបានព្រមព្រៀងគ្នាកាលពីថ្ងៃទី២២ ខែ កក្កដា ឆ្នាំ ២០១៤។ សមាសភាពចូលរួមក្នុងកិច្ចប្រជុំមានដូចខាងក្រោម៖

**ក-ក្រុមការងារគណបក្សប្រជាជនកម្ពុជា៖**

- ឯកឧត្តម **ប៊ិន ឈិន** ប្រធាន
- ឯកឧត្តម **ជាម យៀប** សមាជិក
- ឯកឧត្តម **ស៊ុក ប៊ុងហុក** សមាជិក
- លោកជំទាវ **ក្រូច សំអេង** សមាជិកា
- ឯកឧត្តម **សក់ សេដ្ឋា** សមាជិក

**ខ-ក្រុមការងារគណបក្សសង្គ្រោះជាតិ៖**

- ឯកឧត្តម **គួយ ប៊ុនរឿន** ប្រធាន
- ឯកឧត្តម **អេង ឆៃអ៊ាង** សមាជិក
- ឯកឧត្តម **ឡុង រី** សមាជិក
- កញ្ញា **ទីវ សុវ៉ាចិត្រា** សមាជិកា
- ឯកឧត្តម **ម៉េង ពុទ្ធារិទ្ធ** អ្នកកត់

ក្រោយពីបានពិភាក្សាលើចំណុចខាងលើរួចមក ក្រុមការងារគណបក្សទាំងពីរបានឯកភាពគ្នាលើគោលការណ៍មួយចំនួនដូចខាងក្រោម៖

១-រៀបចំការប្រជុំពេញអង្គរដ្ឋសភា បន្ទាប់ពីបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិចូលធ្វើសច្ចាប្រណិធាននៅព្រះបរមរាជវាំង និងចូលរួមប្រជុំនៅក្នុងរដ្ឋសភា ដើម្បី៖

- បោះឆ្នោតអនុម័តលើសេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុង នៃរដ្ឋសភា
- បោះឆ្នោតជ្រើសតាំងសមាសភាពថ្នាក់ដឹកនាំរដ្ឋសភាតាមស្មារតី នៃកិច្ចព្រមព្រៀង ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៤។

អនុម័តសេចក្តីស្នើច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មរដ្ឋធម្មនុញ្ញត្រង់ មាត្រា ៧៦ និងបង្កើតជំពូកថ្មី ១៥ ថ្មី ទាក់ទងនឹងអង្គការរៀបចំការបោះឆ្នោត

-ធ្វើការបោះឆ្នោតជ្រើសតាំងសមាសភាព គណៈកម្មការជាតិរៀបចំការបោះឆ្នោតថ្មី ដើម្បីឱ្យគណៈកម្មការនេះចូលរួមរៀបចំសេចក្តីព្រាង សេចក្តីស្នើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មការជាតិរៀបចំការបោះឆ្នោត និងសេចក្តីព្រាងសេចក្តីស្នើវិសោធនកម្មច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

២-ក្រុមការងារគណបក្សទាំងពីរបានឯកភាពគ្នា ក្រោយពីច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មរដ្ឋធម្មនុញ្ញត្រូវបានអនុម័ត និងចូលជាធរមាន ត្រូវរៀបចំ៖

-សេចក្តីព្រាងសេចក្តីស្នើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មការជាតិរៀបចំការបោះឆ្នោត។

-សេចក្តីព្រាងសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

៣-ចំពោះបញ្ហាស្វ័យភាព ការរៀបចំមន្ត្រីបោះឆ្នោតនៅថ្នាក់ក្រោមជាតិ អង្គប្រជុំបានសម្រេចឱ្យគណៈកម្មការជាតិរៀបចំការបោះឆ្នោតថ្មី លើកយកបញ្ហាដាក់ក្នុងសេចក្តីស្នើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការជាតិរៀបចំការបោះឆ្នោត។

ក្រុមការងារទាំងពីរបានឯកភាពគ្នានឹងបន្តកិច្ចប្រជុំនៅលើកក្រោយ បន្ទាប់ពីរដ្ឋសភាបានរៀបចំបង្កើតគណៈកម្មការជាតិរៀបចំការបោះឆ្នោតថ្មីបានពេញលេញគ្រប់។ ក្នុងករណីចាំបាច់ ក្រុមការងារ នៃគណបក្សទាំងពីរអាចប្រជុំជាបន្ទាន់។

ក្រុមការងារ នៃគណបក្សទាំងពីរបានឯកភាព ធ្វើសេចក្តីរាយការណ៍ពីលទ្ធផល នៃកិច្ចប្រជុំនេះជូនថ្នាក់ដឹកនាំគណបក្សរៀងៗខ្លួន។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោងដប់មួយ និងសែសិបប្រាំនាទី ថ្ងៃ ខែ ឆ្នាំ ដដែល ក្នុងបរិយាកាសរីករាយ ស្និទ្ធស្នាល និងទទួលខុសត្រូវខ្ពស់។

**ក្រុមការងារគណបក្សប្រជាជនកម្ពុជា**

**ប៊ិន ឈិន**

**ក្រុមការងារគណបក្សសង្គ្រោះជាតិ**

**គួយ ប៊ុនរឿន**

**គណបក្សប្រជាជនកម្ពុជា**
គណៈកម្មាធិការកណ្តាល

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ
អព្យាក្រឹត និង វិឡុនភាពសង្គម

# សេចក្តីថ្លែងការណ៍
# របស់គណបក្សប្រជាជនកម្ពុជា

ជនរួមជាតិជាទីគោរពស្នេហា !

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ៥ កាលពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៣ កន្លងទៅនេះ បានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងគោលការណ៍ប្រជាធិបតេយ្យ ។ នៅក្នុងបរិយាកាសនយោបាយប្រកបដោយសន្តិភាព សេរី និងតម្លាភាព ប្រជាជនកម្ពុជាដែលមានឈ្មោះក្នុងបញ្ជីអ្នកបោះឆ្នោតយ៉ាងច្រើនកុះករបំផុតបានអនុវត្តនូវសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនក្នុងភាពជាម្ចាស់ ប្រកបដោយកិត្តិយស សេចក្តីថ្លៃថ្នូរ និងការទទួលខុសត្រូវ ដើម្បីជ្រើសរើសគណបក្សនយោបាយ និងតំណាងរបស់ខ្លួនធ្វើមឱ្យដឹកនាំប្រទេសសម្រាប់រយៈពេល ៥ឆ្នាំបន្តទៀតស្របទៅតាមឆន្ទៈរបស់ខ្លួន។ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិបានអបអរសាទរ និងធ្វើការវាយតម្លៃប្រកបដោយភាពវិជ្ជមានក្រៃលែងចំពោះការបោះឆ្នោតនេះ ហើយបានធ្វើការកត់សម្គាល់ថា ទោះបីជាមានបញ្ហាខ្វះខាតតិចតួចក្តី ក៏ពុំបានធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតឡើយ ។ នេះជាសមិទ្ធផលជាប្រវត្តិសាស្ត្រថ្មីមួយទៀតរបស់ជាតិយើង ដែលបានឆ្លុះបញ្ចាំងឱ្យឃើញនូវភាពចាស់ទុំនៃប្រជាធិបតេយ្យនៅកម្ពុជា និងបំណងប្រាថ្នារបស់ប្រជាជន ដើម្បីបន្តស្ថាបនាសង្គមជាតិរបស់ខ្លួនប្រកបដោយសន្តិភាព សេរីភាព សមភាព យុត្តិធម៌ និងវឌ្ឍនភាព ដែលរួចចាកផុតពីភាពក្រីក្រ ។

នៅក្នុងឱកាសនេះ គណបក្សប្រជាជនកម្ពុជា សូមប្រកាសជាឧឡារិក**ទទួលយកលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ៥** ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានប្រកាសនាថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៣ នេះ ហើយប្តេជ្ញាការពារលទ្ធផលនៃការបោះឆ្នោតនេះ ដែលបានកើតចេញពីឆន្ទៈរបស់ប្រជាជនពិតប្រាកដ ។

គណបក្សប្រជាជនកម្ពុជាសូមសម្តែងនូវការគោរព និងដឹងគុណដ៏ជ្រាលជ្រៅបំផុតចំពោះជនរួមជាតិនៅគ្រប់ទិសទី ដែលបានផ្តល់យុត្តិធម៌ចំពោះការដឹកនាំរបស់គណបក្សរយៈពេលជិត ៣៥ឆ្នាំមកនេះ ហើយបានបន្តបោះឆ្នោតគាំទ្រឱ្យគណបក្សទទួលបានជ័យជម្នះជាថ្មីទៀត ។ ប្រការនេះបានបង្ហាញយ៉ាងច្បាស់ថា ប្រជាជនកម្ពុជានៅតែមានជំនឿទុកចិត្តយ៉ាងមុតមាំមកលើគណបក្សប្រជាជនកម្ពុជា ក្នុងការដឹកនាំ កសាង និងការពារមាតុភូមិតទៅមុខទៀត ទោះបីជាមានមជ្ឈដ្ឋានអគតិខ្លះបានខិតខំរកគ្រប់វិធី ដើម្បីបំបែកបំបាក់ចំណងទាក់ទងដ៏ស្អិតរមួត រវាងគណបក្ស និងប្រជាជនយ៉ាងណាក្តី ។

គណបក្សប្រជាជនកម្ពុជា សូមវាយតម្លៃខ្ពស់ចំពោះការខិតខំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានជំនះរាល់ការលំបាកស្មុគស្មាញនានាក្នុងការបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន ធានាឱ្យដំណើរការរៀបចំការបោះឆ្នោតទាំងមូលបានប្រព្រឹត្តទៅយ៉ាងល្អប្រសើរ និងទៀងទាត់តាមប្រតិទិនការងារ ដោយប្រកាន់ខ្ជាប់នូវជំហរ

ឯករាជ្យ អព្យាក្រឹត និងតម្លាភាព លើមូលដ្ឋានអនុវត្តយ៉ាងត្រឹមត្រូវ តាមច្បាប់ បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត។ ព្រមជាមួយនេះ សូមវាយតម្លៃខ្ពស់ចំពោះរាជរដ្ឋាភិបាល គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដែលបានយកអស់លទ្ធភាពជួយគាំទ្រដល់កិច្ចដំណើរការរៀបចំការបោះឆ្នោត និងការពារស្ថិរភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈបានល្អប្រសើរ ទាំងក្នុងពេលយុទ្ធនាការឃោសនា ពេលបោះឆ្នោត ក៏ដូចក្រោយពេលបោះឆ្នោត។

ទន្ទឹមនេះក្នុងនាមប្រជាជនកម្ពុជា សូមសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបណ្តាប្រទេសជាមិត្ត សហគមន៍អន្តរជាតិ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ និងមជ្ឈដ្ឋាននានាក្នុងសង្គម ដែលបានចូលរួមសង្កេតការណ៍ និងសម្តែងការអបអរសាទរចំពោះជោគជ័យនៃដំណើរការបោះឆ្នោតនៅកម្ពុជា។ វិភាគទានដ៏ថ្លៃថ្លានេះ ជាកត្តាលើកទឹកចិត្តដ៏សំខាន់ចំពោះដំណើរការនៃប្រជាធិបតេយ្យនៅកម្ពុជាទាំងក្នុងពេលបច្ចុប្បន្ន ក៏ដូចតទៅមុខទៀត ។

ជនរួមជាតិជាទីគោរពស្នេហា ដើម្បីឆ្លើយតបទៅនឹងការជឿទុកចិត្តរបស់ជនរួមជាតិ គណបក្សប្រជាជនកម្ពុជា សូមសន្យាថា នឹងប្រមូលផ្តុំគ្រប់កម្លាំង និងលទ្ធភាពទាំងអស់របស់ខ្លួន ដើម្បីអនុវត្តនូវកម្មវិធីនយោបាយដែលបានប្រកាសជូនជនរួមជាតិរួចមកហើយ សំដៅសម្រេចនូវគោលដៅធំៗទាំងឡាយគឺ ការការពារឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដីនៃមាតុភូមិ ការថែរក្សាសន្តិភាព ស្ថិរភាព សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ការបន្តអនុវត្តកំណែទម្រង់រដ្ឋដ៏ស៊ីជម្រៅ និងដាច់ខាត ការលុបបំបាត់នូវបាតុភាពអសកម្មទាំងឡាយដែលធ្វើឱ្យខូចខាតដល់ផលប្រយោជន៍របស់ប្រទេសជាតិ និងប្រជាពលរដ្ឋ ការបន្តអភិវឌ្ឍសេដ្ឋកិច្ច សង្គមឱ្យកាន់តែរីកចម្រើនខ្លាំងឡើង ការបន្តជំរុញដំឡើងប្រាក់បៀវត្សរបស់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ ក៏ដូចកម្មករ និយោជិត និងការលើកកម្ពស់ឥតឈប់ឈរនូវកម្រិតជីវភាព និងសុខុមាលភាពរបស់ប្រជាជនគ្រប់ៗរូប ជាពិសេសប្រជាជនក្រីក្រដែលកំពុងមានជីវភាពលំបាកលំបិន ។

ដើម្បីសម្រេចនូវរាល់គោលដៅខាងលើនេះ គណបក្សប្រជាជនកម្ពុជា នឹងរៀបចំរាជរដ្ឋាភិបាលសម្រាប់នីតិកាលទី ៥ ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី ជារាជរដ្ឋាភិបាលដែលបម្រើនូវឆន្ទៈ និងផលប្រយោជន៍របស់ប្រជាជនទាំងស្រុង ប្រកបដោយតម្លាភាព និងមានសមត្ថភាពពេញលេញក្នុងការដឹកនាំប្រទេសជាតិ។

**គណបក្សប្រជាជនកម្ពុជា** សូមអំពាវនាវជនរួមជាតិទាំងអស់ ទោះបីបានបោះឆ្នោតគាំទ្រគណបក្សនយោបាយណាក្តី សូមរួមសាមគ្គីគ្នាជាធ្លុងមួយក្រោមដំបូលរដ្ឋធម្មនុញ្ញ និងក្រោមម្លប់ដ៏ត្រជាក់នៃ **ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតនៃយើង និងសាមគ្គីជុំវិញរាជរដ្ឋាភិបាល ដើម្បីថែរក្សារាល់សមិទ្ធផលរបស់ជាតិ បន្តការពារ និងកសាងមាតុភូមិកម្ពុជាឆ្ពោះទៅរកអនាគតដ៏រុងរឿង។ ព្រមជាមួយនេះ សូមអំពាវនាវដល់គណបក្សដែលទទួល

បានអាសនៈក្នុងរដ្ឋសភា នីតិកាលទី ៥ សូមតម្កល់នូវឧត្តមប្រយោជន៍របស់ប្រទេសជាតិ និងប្រជាជនជាធំលើសអ្វីៗទាំងអស់ ហើយធ្វើការរួមគ្នា ដោយឈរលើមូលដ្ឋានរដ្ឋធម្មនុញ្ញ ច្បាប់ និងគោលការណ៍នៃប្រជាធិបតេយ្យ និងស្មារតីបង្រួបបង្រួមជាតិ ដើម្បីធានាឱ្យរដ្ឋសភានីតិកាលទី ៥ បានចាប់ផ្តើមការងាររបស់ខ្លួនយ៉ាងល្អប្រសើរ ស្របតាមរដ្ឋធម្មនុញ្ញ និងបំណងប្រាថ្នារបស់ប្រជាជនយើង ។

ជាទីបញ្ចប់សូមប្រសិទ្ធពរជូនជនរួមជាតិ សូមបានប្រកបពុទ្ធពរទាំង ៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៣

**គណបក្សប្រជាជនកម្ពុជា**

គណបក្សសង្គ្រោះជាតិ

CAMBODIA NATIONAL RESCUE PARTY

សង្គ្រោះ បម្រើ ការពារ

# សេចក្តីថ្លែងការណ៍

**គណបក្សសង្គ្រោះជាតិ** គាំទ្រញត្តិដែលសម្រេចអនុម័តដោយប្រជាពលរដ្ឋខ្មែរ ចូលរួមក្នុងមហាបាតុកម្មអហិង្សា កាលពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៣ នៅរាជធានីភ្នំពេញ ។

**គណបក្សសង្គ្រោះជាតិ** គាំទ្រសេចក្តីអំពាវនាវបន្ទាន់របស់បន្ទប់ស្ថានការណ៍ ដែលបានដាក់ជូនគណបក្សសង្គ្រោះជាតិ ក្នុងអំឡុងពេលធ្វើមហាបាតុកម្មអហិង្សា កាលពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៣ នៅរាជធានីភ្នំពេញ ។

**គណបក្សសង្គ្រោះជាតិ** សូមថ្លែងអំណរគុណសាជាថ្មីម្តងទៀតដល់បងប្អូនប្រជាពលរដ្ឋខ្មែរ ដែលបានបោះឆ្នោតគាំទ្រដល់បេក្ខជនតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ដែលលទ្ធផលនៃការបោះឆ្នោតនេះ សល់ពីការបំភិតបំភ័យ និងលួចបន្លំសន្លឹកឆ្នោតនៅទូទាំងប្រទេស ។

**គណបក្សសង្គ្រោះជាតិ** ជំទាស់នូវលទ្ធផលនៃការបោះឆ្នោត ដែលបានប្រកាសដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) កាលពីថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៣ និងនៅតែបន្តទាមទារឲ្យមានការបង្កើតគណៈកម្មការចម្រុះឯករាជ្យមួយដើម្បីស៊ើបអង្កេត និងដោះស្រាយភាពមិនប្រក្រតីនៃការបោះឆ្នោតជាតិអាណត្តិទី៥ ។ ក្នុងករណីដែលមិនមានដំណោះស្រាយសមស្របណាមួយដើម្បីរកយុត្តិធម៌ជូនម្ចាស់ឆ្នោត គណបក្សសង្គ្រោះជាតិនឹងបន្តរៀបចំមហាបាតុកម្មអហិង្សាដើម្បីសម្តែងពីឆន្ទៈរបស់មហាជនខ្មែរ ចាប់ពីថ្ងៃទី១៥ ១៦ និង១៧ ខែកញ្ញា ឆ្នាំ២០១៣ នេះតទៅ រហូតដល់មានដំណោះស្រាយប្រកបដោយយុត្តិធម៌ជូនប្រជាពលរដ្ឋខ្មែរដែលជាម្ចាស់ឆ្នោត ។

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៣

គណបក្សសង្គ្រោះជាតិ

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង*

*ទូរស័ព្ទលេខ ៖ 012 788 999*

ទីស្នាក់ការកណ្តាល : ផ្ទះលេខ ៥៧៦ ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Headquarters : House #576, National Road N°2, Sangkat Chakangres Leu, Khan Mean Chey Phnom Penh, Kingdom of Cambodia

Tel : 012 90 57 75 / 092 92 51 71

# កិច្ចព្រមព្រៀង
# ស្តីពី
# ដំណោះស្រាយនយោបាយរវាងគណបក្សប្រជាជនកម្ពុជា និង គណបក្សសង្គ្រោះជាតិ

- ដោយយល់ឃើញថា ដំណោះស្រាយដោយសន្តិវិធីតាមរយៈការចរចា គឺជាមធ្យោបាយដ៏ល្អតែមួយគត់ក្នុងការដោះស្រាយបញ្ហានយោបាយដែលកើតមាន ក្រោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ៥ នៃរដ្ឋសភា នាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣
- ដោយគោរពតាមឆន្ទៈរបស់ប្រជាពលរដ្ឋ និងដើម្បីជាផលប្រយោជន៍ដ៏ឧត្តុងឧត្តមនៃប្រទេសជាតិ

ថ្នាក់ដឹកនាំកំពូលនៃ **គណបក្សប្រជាជនកម្ពុជា** និង **គណបក្សសង្គ្រោះជាតិ** បានជួបប្រជុំពិភាក្សាគ្នា នាថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១៤ នៅវិមានព្រឹទ្ធសភា និងបានព្រមព្រៀងគ្នាលើដំណោះស្រាយនយោបាយ ដែលមានខ្លឹមសារដូចខាងក្រោម៖

**ប្រការ ១**.-

គណបក្សទាំងពីរបានឯកភាពគ្នាលើដំណោះស្រាយនយោបាយដោយចូលរួមធ្វើការជាមួយគ្នានៅក្នុងស្ថាប័នរដ្ឋសភា ដើម្បីឈានទៅដោះស្រាយបញ្ហានានារបស់ប្រទេសជាតិ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ។

**ប្រការ ២**.-

ផ្អែកតាមស្មារតីនៃសេចក្តីប្រកាសរួមនៃជំនួបកំពូលរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិកាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣ គណបក្សទាំងពីរបានឯកភាពគ្នាដើម្បីកែទម្រង់ការបោះឆ្នោតដោយរៀបចំស្ថាប័នរៀបចំការបោះឆ្នោតជាស្ថាប័ន ដែលមានឯករាជ្យពេញលេញដោយមានចែងក្នុងជំពូកមួយដោយឡែកក្នុងរដ្ឋធម្មនុញ្ញ ហើយសមាសភាពនៃស្ថាប័ននេះ ត្រូវជ្រើសតាំងដោយរដ្ឋសភាតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។ សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានចំនួន ០៩ រូប ក្នុងនោះ សមាសភាព ០៤ រូប ជ្រើសរើសដោយគណបក្សដឹកនាំរាជរដ្ឋាភិបាល, សមាសភាព ០៤ រូប ជ្រើសរើសដោយគណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល ហើយសមាសភាព ០១ រូបទៀត គឺត្រូវជ្រើសរើសដោយមានការព្រមព្រៀងគ្នារវាងគណបក្ស ដែលមានអាសនៈក្នុងរដ្ឋសភា។ គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា ត្រូវដំណើរការរៀបចំឱ្យមានការជ្រើសរើសដោយបើកចំហ និងតម្លាភាព នូវសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដាក់ជូនរដ្ឋសភាដើម្បីបោះឆ្នោតទុកចិត្ត។ ក្នុងករណីដែលខកខានមិនបានរៀបចំសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែល

មានស្រាប់ត្រូវបន្តការងាររបស់ខ្លួនបន្តទៀត និងមានសមត្ថកិច្ចដើម្បីចាត់ចែងរៀបចំការបោះឆ្នោតតាមច្បាប់។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានថវិកាស្វយ័តសម្រាប់ដំណើរការ។

គណបក្សទាំងពីរឯកភាពគ្នាឱ្យគណៈកម្មការចម្រុះដែលមានស្រាប់ បន្តពិភាក្សាគ្នារៀបចំក្របខណ្ឌកំណែទម្រង់ការបោះឆ្នោតនាពេលខាងមុខ ស្របតាមសេចក្ដីប្រកាសរួមរវាងក្រុមការងារគណបក្សប្រជាជនកម្ពុជា និងក្រុមការងារគណបក្សសង្គ្រោះជាតិ កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤ ក្នុងនោះ ដោយរួមទាំងការរៀបចំបញ្ជីឈ្មោះបោះឆ្នោតជាថ្មី។

**ប្រការ ៣.-**

គណបក្សទាំងពីរឯកភាពគ្នាកំណត់ឡើងវិញ នូវកាលបរិច្ឆេទសម្រាប់ការបោះឆ្នោតនាពេលខាងមុខ។

**ប្រការ ៤.-**

គណបក្សទាំងពីរឯកភាពគ្នាក្នុងការរៀបចំឱ្យមានការបែងចែកអំណាចដាច់ពីគ្នា រវាងអំណាចនីតិប្បញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ។ គណបក្សទាំងពីរឯកភាពគ្នាធ្វើការសិក្សា ដើម្បីឈានទៅធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ដើម្បីឱ្យស្ថាប័ននេះអាចបំពេញតួនាទីរបស់ខ្លួនបានត្រឹមត្រូវ និងកាន់តែមានប្រសិទ្ធភាព ក្នុងនោះ លើកកំពស់តួនាទី និងសិទ្ធិអំណាចរបស់គណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល ស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ គណបក្សទាំងពីរឯកភាពគ្នារៀបចំក្បាលម៉ាស៊ីនរដ្ឋសភា ដោយបែងចែកតួនាទីដឹកនាំនៅក្នុងគណៈកម្មាធិការ អចិន្ត្រៃយ៍នៃរដ្ឋសភា តាមរូបមន្ត ៧ ទល់ ៦ ដោយត្រូវបង្កើតបន្ថែម គណៈកម្មការជំនាញថ្មីមួយទៀត ហើយដោយមានប្រធានរដ្ឋសភាមកពីគណបក្សប្រជាជនកម្ពុជា, អនុប្រធានទី ១ មកពីគណបក្សសង្គ្រោះជាតិ និងអនុប្រធានទី ២ មកពីគណបក្សប្រជាជនកម្ពុជា។ គណៈកម្មការដែលបង្កើតថ្មីជាគណៈកម្មការទី ១០ មានឈ្មោះថា "គណៈកម្មការអង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយ" ដោយបំបែកចេញពីគណៈកម្មការទី ៤ ហើយប្ដូរឈ្មោះគណៈកម្មការទី ៤ មកជា "គណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ"។ គណៈកម្មការដែលគណបក្សប្រជាជនកម្ពុជាធ្វើជាប្រធាន និងធ្វើជាលេខាធិការ រួមមាន គណៈកម្មការទី ២, គណៈកម្មការទី ៤, គណៈកម្មការទី ៥, គណៈកម្មការទី ៦ និងគណៈកម្មការទី ៩។ គណៈកម្មការដែលគណបក្សសង្គ្រោះជាតិធ្វើជាប្រធាន និងធ្វើជាលេខាធិការ រួមមាន គណៈកម្មការទី ១, គណៈកម្មការទី ៣, គណៈកម្មការទី ៧, គណៈកម្មការទី ៨ និង គណៈកម្មការទី ១០។ គណៈកម្មការនីមួយៗមាន ០៩ រូប។ គណៈកម្មការដែលគណបក្សណាធ្វើជាប្រធាន គណបក្សនោះមាន ០៥ រូប និងគណបក្សមួយទៀតមាន ០៤ រូប។

**ប្រការ ៥.-**

គណបក្សទាំងពីរឯកភាពគ្នាពិនិត្យរៀបចំឡើងវិញនូវក្បាលម៉ាស៊ីនដឹកនាំព្រឹទ្ធសភា។

**ប្រការ ៦.-**

គណបក្សទាំងពីរឯកភាពគ្នាធ្វើការកែទម្រង់ និងពង្រឹងស្ថាប័នជាតិសំខាន់ៗ ជាពិសេសស្ថាប័នឯករាជ្យនានាឱ្យអាចបំពេញការងារបម្រើជាតិ និងប្រជាពលរដ្ឋ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងនីតិរដ្ឋ។

**ប្រការ ៧.-**

គណបក្សទាំងពីរឯកភាពគ្នាក្នុងការសិក្សា ដើម្បីឈានទៅធ្វើវិសោធនកម្មបទដ្ឋានគតិយុត្ត ពាក់ព័ន្ធដើម្បីធានាការអនុវត្តកិច្ចព្រមព្រៀងនេះ។

| **តំណាងគណបក្សប្រជាជនកម្ពុជា** | **តំណាងគណបក្សសង្គ្រោះជាតិ** |
| --- | --- |
| **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** | **ឯកឧត្តម សម រង្ស៊ី** |
| **ឯកឧត្តម សាយ ឈុំ** **ឯកឧត្តម ស ខេង** | **ឯកឧត្តម កឹម សុខា** **ឯកឧត្តម ប៉ុល ហំម** |

# សេចក្តីប្រកាសរួមនៃជំនួបកំពូល
# រវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ
# ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១៣

នាព្រឹកថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១៣ គណៈប្រតិភូគណបក្សប្រជាជនកម្ពុជា ដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និងគណៈប្រតិភូគណបក្សសង្គ្រោះជាតិ ដឹកនាំដោយ **ឯកឧត្តម សម រង្ស៊ី** បានជួបប្រជុំដើម្បីពិភាក្សាគ្នា និងរកដំណោះស្រាយចំពោះបញ្ហាប្រទេសជាតិ តបតាមព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់ របស់ **ព្រះករុណា ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** កាលពីប្រជុំកំពូលថ្ងៃទី ១៤ ខែកញ្ញា កន្លងទៅ ដោយទទួលបានលទ្ធផលដូចខាងក្រោមៈ

១- ភាគីទាំងពីរ បានឯកភាពគ្នាគោរព និងអនុវត្តដោយហ្មត់ចត់តាមព្រះរាជសាររបស់ **ព្រះករុណា ព្រះមហាក្សត្រ** ចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១៣ អំពាវនាវចំពោះជនរួមជាតិទាំងមូល ដែលជាក្រុមបាតុករ និងក្រុមសមត្ថកិច្ច សូមបញ្ឈប់ការប្រើអំពើហិង្សាតាមរូបភាពណាក៏ដោយ ដូចជាការគប់ដុំថ្ម និងការប្រើប្រាស់អាវុធ ដែលបណ្តាលអោយបងប្អូនទាំងអស់គ្នាទទួលរងរបួស ឬបាត់បង់ជីវិត និងបណ្តាលអោយមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សង្គមជាតិទាំងមូល ហើយងាកមកប្រកាន់យកប្រពៃណីអហិង្សា ខិតខំយោគយល់គ្នា រាប់អានគ្នាជាខ្មែរដូចគ្នា និងអត់ធ្មត់ជាអតិបរមា ដើម្បីបញ្ចៀសអស្ថិរភាពនៃជាតិយើង ព្រមទាំងរក្សាភាពថ្លៃថ្នូរ និងភាពស្ងាត់ស្ងៀម ដើម្បីទុកឱកាសរកដំណោះស្រាយបញ្ហាជាតិយើងទាំងអស់គ្នា ។

២- ភាគីទាំងពីរព្រមព្រៀងគ្នា នឹងបង្កើតយន្តការមួយដើម្បីកែទម្រង់ការបោះឆ្នោតនាពេលខាងមុខ ។

៣- ភាគីទាំងពីរនឹងបន្តជួបចរចាគ្នាតទៅទៀតតាមគ្រប់កម្រិតដើម្បីដោះស្រាយបញ្ហារបស់ជាតិ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១៣

| តំណាងគណបក្សប្រជាជនកម្ពុជា | តំណាងគណបក្សសង្គ្រោះជាតិ |
|---|---|
| **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** | **ឯកឧត្តម សម រង្ស៊ី** |
| **ឯកឧត្តម សាយ ឈុំ**  **ឯកឧត្តម ស ខេង** | **ឯកឧត្តម កឹម សុខា**  **ឯកឧត្តម ប៉ុល ហំម** |

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

# សេចក្ដីថ្លែងការណ៍របស់រដ្ឋសភា
# នៃព្រះរាជាណាចក្រកម្ពុជា

នៅព្រឹកថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ នេះ នៅជិតបរិវេណទីលានប្រជាធិបតេយ្យ មានកើតនូវអំពើហិង្សាបង្កឡើងដោយជនអនាធិបតេយ្យមានការចាត់តាំង ដឹកនាំដោយឈ្មោះ មូរ សុខហួរ ហូ វ៉ាន់ ម៉ែន សុថាវិរិន្ទ្រ កែវ ភារម្យ រៀល ខេមរិន្ទ្រ និងបក្សពួក។ អំពើហិង្សានេះបានធ្វើឲ្យមានភាពចលាចល ប៉ះពាល់ដល់សន្តិសុខសណ្ដាប់ធ្នាប់សាធារណៈ ប្រជាពលរដ្ឋដែលកំពុងរស់នៅយ៉ាងសុខសាន្តមានការភ័យខ្លាច ទ្រព្យសម្បត្តិសាធារណៈ និងឯកជនត្រូវបានបំផ្លិចបំផ្លាញ។ ក្រុមអនាធិបតេយ្យដោយមានការចាត់តាំងគិតទុកជាមុនច្បាស់លាស់ បានធ្វើការវាយប្រហារដោយប្រើដំបងដែកនិងដុំថ្ម ទៅលើកងកម្លាំងរក្សាសន្តិសុខសាលាខណ្ឌដូនពេញ ធ្វើឲ្យមានរបួសចំនួន៣៨នាក់ ក្នុងនោះ២២នាក់ត្រូវរងរបួសធ្ងន់ ហើយ៣នាក់ស្ថិតក្នុងការសង្គ្រោះបន្ទាន់។

រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាថ្កោលទោសចំពោះអំពើហិង្សាដ៏ឃោរឃៅព្រៃផ្សៃ អមនុស្សធម៌និងរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរនេះ។ សកម្មភាពអនាធិបតេយ្យមានការគ្រោងទុកជាមុននេះ គឺជាអំពើឧក្រិដ្ឋដែលរំលោភច្បាប់ព្រហ្មទណ្ឌជាធរមាន។

រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា សូមអំពាវនាវដល់អាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់មេត្តាបន្តពុះពារខិតខំថែរក្សាសន្តិសុខ សេចក្ដីថ្លៃថ្នូរ សេចក្ដីសុខក្សេមក្សាន្ត សុវត្ថិភាព និងសណ្ដាប់ធ្នាប់សង្គមរបស់ប្រជាជនយើង។

រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា សូមធ្វើការធានាចំពោះប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតថា នឹងបន្តចូលរួមជាមួយស្ថាប័នរដ្ឋនិងអាជ្ញាធរមានសមត្ថកិច្ចទាំងអស់ក្នុងការថែរក្សាសណ្ដាប់ធ្នាប់សាធារណៈ សុវត្ថិភាព និងសន្តិសុខសង្គម ដើម្បីសេចក្ដីថ្លៃថ្នូររបស់ជាតិនិងប្រជាជនយើង។

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង
# ស្តីពី
# ការចរចាធ្វើសេចក្តីព្រាងវិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា

យោងកិច្ចព្រមព្រៀងចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ រវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ក្រុមការងារចចាររបស់គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ បានជួបប្រជុំពិភាក្សាធ្វើសេចក្តីព្រាងវិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភាជាពីរដំណាក់កាល។

ក្នុងដំណាក់កាលទី១ ក្រុមការងារបានឯកភាពគ្នាដូចខាងក្រោម ៖

**ប្រការ ៦ ថ្មី (ពីរ)** :

គណៈកម្មការនានានៃរដ្ឋសភាមាន :

១- គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា
២- គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម
៣- គណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក
៤- គណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ
៥- គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន
៦- គណៈកម្មការនីតិកម្ម និងយុត្តិធម៌
៧- គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍
៨- គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី
៩- គណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់
១០- គណៈកម្មការអង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយ។

**ប្រការ ៩ ថ្មី (ពីរ)** :

អនុប្រធានទាំងពីរជួយធ្វើការប្រធានទៅតាមការបែងចែកភារកិច្ចពីប្រធាន។ កាលបើប្រធានអវត្តមានឬមកធ្វើការពុំបាន អនុប្រធានធ្វើការជួសប្រធានក្នុងឋានៈជាប្រធានស្តីទី តាមរយៈលិខិតផ្ទេរសិទ្ធិ។ ការផ្ទេរសិទ្ធិនេះត្រូវធ្វើទៅតាមឋានានុក្រម។

**ប្រការ ១៤ ថ្មី (ពីរ)** :

រដ្ឋសភាមានអគ្គលេខាធិការដ្ឋានមួយទទួលបន្ទុកខាងការរៀបចំធ្វើកំណត់ហេតុរបស់រដ្ឋសភា និងរបស់គណៈកម្មការនានា។ អគ្គលេខាធិការដ្ឋាននេះទទួលរ៉ាប់រងនូវគ្រប់កិច្ចការរដ្ឋបាលនិងសេវានានាជូនរដ្ឋសភា និងគណៈកម្មការទាំងអស់ ព្រមទាំងទំនាក់ទំនងផ្សេងៗក្រៅរដ្ឋសភា។

អគ្គលេខាធិការដ្ឋានបង្កើតឲ្យមានការផ្សព្វផ្សាយរបស់គណបក្សនយោបាយដែលមានអាសនៈក្នុងរដ្ឋសភា បន្ទាប់ពីសម័យប្រជុំពេញអង្គ។

ខ្លឹមសារនៃការផ្សព្វផ្សាយនោះ ត្រូវស្របតាមរបៀបវារៈនៃសម័យប្រជុំរបស់រដ្ឋសភា ហើយមានថេរៈវេលា មិនលើសពី២០នាទី។

ការផ្សព្វផ្សាយព័ត៌មានរដ្ឋបាលជាភារកិច្ចរបស់អគ្គលេខាធិការដ្ឋានរដ្ឋសភា។

**ប្រការ ៣២ ( ថ្មី ) :**

អ្នកតំណាងរាស្ត្រមានសិទ្ធិដាក់សំនួរដល់រាជរដ្ឋាភិបាល។ សំណួរនេះត្រូវសរសេរជាលាយលក្ខណ៍អក្សរប្រគល់ជូនតាមរយៈប្រធានរដ្ឋសភា។

ចំលើយអាចធ្វើឡើងដោយរដ្ឋមន្ត្រីមួយរូប ឬ ច្រើនរូបអាស្រ័យដោយបញ្ហាដែលបានចោទឡើងពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់រដ្ឋមន្ត្រីមួយរូប ឬ ច្រើនរូប។ បើបញ្ហាពាក់ព័ន្ធដល់នយោបាយទូទៅរបស់រាជរដ្ឋាភិបាល នាយករដ្ឋមន្ត្រីត្រូវឆ្លើយផ្ទាល់ខ្លួន។

ចំលើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រី អាចធ្វើដោយផ្ទាល់មាត់ ឬសរសេរជាលាយលក្ខណ៍អក្សរ ហើយចាំបាច់ត្រូវតែចូលមកបំភ្លឺតាមសំណើរបស់អ្នកតំណាងរាស្ត្រ។

ចម្លើយខាងលើនេះត្រូវធ្វើឡើងក្នុងរយៈពេលប្រាំពីរថ្ងៃ បន្ទាប់ពីបានទទួលសំណួរ។

ចំពោះចម្លើយផ្ទាល់មាត់ ប្រធានរដ្ឋសភាអាចសម្រេចបើកឲ្យមាន ឬ មិនឲ្យមានការជជែកដេញដោល។ បើគ្មានការបើកឲ្យជជែកដេញដោលទេ នោះចម្លើយរបស់រដ្ឋមន្ត្រី ឬរបស់នាយករដ្ឋមន្ត្រីនឹងបញ្ចប់សំណួរតែម្តង។

**ប្រការ ៣៤ ( ថ្មី ) :**

គណៈកម្មការទាំងឡាយរបស់រដ្ឋសភាអាចអញ្ជើញរដ្ឋមន្ត្រី ឬវជនណាមួយមកបំភ្លឺពីបញ្ហាអ្វីមួយដែលពាក់ព័ន្ធនឹងវិស័យទទួលខុសត្រូវរបស់ខ្លួន រដ្ឋមន្ត្រី ឬ វជននោះចាំបាច់ត្រូវតែចូលមកបំភ្លឺ។

បញ្ហាដែលនៅសេសសល់ ក្រុមការងារបានឯកភាពថានឹងយកទៅដោះស្រាយនៅក្នុងយន្តការរដ្ឋសភានៅពេលខាងមុខ។

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤

**ប្រធានក្រុមការងារគណបក្សប្រជាជនកម្ពុជា** **ប្រធានក្រុមការងារតំណាងគណបក្សសង្គ្រោះជាតិ**

**ឯកឧត្តម ឈាង វុន** **ឯកឧត្តម យ៉េម បុញ្ញឫទ្ធិ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

អគ្គលេខាធិការដ្ឋាន

លេខ ៨៦៨/១៤ អ.រ.ស.សា.ជ.សា.និ

# សេចក្តីជូនដំណឹង

អគ្គលេខាធិការដ្ឋានរដ្ឋសភាមានកិត្តិយសសូមជម្រាបជូនសាធារណជនជ្រាបថា នៅថ្ងៃ សុក្រ ទី ៨ ខែ សីហា ឆ្នាំ ២០១៤ វេលាម៉ោង ៨: ០០ ព្រឹក រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា នឹងបន្តសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី ៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា** ដើម្បីធ្វើ **ការពិភាក្សា និងអនុម័តលើសេចក្តីស្នើវិសោធនកម្មប្រការ ៦ ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ។**

អាស្រ័យហេតុនេះ សូមសាធារណជនជ្រាប ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤

**អគ្គលេខាធិការ**

**ឡេង ប៉េងឡុង**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**
**អគ្គលេខាធិការដ្ឋាន**
លេខ .....៥៤២/១៤ អ.ស.ស.កស.ណា.ន៩

# សេចក្តីជូនដំណឹង

អគ្គលេខាធិការដ្ឋានរដ្ឋសភាមានកិត្តិយសសូមជម្រាបជូនសាធារណជនជ្រាបថា នៅថ្ងៃ អង្គារ ទី ២៦ ខែ សីហា ឆ្នាំ ២០១៤ វេលាម៉ោង ៨: ០០ ព្រឹក រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា នឹងបន្តសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី ៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា** តាមរបៀបវារៈដូចតទៅ :

**១.ការបោះឆ្នោតជ្រើសតាំង ឯកឧត្តមបណ្ឌិត ងួន ញ៉ិល ជាអនុប្រធានទី ២ នៃរដ្ឋសភា ។**

**នៃរដ្ឋសភា ។**

**២.ការបោះឆ្នោតជ្រើសតាំង ឯកឧត្តម គឹម សុខា ជាអនុប្រធានទី ១ នៃរដ្ឋសភា ។**

**៣.ការបោះឆ្នោតជ្រើសតាំងជំនួស និងបំពេញបន្ថែមសមាជិកគណៈកម្មការនានានៃរដ្ឋសភា:**

**៣.១.គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹង អង្កេត និងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា**

**៣.២.គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម**

**៣.៣.គណៈកម្មការផែនការ វិនិយោគ កសិកម្ម អភិវឌ្ឍន៍ជនបទ បរិស្ថាន និងធនធានទឹក**

**៣.៤.គណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ**

**៣.៥.គណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន**

៣.៦.គណៈកម្មការនីតិកម្ម និងយុត្តិធម៌

៣.៧.គណៈកម្មការអប់រំ យុវជន កីឡា ធម្មការ កិច្ចការសាសនា វប្បធម៌ និងទេសចរណ៍

៣.៨.គណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី

៣.៩.គណៈកម្មការសាធារណការ ដឹកជញ្ជូន ទូរគមនាគមន៍ ប្រៃសណីយ៍ ឧស្សាហកម្ម រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់

៣.១០.គណៈកម្មការអង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយ ។

អាស្រ័យហេតុនេះ សូមសាធារណជនជ្រាប ។

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែ សីហា ឆ្នាំ ២០១៤

**អគ្គលេខាធិការ**

**ឡេង ប៉េងឡុង**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**
**អគ្គលេខាធិការដ្ឋាន**
-លេខៈ ១៣៦៥/១៤ អ.ល.រ.ស.ស.គ.ណ.នី.ត.

# សេចក្តីជូនដំណឹង

អគ្គលេខាធិការដ្ឋានរដ្ឋសភាមានកិត្តិយសសូមជម្រាបជូនសាធារណជនជ្រាបថា នៅថ្ងៃ សុក្រ ទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៤ វេលាម៉ោង ៨: ០០ ព្រឹក រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា នឹងបន្តសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា** ដើម្បីធ្វើ **ការពិភាក្សា និងអនុម័តលើសេចក្តីស្នើវិសោធនកម្មជំពូកទី ១២ ប្រការ ៤៨ ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុង នៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ។**

អាស្រ័យហេតុនេះ សូមសាធារណជនជ្រាប ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៤
**អគ្គលេខាធិការ**

**ឡេង ប៉េងឡុង**

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

# សេចក្តីជូនដំណឹង

**យោង:** សេចក្តីប្រកាសរួម ស្តីពីលទ្ធផលនៃកិច្ចប្រជុំរវាងថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៥ នៅវិមានរដ្ឋសភា

ថ្នាក់ដឹកនាំតំណាងរាស្ត្រនៃ **គណបក្សប្រជាជនកម្ពុជា** និង **គណបក្សសង្គ្រោះជាតិ** មានកិត្តិយស សូមជម្រាបជូនដល់សាធារណជនមេត្តាជ្រាបថា ក្រោយពីបានដោះស្រាយបញ្ចប់នូវចំណុចសេសសល់ពាក់ព័ន្ធនឹង **សេចក្តីស្នើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ** កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៥ កន្លងទៅនេះ **ក្រុមការងារនៃគណបក្សនយោបាយទាំងពីរ** បានព្រមព្រៀងឯកភាពគ្នា រៀបចំធ្វើសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីស្នើច្បាប់ទាំងពីរនេះ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃច័ន្ទ ទី០៩ ខែមីនា ឆ្នាំ២០១៥ វេលាម៉ោង ៨:៣០ នាទីព្រឹក នៅវិមានរដ្ឋសភា ដែលមានគណបក្សនយោបាយទាំងពីរជាអ្នកចាត់ចែង និងធ្វើការសម្របសម្រួល។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបងប្អូនសាធារណជនដែលមានបំណងចង់ចូលរួមក្នុងសិក្ខាសាលានេះ អញ្ជើញមកទំនាក់ទំនងជាមួយអគ្គលេខាធិការដ្ឋានរដ្ឋសភា ដើម្បីចុះឈ្មោះ និងទទួលយកស្លាកសញ្ញាសំគាល់សម្រាប់ចូលរួមសិក្ខាសាលានេះ។

លេខទូរស័ព្ទទំនាក់ទំនង៖ ០១២ ៥៨៣ ២៩៩, ០១៦ ៥៥៨ ០៧០, ០៩៥ ៩៩ ៩៩ ៧៦

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥

| | |
|---|---|
| **ជ.ថ្នាក់ដឹកនាំតំណាងរាស្ត្រ** | **ជ.ថ្នាក់ដឹកនាំតំណាងរាស្ត្រ** |
| **គណបក្សប្រជាជនកម្ពុជា** | **គណបក្សសង្គ្រោះជាតិ** |
| **ប្រធាន** | **ប្រធាន** |
| **ស ខេង** | **សម រង្ស៊ី** |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កំណត់ហេតុ
## ស្តីពី
## លទ្ធផលកិច្ចប្រជុំក្រុមការងារវិសោធនកម្មច្បាប់បោះឆ្នោត
## រវាងគណបក្សប្រជាជនកម្ពុជា និង គណបក្សសង្គ្រោះជាតិ

នៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៥ វេលាម៉ោង ១៥: ០០ នាទីរសៀល នៅវិមានរដ្ឋសភា ក្រុមការងារវិសោធនកម្មច្បាប់បោះឆ្នោតរបស់ **គណបក្សប្រជាជនកម្ពុជា** និង**គណបក្សសង្គ្រោះជាតិ** បានបញ្ចប់កិច្ចប្រជុំពិភាក្សាឆ្លងសេចក្តីព្រាងនៃសេចក្តីស្នើច្បាប់ ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រដែលមានសមាសភាពចូលរួមដូចខាងក្រោម៖

**ក. ក្រុមការងារគណបក្សប្រជាជនកម្ពុជា**

| | | |
|---|---|---|
| -ឯកឧត្តម | **ប៊ិន ឈិន** | ប្រធាន |
| -ឯកឧត្តម | **ជាម យៀប** | សមាជិក |
| -ឯកឧត្តម | **ស៊ិក ប៊ុនហុក** | សមាជិក |
| -លោកជំទាវ | **គ្រួច សំអាន** | សមាជិកា |
| -ឯកឧត្តម | **ហ៊ី សោភា** | សមាជិក |
| -ឯកឧត្តម | **ព្រុំ សុខា** | សមាជិក |
| -ឯកឧត្តម | **កើត រិទ្ធ** | សមាជិក |

- និងក្រុមជំនួយការ

**ខ. ក្រុមការងារគណបក្សសង្គ្រោះជាតិ**

| | | |
|---|---|---|
| -ឯកឧត្តម | **គួយ ប៊ុនរឿន** | ប្រធាន |
| -ឯកឧត្តម | **សុន ឆ័យ** | សមាជិក |
| -ឯកឧត្តម | **អេង ឆៃអ៊ាង** | សមាជិក |
| -ឯកឧត្តម | **យ៉ែម បុញ្ញឫទ្ធិ** | សមាជិក |
| -ឯកឧត្តម | **អ៊ូ ច័ន្ទឫទ្ធិ** | សមាជិក |
| -ឯកឧត្តម | **គីមសួរ ភីរិទ្ធិ** | សមាជិក |
| -ឯកឧត្តម | **ហូរ វ៉ាន់** | សមាជិក |

- និងក្រុមជំនួយការ

ចាប់តាំងពីថ្ងៃទី០៨ខែធ្នូ ឆ្នាំ២០១៤ រហូតដល់ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៥ ក្រុមការងារនៃគណបក្សទាំងពីរបានជួបប្រជុំពិនិត្យពិភាក្សាជាបន្តបន្ទាប់ លើខ្លឹមសារនៃសេចក្តីព្រាងសេចក្តីស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បានចំនួន២៧លើក ដោយបានឯកភាពគ្នាលើខ្លឹមសារទាំងស្រុងនៃសេចក្តីព្រាងសេចក្តីស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលរួមមានសរុបចំនួន ១៧១មាត្រា ចែកចេញជា១២ជំពូក ដូចខាងក្រោម ៖

**ជំពូកទី១ចែងអំពីបទប្បញ្ញត្តិទូទៅ** ដែលរួមមាន ៤មាត្រា ចាប់ពីមាត្រា១ ដល់មាត្រា៤ ។

**ជំពូកទី២ចែងអំពីប្រព័ន្ធបោះឆ្នោត និងការកំណត់អាសនៈ** ដែលរួមមាន ២មាត្រា ចាប់ពីមាត្រា៥ដល់មាត្រា៦ ។

**ជំពូកទី៣ចែងអំពីភ្នាក់ងារគណបក្សនយោបាយនិងអ្នកសង្កេតការណ៍បោះឆ្នោត** ដែលរួមមាន១៦មាត្រា ចាប់ពីមាត្រា៧ ដល់មាត្រា២២ ។

**ជំពូកទី៤ចែងអំពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ** ដែលរួមមាន១៥មាត្រា ចាប់ពីមាត្រា២៣ ដល់មាត្រា៣៧ ។

**ជំពូកទី៥ចែងអំពីការិយាល័យបោះឆ្នោត** ដែលរួមមាន៦មាត្រា ចាប់ពីមាត្រា៣៨ ដល់មាត្រា៤៣។

**ជំពូកទី៦ចែងអំពីការចុះឈ្មោះបោះឆ្នោតនិងបញ្ជីបោះឆ្នោត** ដែលរួមមាន២៣មាត្រា ចាប់ពី មាត្រា៤៤ដល់មាត្រា៦៦។

**ជំពូកទី៧អំពីការឃោសនាបោះឆ្នោត** ដែលរួមមាន២៥មាត្រា ចាប់ពីមាត្រា៦៧ដល់មាត្រា៩១។

**ជំពូកទី៨អំពីការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោត** ដែលរួមមាន៤៦មាត្រា ចាប់ពីមាត្រា៩២ដល់មាត្រា១៣៧ ។

**ជំពូកទី៩អំពីការបាត់អាសនៈរដ្ឋសភា និងការជ្រើសតាំងជំនួស** ដែលរួមមាន២មាត្រា ចាប់ពីមាត្រា១៣៨ដល់មាត្រា១៣៩ ។

**ជំពូកទី១០អំពីទោសប្បញ្ញត្តិ**ដែលរួមមាន២៧មាត្រា ចាប់ពីមាត្រា១៤០ដល់មាត្រា១៦៦។

**ជំពូកទី១១អំពីអន្តរប្បញ្ញត្តិ** ដែលរួមមាន៣មាត្រា ចាប់ពីមាត្រា១៦៧ដល់មាត្រា១៦៩។

**ជំពូកទី១២ អំពីអវសានប្បញ្ញត្តិ** ដែលរួមមាន២មាត្រា ចាប់ពីមាត្រា១៧០ដល់មាត្រា១៧១។

ខ្លឹមសារទាំងស្រុងនៃសេចក្តីព្រាងសេចក្តីស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលទទួលបានការឯកភាពគ្នានេះមានចុះហត្ថលេខាសង្ខេបនៅចុងសន្លឹកនៃទំព័រនីមួយៗ ដោយប្រធានក្រុមការងាររបស់គណបក្សទាំងពីរ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង ១៧: ០០នាទី នាថ្ងៃដដែលប្រកបដោយលទ្ធផលល្អ និងបរិយាកាសយោគយល់គ្នា ។

រាជធានីភ្នំពេញថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៥

ក្រុមការងារគណបក្សប្រជាជនកម្ពុជា
ប្រធាន

**ប៊ិន ឈិន**

ក្រុមការងារគណបក្សសង្គ្រោះជាតិ
ប្រធាន

**គួយ ប៊ុនរឿន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**

**អគ្គលេខាធិការដ្ឋាន**

លេខ ...៣៣៣១/១៥ អ.រ.ស.ក.ន.ល.និ

# សេចក្តីជូនដំណឹង

អគ្គលេខាធិការដ្ឋានរដ្ឋសភាមានកិត្តិយសសូមជម្រាបជូនសាធារណជនជ្រាបថា នៅថ្ងៃ ព្រហស្បតិ៍ ទី ១៩ ខែ មីនា ឆ្នាំ២០១៥ វេលាម៉ោង ៨: ០០ នាទីព្រឹក រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា កោះប្រជុំជាវិសាមញ្ញ នីតិកាលទី ៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា** តាមរបៀបវារៈដូចតទៅ :

**១-ការពិភាក្សា និងអនុម័តសេចក្តីស្នើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។**

**២-ការពិភាក្សា និងអនុម័តសេចក្តីស្នើច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។**

អាស្រ័យហេតុនេះ សូមសាធារណជនជ្រាប ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៥

**អគ្គលេខាធិការ**

**ឡេង ប៉េងឡុង**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋសភា**
**អគ្គលេខាធិការដ្ឋាន**
លេខ ៤១៩/១៥ អ.រ.ស.ការ.ស.ដ

# សេចក្តីជូនដំណឹង

**យោង** : - មាត្រា១៥១ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- មាត្រា៥ និងមាត្រា៦ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ការសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥។

អគ្គលេខាធិការដ្ឋានរដ្ឋសភា មានកិត្តិយសសូមជម្រាបជូនសាធារណជន មេត្តាជ្រាបថា : គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា នឹងធ្វើការជ្រើសរើសបេក្ខជនឈរឈ្មោះជាសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អនុលោមតាមមាត្រា៥ និងមាត្រា៦ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

ឥស្សរជនដែលមានបំណងឈរឈ្មោះជាបេក្ខជនក្នុងការជ្រើសរើសនេះ ត្រូវដាក់ពាក្យសុំឈរឈ្មោះជាបេក្ខជន ជូនគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ដោយមានភ្ជាប់មកជាមួយនូវ :

| | |
|---|---|
| ១- ជីវប្រវត្តិសង្ខេប | ០២ច្បាប់ |
| ២- សេចក្តីចម្លងសំបុត្រកំណើត | ០២ច្បាប់ |
| ៣- ច្បាប់ថតចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ | ០២ច្បាប់ |
| ៤- សេចក្តីប្រកាសអំពីសញ្ជាតិ (មានគំរូផ្តល់ជូន) | ០២ច្បាប់ |
| ៥- សេចក្តីបញ្ជាក់អំពីការចុះឈ្មោះបោះឆ្នោត ដោយអាជ្ញាធរឃុំ សង្កាត់ដែលខ្ញុំបាទ/នាងខ្ញុំបានចុះឈ្មោះបោះឆ្នោត | ០២ច្បាប់ |
| ៦- សញ្ញាបត្រថ្នាក់ឧត្តមសិក្សា ឬលិខិតបញ្ជាក់ថាបានបញ្ចប់ការសិក្សាចាប់ពីថ្នាក់ឧត្តមសិក្សាឡើងទៅ | ០២ច្បាប់ |
| ៧- លិខិតបញ្ជាក់អំពីបទពិសោធន៍ការងារយ៉ាងតិច ១០ ឆ្នាំដែលចេញឲ្យដោយអង្គភាពដែលខ្ញុំបាទ/នាងខ្ញុំបានបម្រើការងារ | ០២ច្បាប់ |
| ៨- សេចក្តីប្រកាសអំពីចំណងសហព័ទ្ធ ញាតិលោហិត និងញាតិពន្ធ (មានគំរូផ្តល់ជូន) | ០២ច្បាប់ |
| ៩- លិខិតថ្កោលទោស | ០២ច្បាប់ |
| ១០-រូបថតទំហំ ៤ x ៦ (រូបថតថ្មី ថតចំពីមុខ គ្មានពាក់វ៉ែនតា) | ០៣សន្លឹក |

អគ្គលេខាធិការដ្ឋានរដ្ឋសភានឹងទទួលពាក្យសុំឈរឈ្មោះជាបេក្ខជនចាប់ពីថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ រៀងរាល់ថ្ងៃ គិតទាំងថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ពេលព្រឹកចាប់ពីម៉ោង៧:០០ ដល់ម៉ោង១១:៣០នាទី និងពេលរសៀលចាប់ពីម៉ោង១៤:០០ ដល់ម៉ោង ១៧:៣០នាទី នៅនាយកដ្ឋានគ្រប់គ្រងបុគ្គលិក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ។

កាលបរិច្ឆេទឈប់ទទួលពាក្យ នៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៥ វេលាម៉ោង១៧:៣០នាទីរសៀល។

ព័ត៌មានផ្សេងៗ សូមទំនាក់ទំនងជាមួយនាយកដ្ឋានគ្រប់គ្រងបុគ្គលិក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ មីនា ឆ្នាំ២០១៥
**អគ្គលេខាធិការរដ្ឋសភា**

ឡេង ប៉េងឡុង

*** ទូរស័ព្ទទំនាក់ទំនង**
-ទូរស័ព្ទដៃ : ០១២ ៧៣៤ ៨១៦
០១១ ៩៧៧ ៩៩២
០១៥ ៩៧៧ ៧២៧

**សេចក្តីប្រកាសព័ត៌មាន**

**ស្តីពី**

**លទ្ធផលនៃជំនួបកំពូលរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ**

នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៤ នេះ វេលាម៉ោង ១០ និង ៣០ នាទីព្រឹក, នៅវិមានរដ្ឋសភា មានជំនួបកំពូលមួយរវាងគណបក្សប្រជាជនកម្ពុជាដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និង គណបក្សសង្គ្រោះជាតិដឹកនាំដោយ ឯកឧត្តម **សម រង្ស៊ី** ដើម្បីពិភាក្សាគ្នារកដំណោះស្រាយបញ្ហាមួយចំនួន ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

១-ចំពោះសំណើសុំរបស់ឯកឧត្តម **សម រង្ស៊ី** ទាក់ទងនឹងការដាក់ឱ្យដំណើរការស្ថានីយទូរទស្សន៍ និងការដាក់ឱ្យដំណើការស្ថានីយវិទ្យុផ្សាយបន្តទៅតាមបណ្តាខេត្ត, **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានផ្តល់ការឯកភាពជាគោលការណ៍ ដោយតម្រូវឱ្យក្រុមហ៊ុនពាក់ព័ន្ធត្រូវបំពេញបែបបទស្នើសុំអាជ្ញាប័ណ្ណនៅក្រសួងព័ត៌មាន។

២-ចំពោះការកែសម្រួលបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា, ថ្នាក់ដឹកនាំកំពូលនៃគណបក្សទាំងពីរបានឯកភាពគ្នាក្នុងការធ្វើវិសោធនកម្មប្រការ ៤៨ ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ដើម្បីរៀបចំឱ្យមានថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សនយោបាយដែលមានអាសនៈនៅក្នុងរដ្ឋសភា និងរៀបចំឱ្យមានប្រធានក្រុមភាគតិចនៅរដ្ឋសភា ដើម្បីជាគូសន្ទនាជាមួយនឹងប្រមុខរាជរដ្ឋាភិបាលទាក់ទងនឹងបញ្ហារបស់ប្រទេសជាតិ។ ប្រធានក្រុមភាគតិចនេះ នឹងមានឋានៈស្មើនាយករដ្ឋមន្ត្រី។ គណបក្សទាំងពីរនឹងជំរុញការធ្វើវិសោធនកម្មប្រការ ៤៨ ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានេះ ឱ្យបានឆាប់ ដោយចាត់ទុកជាអាទិភាព។ ដោយឡែក ចំណុចវិសោធនកម្មផ្សេងទៀតនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នឹងត្រូវពិភាក្សាគ្នានាពេលក្រោយទៀត នៅក្នុងយន្តការរបស់រដ្ឋសភា។

៣-ចំពោះរាល់បញ្ហាដែលនៅសេសសល់មិនទាន់ចុះសម្រុងគ្នា នៅក្នុងសេចក្តីស្នើសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប., ថ្នាក់ដឹកនាំកំពូលនៃគណបក្សទាំងពីរបានឯកភាពគ្នាដោះស្រាយបញ្ចប់ ហើយក្រុមការងារគណបក្សទាំងពីរនឹងបន្តជួបប្រជុំគ្នា ដើម្បីអនុវត្តតាមស្មារតីនេះនៅសប្តាហ៍ក្រោយ។

ជាមួយគ្នានេះដែរ ថ្នាក់ដឹកនាំកំពូលនៃគណបក្សទាំងពីរក៏បានឯកភាពគ្នាជំរុញការបញ្ចប់សេចក្តីស្នើសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប. និងសេចក្តីស្នើសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់បោះឆ្នោត ឱ្យរួចរាល់ចប់សព្វគ្រប់ជាមួយគ្នា យ៉ាងយូរនៅដំណាច់ខែកុម្ភៈ ឆ្នាំ២០១៥ ខាងមុខ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០១៤

សម រង្ស៊ី

ហ៊ុន សែន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្តីប្រកាសរួមស្តីពីលទ្ធផលនៃកិច្ចប្រជុំ
# រវាងថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សប្រជាជនកម្ពុជា
# និងគណបក្សសង្គ្រោះជាតិ

(វិមានរដ្ឋសភា ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៥)

ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៥ វេលាម៉ោង ១៦:០០ នាទី នៅវិមានរដ្ឋសភា ថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សប្រជាជនកម្ពុជា ដឹកនាំដោយ ឯកឧត្តម **ស ខេង** និងថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សសង្គ្រោះជាតិ ដឹកនាំដោយ ឯកឧត្តម **សម រង្ស៊ី** បានជួបប្រជុំពិភាក្សាគ្នា ដើម្បីដោះស្រាយចំណុចសេសសល់ដែលក្រុមការងារនៃគណបក្សទាំងពីរមិនទាន់ឯកភាពគ្នា លើសេចក្តីព្រាងសេចក្តីស្នើវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

ថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សទាំងពីរ បានដោះស្រាយបញ្ចប់នូវរាល់បញ្ហាដែលនៅសេសសល់ទាំងអស់ នៃសេចក្តីព្រាងសេចក្តីស្នើវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

ដោយឡែក ពាក់ព័ន្ធទៅនឹងការធានានិរន្តរភាព និងប្រក្រតីភាពនៃស្ថាប័នជាតិ ដើម្បីបង្ការភាពជាប់គាំងបន្ទាប់ពីការបោះឆ្នោត ថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សទាំងពីរបានព្រមព្រៀងគ្នាជាគោលការណ៍ ដើម្បីសិក្សាអំពីបញ្ហានេះ ហើយរៀបចំដាក់បញ្ចូលទៅក្នុងអត្ថបទច្បាប់សមស្របណាមួយ។

ថ្នាក់ដឹកនាំតំណាងរាស្ត្រនៃគណបក្សទាំងពីរបានឯកភាពគ្នា ដើម្បីរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងសេចក្តីស្នើច្បាប់នេះ និងសេចក្តីព្រាងសេចក្តីស្នើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នាពេលដ៏ខ្លីខាងមុខនេះ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៥

| | |
|---|---|
| ប្រធានក្រុមតំណាងរាស្ត្រ<br>គណបក្សប្រជាជនកម្ពុជា | ប្រធានក្រុមតំណាងរាស្ត្រ<br>គណបក្សសង្គ្រោះជាតិ |
| **ស ខេង** | **សម រង្ស៊ី** |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា
អគ្គលេខាធិការដ្ឋាន

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីលទ្ធផលនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា

អគ្គលេខាធិការដ្ឋានរដ្ឋសភា សូមជម្រាបជូនសាធារណៈជនមេត្តាជ្រាបថា នៅព្រឹកថ្ងៃព្រហស្បតិ៍ ទី១២ខែមីនាឆ្នាំ២០១៥វេលាម៉ោង០៨និង៣០នាទីព្រឹក គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាបាន បើកកិច្ចប្រជុំក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា។

**លទ្ធផលនៃកិច្ចប្រជុំមានដូចខាងក្រោម៖**

**១**-អង្គប្រជុំបានអនុម័តប្រគល់សេចក្តីស្នើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជូនគណៈកម្មការនីតិកម្មនិងយុត្តិធម៌នៃរដ្ឋសភា ពិនិត្យនិងសិក្សា ហើយធ្វើរបាយការណ៍ជូន គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាវិញ។

**២**-អង្គប្រជុំបានអនុម័តប្រគល់សេចក្តីស្នើច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ជូនគណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃរដ្ឋសភាពិនិត្យនិងសិក្សា ហើយធ្វើរបាយការណ៍ជូន គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាវិញ។

**៣**-អង្គប្រជុំបានអនុម័តលើសំណើសុំកោះប្រជុំរដ្ឋសភាជាវិសាមញ្ញ ក្នុងនីតិកាលទី៥នៃរដ្ឋសភា ក្នុងពេលឆាប់ខាងមុខនេះដើម្បីពិនិត្យនិងអនុម័តនូវ៖

៣.១-សេចក្តីស្នើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

៣.២-សេចក្តីស្នើច្បាប់ស្តីពី ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

អាស្រ័យដូចជម្រាបជូនខាងលើសូមសាធារណជនជ្រាបជាព័ត៌មាន។

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៥

**អគ្គលេខាធិការដ្ឋានរដ្ឋសភា**

វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២១៣ ៥៣៥, ២២០ ៦២៨
ទូរសារៈ (៨៥៥-២៣) ២២០ ៦២៥ សារអេឡិចត្រូនិចៈ sg@national-assembly.org.kh គេហទំព័រៈ www.national-assembly.org.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា
អគ្គលេខាធិការដ្ឋាន

## សេចក្ដីប្រកាសព័ត៌មាន
## ស្ដីពីលទ្ធផលកិច្ចប្រជុំរដ្ឋសភា ជាវិសាមញ្ញ នីតិកាលទី៥
## ថ្ងៃព្រហស្បតិ៍ ទី១៩ ខែមីនា ឆ្នាំ២០១៥

អគ្គលេខាធិការដ្ឋានរដ្ឋសភា មានកិត្តិយសសូមជម្រាបជូន សាធារណជនមេត្តាជ្រាបថា នៅថ្ងៃព្រហស្បតិ៍ទី១៩ ខែមីនា ឆ្នាំ២០១៥ វេលាម៉ោង ០៨:០០នាទីព្រឹក រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានបើកសម័យប្រជុំរដ្ឋសភា ជាវិសាមញ្ញ នីតិកាលទី៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្ដេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា**។ វត្តមានតំណាងរាស្ត្រ ពេលផ្ដើមការប្រជុំដំបូងមានចំនួន១០២រូប ។

ជាដំបូង អង្គសភាបានអនុម័ត សមាសភាពលេខាធិការ៣រូប សម្រាប់សម័យប្រជុំ រដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥នេះ រួមមាន៖

១- ឯកឧត្តម **ស្វស យ៉ារ៉ា**

២- លោកជំទាវ **បាន ស្រីមុំ**

៣- ឯកឧត្តម **គង់ សភា**

អង្គសភាបានអនុម័តរបៀបវារៈចំនួនពីរគឺ **ការពិភាក្សានិងអនុម័ត សេចក្ដីស្នើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** និង**ការពិភាក្សានិងអនុម័ត សេចក្ដីស្នើច្បាប់ ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ** មកធ្វើការពិភាក្សា និងអនុម័ត ចំនួន១០២ សំឡេង។

ចំពោះលទ្ធផលការប្រជុំពិភាក្សា និងអនុម័តរបៀបវារៈទាំងពីរ មានដូចខាងក្រោម៖

**១-ការពិភាក្សា និងអនុម័តសេចក្ដីស្នើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

សេចក្ដីស្នើច្បាប់នេះមានចំនួន៧ជំពូក ចែកចេញជា៦៦មាត្រា។ ឯកឧត្តមបណ្ឌិត **ម៉ែន បញ្ញា** ប្រធានគណៈកម្មការនីតិកម្ម និងយុត្តិធម៌ នៃរដ្ឋសភា ជាអ្នករាយការណ៍ជូនអង្គសភា អំពីលទ្ធផល

ការពិនិត្យនិងការសិក្សាសេចក្តីស្នើច្បាប់។ ឯកឧត្តម **ប៊ិន ឈិន** ឯកឧត្តម **អេង ឆៃអ៊ាង** និង សហការី តំណាង តំណាងរាស្ត្រហត្ថលេខី ជាអ្នកការពារសេចក្តីស្នើច្បាប់។

អង្គសភាបានពិភាក្សានិងអនុម័តសេចក្តីស្នើច្បាប់មួយជំពូកម្តងៗ មានលទ្ធផលដូចតទៅ:

-អង្គសភាបានអនុម័តយល់ព្រមទទួលយកសេចក្តីស្នើច្បាប់នេះ មកពិភាក្សានិងអនុម័តចំនួន ១០២ សំឡេង។

សមាជិករដ្ឋសភា មានមតិ ចំនួន០១រូបគឺឯកឧត្តម **សម រង្ស៊ី** មកពីគណបក្សសង្គ្រោះជាតិ។

-អង្គសភាបានអនុម័តយល់ព្រមជំពូកទី១ ចំនួន១០២ សំឡេង

-អង្គសភាបានអនុម័តយល់ព្រមជំពូកទី២ ចំនួន១០៣ សំឡេង

-អង្គសភាបានអនុម័តយល់ព្រមជំពូកទី៣ ចំនួន១០៣ សំឡេង

-អង្គភាបានអនុម័តយល់ព្រមជំពូកទី៤ ចំនួន១០៣ សំឡេង

-អង្គសភាបានអនុម័តយល់ព្រមជំពូកទី៥ ចំនួន១០៣ សំឡេង

-អង្គសភាបានអនុម័តយល់ព្រមជំពូកទី៦ ចំនួន១០៣ សំឡេង

-អង្គសភាបានអនុម័តយល់ព្រមជំពូកទី៧ ចំនួន១០៣ សំឡេង

-អង្គសភាបានអនុម័តយល់ព្រមខ្លឹមសារទាំងមូល នៃសេចក្តីស្នើច្បាប់ចំនួន ១០៣ សំឡេង។

**២-ការពិភាក្សា និងអនុម័តសេចក្តីស្នើច្បាប់ ស្តីពីការ បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ**

សេចក្តីស្នើច្បាប់នេះមានចំនួន១២ជំពូក ចែកចេញជា១៧១មាត្រា។ ឯកឧត្តមបណ្ឌិត **ម៉ែន សំអន** ប្រធានគណៈកម្មការនីតិកម្ម និងយុត្តិធម៌ នៃរដ្ឋសភា ជាអ្នករាយការណ៍ជូនអង្គសភា អំពីលទ្ធផលការពិនិត្យនិងការសិក្សាសេចក្តីព្រាងច្បាប់។

ឯកឧត្តម **ប៊ិន ឈិន** ឯកឧត្តម **អេង ឆៃអ៊ាង** និងសហការី តំណាង តំណាងរាស្ត្រហត្ថលេខី ជាអ្នកការពារសេចក្តីស្នើច្បាប់។

អង្គសភាបានពិភាក្សា និងអនុម័តសេចក្តីស្នើច្បាប់ មួយជំពូកម្តងៗ មានលទ្ធផលដូចតទៅ:

-អង្គភាបានអនុម័តយល់ព្រមទទួលយកសេចក្តីស្នើច្បាប់នេះ មកពិភាក្សានិងអនុម័តចំនួន ១០៣ សំឡេង។

-អង្គសភាបានអនុម័តយល់ព្រមជំពូកទី១ ចំនួន១០៣ សំឡេង

-អង្គសភាបានអនុម័តយល់ព្រមជំពូកទី២ ចំនួន១០៣ សំឡេង

-អង្គសភាបានអនុម័តយល់ព្រមជំពូកទី៣ ចំនួន១០៣ សំឡេង

-អង្គសភាបានអនុម័តយល់ព្រមជំពូកទី៤ ចំនួន១០៣ សំឡេង

-អង្គសភាបានអនុម័តយល់ព្រមជំពូកទី៥ ចំនួន១០៣ សំឡេង

-អង្គសភាបានអនុម័តយល់ព្រមជំពូកទី៦ ចំនួន១០៣ សំឡេង

-អង្គសភាបានអនុម័តយល់ព្រមជំពូកទី៧ ចំនួន១០៣ សំឡេង

-អង្គសភាបានអនុម័តយល់ព្រមជំពូកទី៨ ចំនួន១០១ សំឡេង

-អង្គសភាបានអនុម័តយល់ព្រមជំពូកទី៩ ចំនួន១០១ សំឡេង

-អង្គសភាបានអនុម័តយល់ព្រមជំពូកទី១០ ចំនួន១០១ សំឡេង

-អង្គសភាបានអនុម័តយល់ព្រមជំពូកទី១២ ចំនួន១០១ សំឡេង

-អង្គសភាបានអនុម័តយល់ព្រមខ្លឹមសារទាំងមូល នៃសេចក្តីស្នើច្បាប់ចំនួន ១០១ សំឡេង។

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា បានប្រកាសបិទសម័យប្រជុំរដ្ឋសភា ជាវិសាមញ្ញ នីតិកាលទី៥ នៅវេលាម៉ោង១៤:៥០នាទីចាប់ពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ នេះទៅ។

អាស្រ័យហេតុនេះ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥

**អគ្គលេខាធិការដ្ឋានរដ្ឋសភា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

## បញ្ជីរាយនាមបេក្ខជនដែលបានដាក់ពាក្យសុំឈរឈ្មោះ
## ជាសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (មានគ្រប់លក្ខខណ្ឌ)
## ពីថ្ងៃទី ២៧ ខែ មីនា ដល់ថ្ងៃទី៦ ខែ មេសា ឆ្នាំ ២០១៥

| ល.រ | គោត្តនាម -នាម | ភេទ |
|---|---|---|
| ១ | ហាឡេ ពុទ្ធា | ប្រុស |
| ២ | ឌុច សុន | ប្រុស |
| ៣ | អ៊ុក ស៊ុយ | ប្រុស |
| ៤ | ឯម សុផាត | ប្រុស |
| ៥ | ស៊ិក ប៊ុនហុក | ប្រុស |
| ៦ | មាន សតិ | ប្រុស |
| ៧ | គួយ ប៊ុនរឿន | ប្រុស |
| ៨ | តែ ម៉ានីរ៉ុង | ស្រី |
| ៩ | រ៉ុង ឈុន | ប្រុស |
| ១០ | កែត យី | ប្រុស |
| ១១ | ម៉ៅ សុគារិទ្ធ | ប្រុស |
| ១២ | ថោង ស៊ីម | ប្រុស |
| ១៣ | មុត ចន្ថា | ប្រុស |
| ១៤ | យឹម ឡាគី | ប្រុស |
| ១៥ | សុក្រុលៈ នីយ៉ោ | ប្រុស |
| ១៦ | សួន រីដា | ប្រុស |
| ១៧ | រស់ សួ | ប្រុស |
| ១៨ | ហ៊ីង ធីឫទ្ធិ | ប្រុស |
| ១៩ | ជុង ជុងី | ប្រុស |

| | | |
|---|---|---|
| ២០ | **ឃឹម សុជាតិ** | ប្រុស |
| ២១ | **រិតខ ម៉ិនធឿន** | ប្រុស |
| ២២ | **សោម ច័ន្ទឌីណា** | ប្រុស |
| ២៣ | **សំរិទ្ធី ដួងហាក់** | ប្រុស |
| ២៤ | **សៀក សុផាត** | ប្រុស |

បញ្ជីនេះត្រូវបានគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា អនុម័តនៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៥។

ភ្នំពេញ, ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៥

**ជ.គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា**

**ប្រធាន**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រដ្ឋសភា

**បញ្ជីរាយនាមបេក្ខជនដែលបានដាក់ពាក្យសុំឈរឈ្មោះ**
**ជាសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (មានគ្រប់លក្ខខណ្ឌ)**
**ពីថ្ងៃទី ២៧ ខែ មីនា ដល់ថ្ងៃទី ៦ ខែ មេសា ឆ្នាំ ២០១៥**

| ល.រ | គោត្តនាម-នាម | ភេទ | លក្ខខណ្ឌជ្រើសរើស | | | | | | | | | | | អាសយដ្ឋាន (ស្រុក ខេត្ត) និងលេខទូរស័ព្ទ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | អាយុ | សញ្ញាបត្រ | បទពិសោធន៍ការងារ | | លិខិតបញ្ជាក់អំពី: (១) សំបុត្រកំណើត, (២) អត្តសញ្ញាណប័ណ្ណ, (៣) សញ្ជាតិ, (៤) ការចុះឈ្មោះបោះឆ្នោត, (៥) សមាព័ន្ធ ញាតិលោហិត និងញាតិពន្ធ, (៦) លិខិតថ្កោលទោស | | | | | | |
| | | | | | តួនាទីអង្គភាព (បច្ចុប្បន្ន) | រយៈពេលសរុប (ឆ្នាំ) | (១) | (២) | (៣) | (៤) | (៥) | (៦) | |
| ១ | **ហាឡ្យ ឤន្ទា** | ប្រុស | ៥០ឆ្នាំ | បណ្ឌិតច្បាប់ | នាយកអង្គការ NICFEC | **១៧ឆ្នាំ** | ✓ | ✓ | ✓ | ✓ | ✓ | ✓ | -ខណ្ឌចំការមន រាជធានីភ្នំពេញ -០១២ ៩៥៥ ៦៦៦ |
| ២ | **ឌុច សុន** | ប្រុស | ៦០ឆ្នាំ | ប.ជាន់ខ្ពស់រដ្ឋបាលសាធារណៈ | និវត្តជន ក្រសួងមហាផ្ទៃ | **៣៥ឆ្នាំ** | ✓ | ✓ | ✓ | ✓ | ✓ | ✓ | -ខណ្ឌមានជ័យ រាជធានីភ្នំពេញ -០១២ ៦០៥ ៨៥៥ |
| ៣ | **អ៊ុក ស៊ីយ** | ប្រុស | ៤៣ឆ្នាំ | ប.នីតិសាស្ត្រ | មន្ត្រីរាជការ | **២៥ឆ្នាំ** | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ស្រុកកំពង់សីលា ខេត្តព្រះសីហនុ -០១៦ ៨៥៥ ៤៨៧ -០១៧ ៥០៥ [illegible] |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៤ | **ឯម សុផាត** | ប្រុស | ៥៨ឆ្នាំ | -បណ្ឌិតវិទ្យាសាស្ត្រនយោបាយ<br>-បរិ.ជាន់ខ្ពស់វិទ្យាសាស្ត្រនយោបាយ<br>-ទើរដ្ឋបាលសាធារណៈ | សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | ៣៦ឆ្នាំ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | -ខណ្ឌទួលគោក រាជធានីភ្នំពេញ<br>-០១១ ៩៧២ ៤២៤<br>០១៦ ៩៩២ ៤២៤ |
| ៥ | **ស៊ិក ម៉ុនហុត** | ប្រុស | ៦៩ឆ្នាំ | សញ្ញាបត្រឧត្តមសិក្សាទស្សនៈវិជ្ជា | តំណាងរាស្ត្រមណ្ឌលកំពង់ធំ | ៣៩ឆ្នាំ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | -ខណ្ឌចំការមន រាជធានីភ្នំពេញ<br>-០១២ ៩៨៩ ០៩៨ |
| ៦ | **មាន សតិ** | ប្រុស | ៦៣ឆ្នាំ | បរិ.វិទ្យាសាស្ត្រផ្នែកគណិតវិទ្យា | សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | ៣៤ឆ្នាំ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | -ខណ្ឌទួលគោក រាជធានីភ្នំពេញ<br>-០១២ ៩៣០ ១៤៥ |
| ៧ | **គួយ ម៉ុនរឿន** | ប្រុស | ៤៨ឆ្នាំ | បរិ.ពាណិជ្ជសាស្ត្រ | អតីតតំណាងរាស្ត្រ | ២១ឆ្នាំ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | -ខណ្ឌចំការមន រាជធានីភ្នំពេញ<br>-០១១ ៧១៦ ៩៩៩ |
| ៨ | **តែ ម៉ានីរ៉ុង** | ស្រី | ៦២ឆ្នាំ | បរិ.ជាន់ខ្ពស់រដ្ឋបាលសាធារណៈ | មន្ត្រីនិវត្តជន | ៣៣ឆ្នាំ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | -ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ<br>-០១២ ៨២២ ៨៨៣ |
| ៩ | **រ៉ុង ឈុន** | ប្រុស | ៤៦ឆ្នាំ | បរិ.ផ្នែកគណិតវិទ្យា | ប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ | ១៥ឆ្នាំ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | -ស្រុកស្អាង ខេត្តកណ្ដាល<br>-០១២ ៩៣០ ៧០៦ |
| ១០ | **កែត ឈី** | ប្រុស | ៤៨ឆ្នាំ | -សញ្ញាបត្រមធ្យមនីតិសាស្ត្រ<br>-បរិ.នីតិសាស្ត្រ<br>-បរិ.ជាន់ខ្ពស់នីតិសាស្ត្រ | អគ្គលេខាធិការរងរដ្ឋសភា | ២៥ឆ្នាំ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | -ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ<br>-០១២ ៣៧២ ៨២៨ |
| ១១ | **ម៉ៅ សុគារិទ្ធ** | ប្រុស | ៤៨ឆ្នាំ | បរិ.នីតិសាស្ត្រ | សមាជិកគណកម្មាធិការជាតិរៀបចំការបោះឆ្នោត | ២៣ឆ្នាំ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ<br>០១៥ ៧៨៧ ៦៧៧ |
| ១២ | **ម៉ោង ស៊ីម** | ប្រុស | ៤៨ឆ្នាំ | -បរិ.ជាន់ខ្ពស់នីតិសាស្ត្រ<br>-បរិ.នីតិសាស្ត្រ<br>-បរិ.ធនាគារអង់គ្លេស | មន្ត្រីរាជការ នៃក្រសួងមហាផ្ទៃ | ២៧ឆ្នាំ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | -ខណ្ឌសែនសុខ រាជធានីភ្នំពេញ<br>-០១៦ ៨៤២ ០៦៦<br>-០៩៧ ៧៨៥២ ០៦៦ |
| ១៣ | **នុត ចន្ថា** | ប្រុស | ៤៩ឆ្នាំ | បរិ.នីតិសាស្ត្រ | នាយកខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ រដ្ឋសភា | ២៤ឆ្នាំ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | -ខណ្ឌមានជ័យ រាជធានីភ្នំពេញ<br>០១៧ ៨៨១ ២៩៦ |
| ១៤ | **ឈឹម ឡុងតី** | ប្រុស | ៤០ឆ្នាំ | សញ្ញាបត្រវិស្វករ | មន្ត្រីរាជការក្រសួងឧស្សាហកម្មនិងសិប្បកម្ម | ២០ឆ្នាំ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | -ខណ្ឌទួលគោក រាជធានីភ្នំពេញ<br>-០១៦ ៦០៦ ១៩០<br>-០១២ ៥២៣ ៧៩៤ |
| ១៥ | **សុគុណៈ និរ៉េះ** | ប្រុស | ៤៥ឆ្នាំ | បរិ.ជាន់ខ្ពស់នីតិសាស្ត្រ | អគ្គលេខាធិការរងគ.ជ.ប | ៣៧ឆ្នាំ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | -ខណ្ឌចំការមន រាជធានីភ្នំពេញ<br>-០១៦ ៥៩៦ ១៨៨ |
| ១៦ | **សុខ វីជោ** | ប្រុស | ៤៣ឆ្នាំ | សញ្ញាបត្រវេជ្ជបណ្ឌិត | វេជ្ជបណ្ឌិត | ៣៧ឆ្នាំ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | -ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ<br>-០១២ ៤៤១ ០០២<br>-០១៦ ៧២៧ ២០៩ |
| ១៧ | **រស់ សុ** | ប្រុស | ៣៨ឆ្នាំ | បរិ.នីតិសាស្ត្រ | មន្ត្រីកិច្ចការបោះឆ្នោតនៃគណបក្សសង្គ្រោះជាតិ | ១៤ឆ្នាំ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | -ខណ្ឌចំការមន រាជធានីភ្នំពេញ<br>-០១២ ៣៩០ ៣១១<br>-០១៦ ៥៣៥ ៩២៣ |
| ១៨ | **ហ៊ីង ធីរទ្ធិ** | ប្រុស | ៤៩ឆ្នាំ | -បរិ.ជាន់ខ្ពស់នីតិសាស្ត្រ | ព្រះរាជអាជ្ញា នៃមហាអយ្យការអមតុលាការកំពូល | ១៧ឆ្នាំ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | -ខណ្ឌទួលគោក រាជធានីភ្នំពេញ<br>-០១៦ ៨៣៣ ៦៨៨ |
| ១៩ | **ជុំ ជុំទី** | ប្រុស | ៤៦ឆ្នាំ | -បរិ.នីតិសាស្ត្រ | មេធាវី | ១០ឆ្នាំ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | -ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល<br>-០១២ ២៩០ ៦៧៨<br>-០១៦ ៩៤០ ០៩៩ |
| ២០ | **ឈឹម សុជាតិ** | ប្រុស | ៥០ឆ្នាំ | -បរិ.វិស្វករកសិកម្ម<br>-បរិ.ជាន់ខ្ពស់គ្រប់គ្រង<br>-បណ្ឌិតគ្រប់គ្រង | គ្រូបង្រៀននៅសាលាជាតិកសិកម្មព្រែកលៀប | ១៣ឆ្នាំ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | -ស្រុកកៀនស្វាយ ខេត្តកណ្ដាល<br>-០១៥ ៩៩៩ ១៣៦<br>-០១៧ ៩៩៩ ១៣៦ |
| ២១ | **អ៊ិង ម៉ុនរឿន** | ប្រុស | ៥៧ឆ្នាំ | -បរិ.ជាន់ខ្ពស់រដ្ឋបាលសាធារណៈ<br>-បរិ.ជាន់ខ្ពស់ប្រវត្តិសាស្ត្រ<br>-បណ្ឌិតឯកទេសរដ្ឋបាលសាធារណៈ | -មន្ត្រីអប់រំការិយាល័យរដ្ឋបាល | ២១ឆ្នាំ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | -ខណ្ឌទួលគោក<br>-០១២ ៩៣០ ៤៩២ |
| ២២ | **សោម ច័ន្ទនីណា** | ប្រុស | ៥១ឆ្នាំ | -បរិ.ជាន់ខ្ពស់នីតិសាស្ត្រ<br>-បរិ.នីតិសាស្ត្រ | សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | ១២ឆ្នាំ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | -ខណ្ឌផ្សារដើមថ្កូវ<br>-០១២ ៤២៨ ៨៥៨<br>-០៩៦ ៤២៥ ៨៨៥៥ |
| ២៣ | **ស៊ិទ្ធី ដួងហាក់** | ប្រុស | ៥៣ឆ្នាំ | -បរិ.ជាន់ខ្ពស់វិទ្យាសាស្ត្រនយោបាយ<br>-បរិ.ភាសា និងអក្សរសាស្ត្រឡាំ | អ្នកសារព័ត៌មាន | ២៧ឆ្នាំ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | -ខណ្ឌសែនសុខ រាជធានីភ្នំពេញ<br>-០១២ ៨០២ ៨៨៣<br>-០១២ ៧២២ ៩៩៦ |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២៤ | **សៀក សុផាត** | ប្រុស | ៤២ឆ្នាំ | បណ្ឌិតគ្រប់គ្រងធនធានធម្មជាតិ | ក្រុមបង្រៀនសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | ១៥ឆ្នាំ | ✓ | ✓ | ✓ | ✓ | ✓ | ✓ | -ខណ្ឌទួលគោក<br>-០១៦ ៥០៦ ៨៨៨ |

•កំណត់សម្គាល់ : ✓ = មាន

○ = មិនមាន

•បញ្ឈប់បញ្ជីត្រឹមចំនួន ២៤ នាក់ (ប្រុស ២៣ នាក់ និងស្រី ១ នាក់)។

បញ្ជីនេះត្រូវបានគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាអនុម័តនៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៥។

ភ្នំពេញ, ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៥

**ជ.គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា**

**ប្រធាន**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រដ្ឋសភា
- លេខ: ២៩៨ រសា

**សូមគោរពជូន**

**សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានគណបក្សប្រជាជនកម្ពុជា**

**កម្មវត្ថុ:** សំណើសុំជ្រើសរើសបេក្ខជនសមាជិកគណ:កម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងបញ្ជី ដែលសម្រេចដោយគណ:កម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា។

**យោង:** - មាត្រា១៥១ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញ
- មាត្រា៥ និងមាត្រា៦ នៃច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណ:កម្មាធិការជាតិរៀបចំការបោះឆ្នោត
- សេចក្តីសម្រេចគណ:កម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ស្តីពី "កំណត់បែបបទ និងនីតិវិធីជ្រើសរើសបេក្ខជនសមាជិកគណ:កម្មាធិការជាតិរៀបចំការបោះឆ្នោត
- របាយការណ៍របស់អគ្គលេខាធិការដ្ឋានរដ្ឋសភា ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៥
- ស្មារតីអង្គប្រជុំគណ:កម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៥

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូន **សម្ដេចអគ្គមហាធម្មពោធិសាល** មេត្តាជ្រាបថា គណ:កម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាបានសម្រេចជ្រើសរើសបេក្ខជន សមាជិកគណ:កម្មាធិការជាតិរៀបចំការបោះឆ្នោត ចំនួន ២៤ រូប ដែលមានរាល់លក្ខណ:សម្បត្តិ ស្របតាមច្បាប់បោះឆ្នោត ដូចមានបញ្ជីជូនភ្ជាប់មកជាមួយនេះ។ ខ្ញុំសូមស្នើ គណបក្សប្រជាជនកម្ពុជា ជ្រើសរើសបេក្ខជន ៤រូប ក្នុងចំណោមបេក្ខជនក្នុងបញ្ជីខាងលើ ហើយសូមស្នើគណបក្សប្រជាជនកម្ពុជា សម្របសម្រួលជាមួយគណបក្សសង្គ្រោះជាតិ ជ្រើសរើសបេក្ខជន ១រូបទៀត ហើយផ្ញើបេក្ខជនទាំង ៥រូប មកគណ:កម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា យ៉ាងយូរនៅថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០១៥ ដើម្បីគណ:កម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា រៀបចំសមាសភាពគណ:កម្មាធិការជាតិរៀបចំការបោះឆ្នោត ដាក់ជូនរដ្ឋសភា បោះឆ្នោតទុកចិត្ត នាពេលខាងមុខ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **សម្ដេចអគ្គមហាធម្មពោធិសាល** មេត្តាជួយសម្រួលតាមកម្មវត្ថុខាងលើ តាមការគួរ។

សូម **សម្ដេចអគ្គមហាធម្មពោធិសាល** មេត្តាទទួលនូវការគោរពរាប់អាន អំពីខ្ញុំ។

ភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៥
**ប្រធានរដ្ឋសភា**

**សម្ដេចអគ្គមហាពញាចក្រី ហេង សំរិន**

ឯកសារជូនភ្ជាប់:
-បញ្ជីបេក្ខជនឈរឈ្មោះ ០១ច្បាប់

ចម្លងជូន
-គណ:កម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រដ្ឋសភា
-លេខ ៤៩៥ រ.ស

## សូមជម្រាបជូន
## ឯកឧត្តម សម រង្ស៊ី ប្រធានគណបក្សសង្គ្រោះជាតិ

**កម្មវត្ថុ:** សំណើសុំជ្រើសរើសបេក្ខជនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងបញ្ជី ដែលសម្រេចដោយគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា។

**យោង:** - មាត្រា១៥១ថ្មី(ពីរ) នៃរដ្ឋធម្មនុញ្ញ
- មាត្រា៥ និងមាត្រា៦ នៃច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- សេចក្តីសម្រេចគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ស្តីពី "កំណត់បែបបទ និងនីតិវិធីជ្រើសរើសបេក្ខជនសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- របាយការណ៍របស់អគ្គលេខាធិការដ្ឋានរដ្ឋសភា ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០១៥
- ស្មារតីអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៥

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តម** មេត្តាជ្រាបថា គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាបានសម្រេចជ្រើសរើសបេក្ខជន សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំនួន ២៨ រូប ដែលមានរាល់លក្ខណៈសម្បត្តិ ស្របតាមច្បាប់បោះឆ្នោត ដូចមានបញ្ជីជូនភ្ជាប់មកជាមួយនេះ។ ខ្ញុំសូមស្នើ គណបក្សសង្គ្រោះជាតិ ជ្រើសរើសបេក្ខជន ៤រូប ក្នុងចំណោមបេក្ខជនក្នុងបញ្ជីខាងលើ ហើយសូមស្នើគណបក្សសង្គ្រោះជាតិ សម្របសម្រួលជាមួយ គណបក្សប្រជាជនកម្ពុជា ជ្រើសរើសបេក្ខជន ១រូបទៀត ហើយផ្ញើបេក្ខជនទាំង ៥រូប មកគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា យ៉ាងយូរនៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៥ ដើម្បីគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា រៀបចំសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដាក់ជូនរដ្ឋសភាបោះឆ្នោតទុកចិត្ត នាពេលខាងមុខ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម** មេត្តាជួយសម្រួលតាមកម្មវត្ថុខាងលើតាមការគួរ។

សូម **ឯកឧត្តម** មេត្តាទទួលនូវការរាប់អាន អំពីខ្ញុំ។

ភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៥
**ប្រធានរដ្ឋសភា**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**

<u>ឯកសារជូនភ្ជាប់:</u>
-បញ្ជីបេក្ខជនឈរឈ្មោះ ០១ច្បាប់

ចម្លងជូន
-គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា

វិមានរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៣ ៥៣៥, ២២០ ៦២៨
ទូរសារ: (៨៥៥-២៣) ២២០ ៦២៩ សារអេឡិចត្រូនិច: sg@national-assembly.org.kh គេហទំព័រ: www.national-assembly.org.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា
អគ្គលេខាធិការដ្ឋាន

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីលទ្ធផលសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៥
## ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៥

អគ្គលេខាធិការដ្ឋានរដ្ឋសភា មានកិត្តិយសសូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា នៅព្រឹកថ្ងៃព្រហស្បតិ៍ទី០៩ ខែមេសា ឆ្នាំ២០១៥ វេលាម៉ោង៨:០០នាទី រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា បានបន្តសម័យប្រជុំលើកទី៤នីតិកាលទី៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា។ វត្តមានតំណាងរាស្ត្រពេលផ្តើមសម័យប្រជុំមានចំនួន១១៨រូប។

អង្គសភាបានដំណើរការបោះឆ្នោត តាមរបៀបវារៈចំនួន២ ដែលមានលទ្ធផលដូចតទៅ៖

**១**-អង្គសភាបានធ្វើការបោះឆ្នោតទុកចិត្ត លើសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយសំឡេងយល់ព្រមចំនួន១១៣សំឡេង ដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| **១-ឯកឧត្តម សិក ប៊ុនហុក** | **ប្រធាន** |
| **២-ឯកឧត្តម គួយ ប៊ុនរឿន** | **អនុប្រធាន** |
| **៣-ឯកឧត្តម មាន សតិ** | **សមាជិក** |
| **៤-លោក រ៉ុង ឈុន** | **សមាជិក** |
| **៥-ឯកឧត្តម ឌុច សុន** | **សមាជិក** |
| **៦-លោក ហ៊ីង ធីឫទ្ធិ** | **សមាជិក** |
| **៧-ឯកឧត្តម ឯម សុផាត** | **សមាជិក** |
| **៨-លោកស្រី តែ ម៉ានីរ៉ុង** | **សមាជិកា** |
| **៩-លោក ហាង្ស ពុទ្ធា** | **សមាជិក** |



វិមានរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៣ ៥៣៥, ២២០ ៦២៨
ទូរសារ: (៨៥៥-២៣) ២២០ ៦២៥ សារអេឡិចត្រូនិច: sg@national-assembly.org.kh គេហទំព័រ: www.national-assembly.org.kh

## **តារាងសង្ខេបលទ្ធផលបោះឆ្នោត**

- **ឆ្នាំ១៩៩៣ - ១៩៩៨** (ថ្ងៃទី២៣ - ២៨ ខែឧសភា ឆ្នាំ១៩៩៣)

| **ឈ្មោះគណបក្សនយោបាយ** | **ចំនួនអាសនៈ** |
|---|---|
| គណបក្ស ហ៊្វុនស៊ិនប៉ិច | ៥៨ អាសនៈ |
| គណបក្ស ប្រជាជនកម្ពុជា | ៥១ អាសនៈ |
| គណបក្ស សេរីនិយមព្រះពុទ្ធសាសនា | ១០ អាសនៈ |
| គណបក្ស ម៉ូលីណាកា និងអ្នកតស៊ូខ្មែរ | ១ អាសនៈ |

- **ឆ្នាំ១៩៩៨ - ២០០៣** ( ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៨)

| **ឈ្មោះគណបក្សនយោបាយ** | **ចំនួនអាសនៈ** |
|---|---|
| គណបក្ស ប្រជាជនកម្ពុជា | ៦៤ អាសនៈ |
| គណបក្ស ហ៊្វុនស៊ិនប៉ិច | ៤៣ អាសនៈ |
| គណបក្ស សម រង្ស៊ី | ១៥ អាសនៈ |

- **ឆ្នាំ២០០៣ - ២០០៨** ( ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០៣)

| **ឈ្មោះគណបក្សនយោបាយ** | **ចំនួនអាសនៈ** |
|---|---|
| គណបក្ស ប្រជាជនកម្ពុជា | ៧៣ អាសនៈ |
| គណបក្ស ហ៊្វុនស៊ិនប៉ិច | ២៦ អាសនៈ |
| គណបក្ស សម រង្ស៊ី | ២៤ អាសនៈ |

- **ឆ្នាំ២០០៨ - ២០១៣** ( ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០៨)

| **ឈ្មោះគណបក្សនយោបាយ** | **ចំនួនអាសនៈ** |
|---|---|
| គណបក្ស ប្រជាជនកម្ពុជា | ៩០ អាសនៈ |
| គណបក្ស សម រង្ស៊ី | ២៦ អាសនៈ |
| គណបក្ស សិទ្ធិមនុស្ស | ៣ អាសនៈ |
| គណបក្ស នរោត្តម រណឫទ្ធិ | ២ អាសនៈ |
| គណបក្សហ៊្វុនស៊ិនប៉ិច | ២ អាសនៈ |

- **ឆ្នាំ២០១៣ - ២០១៨** (ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣)

| **ឈ្មោះគណបក្សនយោបាយ** | **ចំនួនអាសនៈ** |
|---|---|
| គណបក្ស ប្រជាជនកម្ពុជា | ៦៨ អាសនៈ |
| គណបក្ស សង្គ្រោះជាតិ | ៥៥ អាសនៈ |